**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៥-២០២៤

## *មគ្គុទេសន៍ក្នុងការពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីបង្កើនអត្រាចុះបញ្ជីអត្រានុកូលដ្ឋាន និងលើកកម្ពស់ការងារអត្តសញ្ញាណកម្ម*

“មនុស្សគ្រប់រូបត្រូវបានកំណត់អត្តសញ្ញាណ”

*រាជធានីភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ..........*

*(សេចក្តីព្រាង១ ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥)*

# មាតិកា


I. សេចក្តីផ្តើម ..... 1
II. អក្សរកាត់ ..... 6
III. បរិបទយុទ្ធសាស្ត្រ ..... 7
IV. ក្របខ័ណ្ឌយុទ្ធសាស្ត្រ ..... 10
៤.១. ចក្ខុវិស័យ និងបេសកកម្ម ..... 10
៤.២. ក្របខ័ណ្ឌសកម្មភាពសំខាន់ៗ ..... 11
៤.២.១. ការប្តេជ្ញាចិត្តខាងនយោបាយ ..... 11
៤.២.២. ការចូលរួមរបស់សាធារណជន និងការជំរុញឱ្យមានតម្រូវការ ..... 12
៤.២.៣. ការសម្របសម្រួល ..... 14
៤.២.៤. គោលនយោបាយ ច្បាប់ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា ..... 15
៤.២.៥. ហេដ្ឋារចនាសម្ព័ន្ធ និងធនធាន ..... 17
៤.២.៦. នីតិវិធីប្រតិបត្តិ ការអនុវត្ត និងការច្នៃប្រឌិត ..... 18
៤.២.៧. ការផលិត ការផ្សព្វផ្សាយ និងការប្រើប្រាស់ស្ថិតិអត្រានុកូលដ្ឋាន និងព័ត៌មានប្រជាពលរដ្ឋ ..... 20
V. គោលបំណងយុទ្ធសាស្ត្រ ..... 22
VI. គោលដៅ និងសកម្មភាព ..... 32
៦.១. គោលបំណងទី១ ៖ រៀបចំក្របខ័ណ្ឌច្បាប់សម្រាប់កំណត់អត្តសញ្ញាណបុគ្គល ..... 32
៦.១.១. គោលដៅទី១ ៖ អនុម័តច្បាប់ថ្មីស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋានឱ្យបានមុនឆ្នាំ ២០១៧ ..... 32
៦.១.២. គោលដៅទី២ ៖ អនុម័តអនុក្រឹត្យថ្មីស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន ឱ្យបានមុន ឆ្នាំ ២០១៧ ..... 33
៦.១.៣. គោលដៅទី៣ ៖ អនុម័តវិសោធនកម្មច្បាប់ដែលចាំបាច់សម្រាប់ការបង្កើត ប.រ.អ.ព.(IPIS) ឱ្យបានមុនឆ្នាំ២០១៧ ..... 34
៦.១.៤. គោលដៅទី៤ ៖ ធ្វើវិសោធនកម្មអនុក្រឹត្យដែលមានការចាំបាច់ក្នុងការបង្កើត ប.រ.អ.ព.(IPIS) ឱ្យបានមុនឆ្នាំ២០១៧ ..... 35
៦.២. គោលបំណងទី២ ៖ បង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋានដែលមានលក្ខណ:ជាសកល និងមានការឆ្លើយតប ..... 38
៦.២.១. គោលដៅទី១ ៖ បង្កើនអត្រាគ្របដណ្តប់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន នៅត្រឹមឆ្នាំ២០២៤ ..... 38
៦.២.២. គោលដៅទី២ ៖ បង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានមានលក្ខណ:ជាសកល ដោយប្រើប្រព័ន្ធ ប.វ.គ.ព.(ICT) ឱ្យបានត្រឹមឆ្នាំ២០១៨ ..... 42
៦.២.៣. គោលដៅទី៣ ៖ បង្កើតប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋាន ឱ្យបានត្រឹមឆ្នាំ២០២៣ ..... 44
៦.២.៤. គោលដៅទី៤ ៖ ភ្ជាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋានជាមួយនឹងប្រព័ន្ធជំនួយផ្សេងទៀតសម្រាប់ការផ្លាស់ប្តូរទិន្នន័យ ឱ្យបានត្រឹមឆ្នាំ២០២៤ ..... 45

៦.៣. គោលបំណងទី៣ ៖ បង្កើតប្រព័ន្ធរួមអត្តសញ្ញាណកម្មពលរដ្ឋ (IPIS) ....... 47
៦.៣.១. គោលដៅទី១ ៖ បង្កើតឱ្យមានលេខកូដអត្តសញ្ញាណខ្មែរ (KIDC) ដល់ប្រជាជនទាំងអស់ដែលបានកំណត់អត្តសញ្ញាណរួច ឱ្យបានត្រឹមឆ្នាំ២០១៩ ....... 47
៦.៣.២. គោលដៅទី២ ៖ ការបង្កើតបញ្ជីពលរដ្ឋ (Population Registry) ឱ្យបានត្រឹមឆ្នាំ២០១៩ ....... 48
៦.៣.៣.គោលដៅទី៣ ៖ បង្កើតប្រព័ន្ធគ្រប់គ្រងការស្នាក់នៅទំនើប និងភ្ជាប់ជាមួយនឹង ប.រ.អ.ព.(IPIS) ឱ្យបានត្រឹមឆ្នាំ២០១៩ ....... 48
៦.៣.៤. គោលដៅទី៤ ៖ បង្កើតប្រព័ន្ធគ្រប់គ្រងសញ្ជាតិដែលមានប្រសិទ្ធភាព និងភ្ជាប់ជាមួយ ប.រ.អ.ព.(IPIS) ឱ្យបានត្រឹមឆ្នាំ២០១៩ ....... 50
៦.៣.៥.គោលដៅទី៥ ៖ ធ្វើទំនើបកម្ម និងភ្ជាប់ប្រព័ន្ធអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាមួយនឹង ប.រ.អ.ព.(IPIS) ឱ្យបានត្រឹមឆ្នាំ២០១៩ ....... 50
៦.៣.៦.គោលដៅទី៦ ៖ ធ្វើទំនើបកម្ម និងភ្ជាប់ប្រព័ន្ធលិខិតឆ្លងដែនជាមួយនឹង ប.រ.អ.ព.(IPIS) ឱ្យបានត្រឹមឆ្នាំ២០១៩ ....... 51
៦.៣.៧.គោលដៅទី៧ ៖ បង្កើតមជ្ឈមណ្ឌលទិន្នន័យទំនើប និងមានសុវត្ថិភាពសម្រាប់ ប.រ.អ.ព.(IPIS) ឱ្យបានត្រឹមឆ្នាំ២០១៧ ....... 52
៦.៤. គោលបំណងទី៤ ៖ ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឯកភាពបែងចែកទិន្នន័យពលរដ្ឋ ....... 53
៦.៤.១. គោលដៅទី១ ៖ បង្កើតប្រព័ន្ធបែងចែកទិន្នន័យ ឱ្យបានត្រឹមឆ្នាំ២០២០ ....... 53
៦.៤.២. គោលដៅទី២ ៖ បំពេញតាមសំណូមពរស្នើសុំព័ត៌មានឱ្យបានពីរលានដងក្នុងមួយឆ្នាំ ឱ្យបានត្រឹមឆ្នាំ២០២៤ ....... 55
៦.៥. គោលបំណងទី៥ ៖ កែសម្រួលរបៀបរបបការងារ និងដាក់ឱ្យដំណើរការប្រព័ន្ធអេឡិចត្រូនិកសម្រាប់ផ្តល់សេវាជូនអតិថិជនប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ....... 56
៦.៥.១. គោលដៅទី១ ៖ សម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ ឱ្យបានត្រឹមឆ្នាំ២០១៧ ....... 56
៦.៥.២. គោលដៅទី២ ៖ កែសម្រួលរបៀបរបបការងារសម្រាប់លើកកម្ពស់ការផ្តល់សេវាកម្មឱ្យបានត្រឹមឆ្នាំ២០១៧ ....... 57
៦.៥.៣. គោលដៅទី៣ ៖ ណែនាំឱ្យប្រើប្រាស់សេវាកម្មតាមប្រព័ន្ធអេឡិចត្រូនិច ឱ្យបានត្រឹមឆ្នាំ២០២១ ....... 58
VII. អភិបាលកិច្ច និងការតាមដានត្រួតពិនិត្យ ....... 60
៧.១. មុខងារ និងការទទួលខុសត្រូវ ....... 61
៧.២. អំពីអាណត្តិ ....... 62
៧.៣.អំពីរបាយការណ៍ ....... 62
៧.៤. ការតាមដានត្រួតពិនិត្យលើកការអនុវត្ត ....... 65
VIII. ក្របខ័ណ្ឌហិរញ្ញវត្ថុ ....... 67
IX. ផែនទីបង្ហាញផ្លូវសម្រាប់ផែនការយុទ្ធសាស្រ្តជាតិស្តីពីអត្តសញ្ញាណកម្ម ....... 70
X. ចរិកាប៉ាន់ស្មាន ....... 71
XI. ការតាមដានត្រួតពិនិត្យ ....... 77

# អារម្ភកថា

រាជរដ្ឋាភិបាលអាណត្តិទី៥នៃនីតិកាលរដ្ឋសភាដែលបានប្រសូត្រចេញពីការបោះឆ្នោតនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ប្រកបដោយលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ បាននិងកំពុងបន្តបេសកកម្មពីរាជរដ្ឋាភិបាលអាណត្តិមុននៅក្នុងដំណើរមួយដ៏ស្វាហាប់ ក្រោមបាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ដើម្បីបម្រើបុព្វហេតុអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងធានាផលប្រយោជន៍ដ៏ឧត្តុងឧត្តមជូនប្រទេសជាតិ។ ដោយបានកត់សម្គាល់ពីបញ្ហាប្រឈមនានាក្នុងសង្គមនាពេលកន្លងមក ប្រមុខរាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងកម្រិតខ្ពស់ថែមទៀត ដើម្បីជំរុញនូវការអនុវត្តគោលនយោបាយកំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ ក្នុងឆន្ទៈដ៏មោះមុតធ្វើឱ្យសង្គមកម្ពុជាក្លាយជាសង្គមមានការអភិវឌ្ឍ មានសន្តិភាព វិបុលភាព សុខដុមរមនា មានស្នាមញញឹម និងក្តីសង្ឃឹមនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។

រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយជាយុទ្ធសាស្ត្រចម្បងៗមួយចំនួន មានជាអាទិ៍ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៥នៃនីតិកាលរដ្ឋសភា សម្រាប់ជាត្រីវិស័យដ៏មានសក្តានុពលក្នុងការបន្តជំរុញកំណើនសេដ្ឋកិច្ច និងការងារក្នុងសង្គម។ កម្ពុជាធ្លាប់ទទួលបាននូវជោគជ័យជាច្រើនក្នុងវិស័យកំណែទម្រង់នានាដែលបានកំណត់ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនយោបាយរបស់ខ្លួននាពេលកន្លងមក។ ការផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាលទាំងឡាយរបស់ស្ថាប័នរដ្ឋនាពេលបច្ចុប្បន្ននេះ កាន់តែទទួលបាននូវការពេញចិត្តពីប្រជាពលរដ្ឋ តាមរយៈការធ្វើទំនើបកម្ម និងកែលម្អរចនាសម្ព័ន្ធប្រព័ន្ធផ្តល់សេវាកម្មទាំងអស់នោះជាបន្តបន្ទាប់។

នៅលើឆាកអន្តរជាតិវិញ កម្ពុជាកំពុងទទួលបានភាពស្មើមុខស្មើមាត់ជាមួយនឹងបណ្តាប្រទេសនានាក្នុងតំបន់ និងក្នុងសកលលោក តាមរយៈការចូលរួម និងការទទួលខុសត្រូវលើសកម្មភាពជាអន្តរជាតិជាច្រើន។ កម្ពុជាក៏បានធ្វើសច្ចាប័នទទួលស្គាល់ និងប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តតាមសិទ្ធិសញ្ញា កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិជាច្រើនដែលក្នុងនោះរួមមាន សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាស្តីពីសិទ្ធិកុមារ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ល។ លើសពីនេះទៀត កម្ពុជាក៏បានត្រៀមខ្លួនជាស្រេចក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ដែលទើបបានដាក់ចេញនាពេលថ្មីៗនេះដោយអង្គការសហប្រជាជាតិ។

នៅក្នុងតំបន់វិញ កម្ពុជាបានចូលរួមជាមួយបណ្តាប្រទេសនៅអាស៊ី និងប៉ាស៊ីហ្វិកនៅក្នុងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីស្តីពីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ដែលបានរៀបចំឡើងដោយគណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមនៅតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដោយសម្រេចបង្កើតបានសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីតំបន់អាស៊ី និងប៉ាស៊ីហ្វិកស្តីពីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន (ឆ្នាំ២០១៤)។ កម្ពុជាក៏ជាប្រទេសមួយដែលបានរួមចំណែកក្នុងការបង្កើតឡើងនូវសេចក្តីថ្លែងការទីក្រុងសេអ៊ូលស្តីពីការគ្រប់គ្រងអត្តសញ្ញាណកម្ម (ឆ្នាំ២០១៤)ផងដែរ។

ផ្អែកតាមស្មារតីខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិថ្មីមួយទៀត នោះគឺ "**ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៥-២០២៤**" សម្រាប់ជា

មគ្គុទេសន៍ក្នុងការពង្រឹងអត្តសញ្ញាណផ្លូវច្បាប់នៃប្រជាពលរដ្ឋរស់នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលជាកិច្ចខិតខំប្រឹងប្រែងមួយទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការឆ្លើយតបទៅនឹងសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីតំបន់អាស៊ី និងប៉ាស៊ីហ្វិកស្តីពីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ក៏ដូចជាសេចក្តីថ្លែងការទីក្រុងសេអ៊ូលស្តីពីការគ្រប់គ្រងអត្តសញ្ញាណកម្មផង ជាពិសេសគឺ គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ត្រង់ចំណុចដែលចែងអំពីអត្តសញ្ញាណផ្លូវច្បាប់។

ម្យ៉ាងទៀត ក្នុងនាម **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំសូមប្រកាសជាឱឡារិកជាមួយនឹងបណ្តាប្រទេសនានានៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ថា "ឆ្នាំ២០២៤ គឺជាសករាជនៃអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មនៅកម្ពុជា"។ អាស្រ័យហេតុនេះ ខ្ញុំសូមស្នើឱ្យគ្រប់ក្រសួង ស្ថាប័នជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ត្រូវជានាឱ្យមានធនធានគ្រប់គ្រាន់ និងខិតខំចូលរួមចំណែកយ៉ាងសកម្មរៀបចំកិច្ចការរបស់ខ្លួនឱ្យមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រជាតិនេះ។ ខ្ញុំក៏សូមអំពាវនាវដល់ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាទាំងអស់ សូមជួយផ្តល់ការគាំទ្រទាំងខាងបច្ចេកទេស និងធនធានសម្រាប់ជាចលករជួយជ្រោមជ្រែងរាជរដ្ឋាភិបាលកម្ពុជាឱ្យទទួលបានជោគជ័យក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ។

រាជធានីភ្នំពេញ ថ្ងៃទី........ខែ...........ឆ្នាំ.............

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

ក្រសួងមហាផ្ទៃជាស្ថាប័នជាតិដ៏សំខាន់មួយដែលបានទទួលអាណត្តិពីរាជរដ្ឋាភិបាល ក្នុងការពង្រឹងការអនុវត្តច្បាប់ រួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៥នៃនីតិកាលរដ្ឋសភា ក្នុងគោលដៅតែមួយគត់ គឺការពង្រឹងនីតិរដ្ឋ អភិបាលកិច្ចល្អ ការគោរពសិទ្ធិមនុស្ស និងសន្តិសុខសុវត្ថិភាពសាធារណៈជូនសង្គមជាតិ។ នេះជាដំណាក់កាលថ្មីមួយទៀតដែលក្រសួងមហាផ្ទៃត្រូវតែបោះជំហានទៅរកដើម្បីលើកកម្ពស់ប្រសិទ្ធភាពអភិបាលកិច្ចល្អ និងការផ្តល់សេវារដ្ឋបាលនានា។

សេវាសាធារណៈគឺជាសមាសធាតុដ៏សំខាន់មួយក្នុងការចូលរួមចំណែកបង្កើតឡើងនូវវិបុលភាពជូនប្រជាពលរដ្ឋ។ ការពង្រឹង និងការលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងការផ្តល់សេវាសាធារណៈដែលកាន់តែកៀកជិត ឆាប់រហ័ស បំបាត់នូវការិយាធិបតេយ្យ និងមានភាពកាន់តែងាយស្រួល គឺបានកំណត់ឡើងយ៉ាងច្បាស់លាស់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងបុព្វហេតុធ្វើកំណែទម្រង់វិស័យសេវាសាធារណៈនេះ ក្រសួងមហាផ្ទៃ ដោយមានការឯកភាពពីរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងសេវាសាធារណៈរបស់ក្រសួងមហាផ្ទៃ ដែលពីមុនមកបាននៅរាយប៉ាយឱ្យមកស្ថិតនៅក្រោមការគ្រប់គ្រងដោយស្ថាប័នមួយជាក់លាក់។

បេសកកម្មរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ប្រាកដជាជួបប្រទះនូវការលំបាក និងបញ្ហាប្រឈមនានាជាច្រើននៅពេលខាងមុខនេះ។ គោលបំណងជាយុទ្ធសាស្ត្ររបស់ក្រសួងមហាផ្ទៃគឺការពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីបង្កើនអត្រាចុះបញ្ជីអត្រានុកូលដ្ឋាន និងលើកកម្ពស់ការងារអត្តសញ្ញាណកម្ម ឱ្យស្របតាមការប្តេជ្ញាចិត្តរបស់ខ្លួននៅក្នុងសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីតំបន់អាស៊ី និងប៉ាស៊ីហ្វិកស្តីពីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន (ឆ្នាំ២០១៤) សេចក្តីថ្លែងការទីក្រុងសេអ៊ូលស្តីពីការគ្រប់គ្រងអត្តសញ្ញាណកម្ម (ឆ្នាំ២០១៤) និងអនុសញ្ញា សិទ្ធិសញ្ញាអន្តរជាតិនានាដែលកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ។ នេះគឺជាកិច្ចខិតខំប្រឹងប្រែងថ្មីមួយទៀតក្នុងការរៀបចំឱ្យឡើងវិញនូវប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបុគ្គល តាមរយៈប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឈានទៅបង្កើតលេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់មនុស្សគ្រប់រូប និងបង្កើតមជ្ឈមណ្ឌលជាតិគ្រប់គ្រងទិន្នន័យអត្តសញ្ញាណកម្ម សម្រាប់ភ្ជាប់ប្រព័ន្ធនេះជាមួយនឹងវិស័យពាក់ព័ន្ធទាំងអស់ ដើម្បីជួយឱ្យរាជរដ្ឋាភិបាលងាយស្រួលក្នុងការពង្រឹងការអនុវត្តច្បាប់ សិទ្ធិ សេរីភាព លុបបំបាត់ចោលរាល់ទម្រង់រើសអើងនានា លើកកម្ពស់ការផ្តល់សេវាសាធារណៈ ការគោរពសិទ្ធិមនុស្ស សិទ្ធិនយោបាយ ប្រយុទ្ធប្រឆាំងនូវរាល់ទម្រង់នៃការកេងប្រវ័ញ្ច ពលកម្មកុមារ ធានាការទទួលបានសេវាមូលដ្ឋាននានា ដូចជា សេវាសុខាភិបាល អប់រំ ព្រមទាំងជួយសម្រួល និងគាំពារដល់វិស័យឯកជនឱ្យទទួលបានព័ត៌មានប្រកបដោយភាពជឿទុកចិត្តអំពីអត្តសញ្ញាណបុគ្គល។

កិច្ចការទាំងអម្បាលមានខាងលើនេះ ពិតជាមិនអាចសម្រេចបានក្នុងពេលមួយយប់នោះទេ។ ក្រសួងមហាផ្ទៃតែឯកឯង ក៏មិនអាចសម្រេចមហិច្ឆតានេះជូនជាតិមាតុភូមិបាន ប្រសិនបើគ្មានការជួយគាំទ្រពីវិស័យពាក់ព័ន្ធ និងផ្នែកឯកជនឡើយ។ ដោយប្តេជ្ញាថានឹងសម្រេចឱ្យបាននូវបុព្វហេតុដ៏មានមហិច្ឆតាខាងលើនេះ ក្រសួងមហាផ្ទៃ ដោយមានអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មជាសេនាធិការ បានបង្កើតឡើងនូវ "**ផែនការយុទ្ធសាស្ត្រជាតិ**

**ស្តីពីអត្តសញ្ញាណកម្ម ២០១៥-២០២៤**" សម្រាប់ជាមគ្គុទេសន៍រយៈពេលវែងរបស់រាជរដ្ឋាភិបាលក្នុងការបង្ហាញអំពីគម្រោយផ្លូវ និងតម្រូវការធនធានចាំបាច់ដែលអាចឈានទៅបង្កើតប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណបុគ្គលដោយប្រើប្រាស់បច្ចេកវិទ្យាទំនើបនៅកម្ពុជា។ ក្នុងនាមថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ក៏ដូចក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសំដែងនូវការកោតសរសើរយ៉ាងខ្លាំងចំពោះស្មារតីយកចិត្តទុកដាក់ និងការទទួលខុសត្រូវខ្ពស់របស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដែលបានពូតផ្តុំបញ្ញាញាណរបស់ខ្លួន បូករួមទាំងមតិយោបល់ពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលនានា ក្នុងការបង្កើតផែនការយុទ្ធសាស្ត្រនេះ។ ខ្ញុំពិនិត្យឃើញថា ផែនការយុទ្ធសាស្ត្រនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ មានស្តង់ដាជាអន្តរជាតិ និងឆ្លើយតបបានទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះការតព្វកិច្ចជាសកលនានា ជាពិសេស ចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពដែលទើបបានបង្កើតឡើងនាពេលថ្មីៗនេះ។

ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី ដែលបានផ្តល់ជំនួយគាំទ្រដល់ក្រសួងមហាផ្ទៃ តាមរយៈអង្គការយូនីសេហ្វ ដើម្បីឱ្យក្រសួងទទួលបានជំនួយបច្ចេកទេសកម្រិតអន្តរជាតិសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រប្រកបដោយវិជ្ជាជីវៈខ្ពស់។

ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃក៏សូមសំដែងនូវអំណរគុណចំពោះរាជរដ្ឋាភិបាលដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតី ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការអនុម័តទទួលយកផែនការនេះជាផែនការយុទ្ធសាស្ត្រជាតិ និងសម្រេចដាក់ឱ្យប្រើប្រាស់ចាប់ពីពេលនេះតទៅ។ ក្នុងនាមថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ខ្ញុំសូមប្តេជ្ញាចិត្តដឹកនាំអនុវត្ត "ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៥-២០២៤" នេះឱ្យមានប្រសិទ្ធភាពខ្ពស់ដើម្បីបម្រើឧត្តមប្រយោជន៍ជាតិមាតុភូមិរបស់យើង។

រាជធានីភ្នំពេញ ថ្ងៃទី........ខែ...........ឆ្នាំ.............

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

# I. សេចក្តីផ្តើម

រាជរដ្ឋាភិបាលបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍សាមគ្គីភាពជាតិមួយដើម្បីឱ្យប្រជាជនកម្ពុជាទាំងអស់ ទាំងក្នុងនិងក្រៅប្រទេស និងប្រជាជនមកពីគ្រប់ស្រទាប់វណ្ណៈ និងនិន្នាការនយោបាយនានា រួមគ្នាក្រោមបាវចនា "ជាតិ សាសនា ព្រះមហាក្សត្រ" ក្នុងគោលបំណងកសាងនិងការពារជាតិ និងសមិទ្ធិផលសង្គមទាំងឡាយ នៅក្នុងខណៈពេលដែលកំពុងតែខិតខំធានាឱ្យបាននូវឯករាជ្យភាព បូរណភាព អធិបតេយ្យភាព សន្តិភាព ប្រជាធិបតេយ្យ និងការរីកចម្រើនរបស់ប្រទេស។ នៅក្នុងទសវត្សចុងក្រោយនេះ ប្រទេសកម្ពុជាកំពុងទទួលបានអត្រាកំណើនសេដ្ឋកិច្ច និងអត្រាកាត់បន្ថយភាពក្រីក្រខ្ពស់ ហើយក៏បានរួមចំណែកយ៉ាងសំខាន់ដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងសកលលោក។ ស្ថិរភាពនយោបាយ ដែលមិនធ្លាប់កើតមានអស់រយៈពេលជាច្រើនឆ្នាំ បានបង្កបរិយាកាសអំណោយផលដល់ប្រទេសកម្ពុជាក្នុងការអនុវត្តវិធានការកំណែទម្រង់របស់ខ្លួនលើគ្រប់វិស័យ ក្នុងគោលបំណងកសាងសមត្ថភាពស្ថាប័ន កែលម្អហេដ្ឋារចនាសម្ព័ន្ធ សង្គម សេដ្ឋកិច្ច និងបង្កើតបរិយាកាសល្អដើម្បីទាក់ទាញការវិនិយោគទាំងក្នុង និងក្រៅស្រុក ក្នុងគោលបំណងធានាឱ្យមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ និងកាត់បន្ថយភាពក្រីក្រខ្ពស់ (ផ.យ.អ.ជ. ២០១៤-២០១៨)។

រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍សហសវត្សប្រកបដោយនិរន្តរភាព។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបានបន្តស្វែងរកកំណើនសេដ្ឋកិច្ចដែលមានលក្ខណៈប្រមូលផ្តុំ តាមរយៈការរៀបចំផែនការអភិវឌ្ឍន៍នានានៅក្នុងក្របខ័ណ្ឌទីផ្សារ។ វិធីសាស្ត្រនេះក៏បានគូសបញ្ជាក់ជាថ្មីនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលជាទិសដៅគោលនយោបាយសម្រាប់ការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលក្នុងរយៈពេលពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៨។ រាជរដ្ឋាភិបាលកម្ពុជាក៏កំពុងព្យាយាមធ្វើសមាហរណកម្មប្រទេសចូលទៅក្នុងសហគមន៍អាស៊ានឱ្យបានពេញលេញ ដើម្បីទទួលបានអត្ថប្រយោជន៍ពីការធ្វើសមាហរណកម្មនេះផងដែរ។ ជាចុងក្រោយ ការធ្វើឱ្យប្រទេសចាកចេញពីឋានៈជាប្រទេសដែលមានការអភិវឌ្ឍតិចតួច គឺជាអាទិភាពមួយដែលយើងកំពុងឆ្ពោះទៅរក។

ការអភិវឌ្ឍប្រកបដោយភាពជោគជ័យក្នុងរយៈពេលច្រើនឆ្នាំចុងក្រោយនេះ និងផែនការអនាគតដែលពោរពេញដោយមហិច្ឆតាទាំងឡាយ បានគូសបញ្ជាក់អំពីតម្រូវការក្នុងការបន្តឱ្យមានការចាប់ផ្តើមការងារកំណែទម្រង់ជាច្រើន ដើម្បីសម្រេចឱ្យបាននូវលទ្ធផលនៃការអភិវឌ្ឍដែលកាន់តែមានសមធម៌ និងកាន់តែផ្តោតទៅរកប្រជាពលរដ្ឋ។ ដើម្បីសម្រេចបាននូវមហិច្ឆតាទាំងនេះ កំណែទម្រង់ក្នុងវិស័យជាច្រើនត្រូវតែបន្តធ្វើ ហើយកំណែទម្រង់ថ្មីៗទៀតក៏ត្រូវតែចាប់ផ្តើមដែរ។ ការងារថ្មីមួយនៃកំណែទម្រង់នានាទាំងនោះ គឺការកសាងប្រព័ន្ធអត្តសញ្ញាណកម្មទំនើបមួយក្នុងប្រទេសកម្ពុជា ដែលនឹងធានាថាប្រទេសកម្ពុជានឹងទទួលបានផលប្រយោជន៍ពីព័ត៌មានប្រជាពលរដ្ឋ និងស្ថិតិអត្រានុកូលដ្ឋាន ហើយនិងប្រើប្រាស់ព័ត៌មាននោះក្នុងគោលបំណងរៀបចំផែនការយុទ្ធសាស្ត្រនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ ជាពិសេសឆ្លើយតបដល់ជនដែលត្រូវការបំផុត។ ប្រព័ន្ធអត្តសញ្ញាណកម្មក៏នឹងជួយលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃកម្មវិធីនានា និងការប្រើប្រាស់ធនធាន ជួយគាំទ្រការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុថ្នាក់តំបន់ ព្រមទាំងជួយផ្តល់នូវស្ថិតិដែលអាចទុកចិត្តបានដល់ប្រទេសជាដៃគូរបស់កម្ពុជា និងសហគមន៍អន្តរជាតិ។ កំណែទម្រង់អត្តសញ្ញាណកម្មក៏នឹងជំរុញសន្ទុះសម្រាប់ការអភិវឌ្ឍប្រកបដោយវិជ្ជមានក្នុងគ្រប់វិស័យទាំងអស់របស់រាជរដ្ឋាភិបាល ក៏ដូចជាវិស័យឯកជនផងដែរ។

ផែនការយុទ្ធសាស្ត្រជាតិនេះមានគោលបំណងសម្រេចចក្ខុវិស័យរយៈពេលវែងសម្រាប់ប្រទេសកម្ពុជា ដែលនោះគឺមនុស្សគ្រប់រូបត្រូវមានអត្តសញ្ញាណមួយ។ ការងារនេះនឹងទាមទារឱ្យមានការកសាងនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានទំនើប អចិន្ត្រៃយ៍ និងមានលក្ខណៈជាសកល ដែលនឹងបង្កើតនូវស្ថិតិអត្រានុកូលដ្ឋានដែលអាចជឿទុកចិត្តបាន និងប្រព័ន្ធរួមអត្តសញ្ញាណកម្មប្រជាពលរដ្ឋ (ប.រ.អ.ព.) ដែលនឹងធានាថា ប្រទេសកម្ពុជានឹងមានប្រភព ដែលអាចជឿទុកចិត្តបានតែមួយគត់អំពីព័ត៌មានស្តីពីបុគ្គល និងប្រជាពលរដ្ឋ។ ការកសាងប្រព័ន្ធទាំងអស់នេះនឹងជម្រុះចោលនូវភាពចាំបាច់នៃការអភិវឌ្ឍនូវប្រព័ន្ធស្រដៀងៗគ្នាផ្សេងៗទៀតសម្រាប់អត្តសញ្ញាណកម្មប្រជាពលរដ្ឋ ដែលអាចជួយធានាឱ្យមានការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព។ ផែនការយុទ្ធសាស្ត្រជាតិនេះបានប្រមើលមើលឃើញថា បុគ្គលម្នាក់ៗនឹងត្រូវផ្តល់ឱ្យនូវលេខកូដអត្តសញ្ញាណខ្មែរ (Khmer Identification Code - KIDC) ផ្ទាល់ខ្លួនមួយនៅពេលដែលពួកគេចុះបញ្ជីកំណើត ហើយនឹងបន្តប្រើប្រាស់លេខកូដនេះពេញមួយជីវិតរបស់ពួកគេ ហើយវាក៏នឹងក្លាយទៅជាការដែលអាចកំណត់អត្តសញ្ញាណជាពិសេសមួយតាមរយៈលេខកូដនេះ នៅពេលដែលពួកគេទៅទទួលសេវាកម្មពីវិស័យសាធារណៈ ឬវិស័យឯកជននានា។ ការអនុវត្តផែនការនេះនឹងធានាថាបុគ្គលម្នាក់មានអត្តសញ្ញាណតែមួយពេញមួយជីវិត។

ប្រព័ន្ធអត្តសញ្ញាណកម្មជាតិដែលមានលក្ខណៈទូលំទូលាយ ដែលនឹងត្រូវបានបង្កើតក្នុងអំឡុងពេលអនុវត្តកម្មវិធីនេះ នឹងដើរតួជាបុរេល័ក្ខខ័ណ្ឌមួយក្នុងការការពាររាល់បុគ្គលទាំងអស់ និងគាំទ្រពួកគេឱ្យទទួលបានសិទ្ធិពលរដ្ឋ សិទ្ធិផ្លូវច្បាប់ សិទ្ធិសង្គម និងសិទ្ធិនយោបាយ ក៏ដូចជាទទួលបាននូវសេវាកម្មទាំងឡាយណាដែលពួកគេមានសិទ្ធិទទួល។ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មដែលមានមុខងារដំណើរការល្អ នឹងជួយជំរុញ និងរួមចំណែកជាវិជ្ជមានដល់អភិបាលកិច្ចល្អ និងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព ព្រមទាំងពង្រឹងរដ្ឋបាលសាធារណៈ ជានាការចូលរួមក្នុងការបោះឆ្នោត ជួយសម្រួលដល់ការផ្តល់សេវាសាធារណៈ និងរួមចំណែកដល់ស្ថេរភាព និងសន្តិសុខរបស់ប្រទេសទាំងមូលទៀតផង។ ការប្រើប្រាស់សិទ្ធិមនុស្សជាច្រើន ត្រូវតែអាស្រ័យដោយផ្ទាល់ទៅលើវត្តមានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដែលមានដំណើរការល្អ។ ប្រព័ន្ធនេះនឹងជួយលើកកម្ពស់សមភាពយេនឌ័រ ទប់ស្កាត់ និងកាត់បន្ថយហានិភ័យនៃភាពគ្មានរដ្ឋ ការជួញដូរមនុស្ស ការរៀបអាពាហ៍ពិពាហ៍កុមារ និងការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង ពលកម្មកុមារ និងហានិភ័យផ្សេងៗទៀត។

ការកំណត់អត្តសញ្ញាណបុគ្គលត្រូវបានបង្កើតឡើងតាមរយៈអត្តសញ្ញាណផ្លូវច្បាប់មួយដែលសំបុត្រកំណើតបានផ្តល់ឱ្យ ហើយនឹងត្រូវយកមកប្រើប្រាស់ដោយបន្ថែមនូវទិន្នន័យជីវសាស្ត្រមួយចំនួនទៀត តាមរយៈការចេញឯកសារអត្តសញ្ញាណ ដូចជាអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងឯកសារផ្សេងៗទៀតទៅតាមការចាំបាច់។ អត្តសញ្ញាណផ្លូវច្បាប់គឺជាភស្តុតាងដែលថា រដ្ឋមួយទទួលស្គាល់ និងគោរពជីវិតរបស់បុគ្គលទាំងអស់ ហើយដែលរដ្ឋនោះមានការទទួលខុសត្រូវក្នុងការការពារ និងការអភិវឌ្ឍ។

ការចុះបញ្ជីអត្រានុកូលដ្ឋានត្រូវបានកំណត់ដោយអង្គការសហប្រជាជាតិថា ជាការកត់ត្រានូវព្រឹត្តិការណ៍រស់នៅ ដោយមានលក្ខណៈជាសកល ជាបន្តបន្ទាប់ ជាអចិន្ត្រៃយ៍ និងដោយខានមិនបាន ដែលត្រូវធ្វើឡើងតាមរយៈអនុក្រឹត្យ ឬបទប្បញ្ញត្តិផ្សេងៗស្របតាមតម្រូវការផ្នែកច្បាប់របស់ប្រទេសនីមួយៗ។ នេះគឺជាការកត់ត្រា និងការចងក្រងឯកសារព្រឹត្តិការណ៍ជីវិតក្នុងជីវិតរបស់មនុស្ស (រួមមាន កំណើត អាពាហ៍ពិពាហ៍ ការលែងលះ ការសុំកូន និងមរណភាព) ហើយក៏គឺជាមុខងារជាមូលដ្ឋានដ៏សំខាន់មួយរបស់រដ្ឋាភិបាលផងដែរ។

ការចុះបញ្ជីអត្រានុកូលដ្ឋានមានគោលដៅសំខាន់ៗចំនួនពីរគឺ ៖

- ផ្តល់ការបញ្ជាក់ផ្លូវច្បាប់សម្រាប់បុគ្គលអំពីព្រឹត្តិការណ៍រស់នៅរបស់ពួកគេ ដែលជាការគាំទ្រក្នុងការបង្កើតអត្តសញ្ញាណខាងផ្លូវច្បាប់ ការបង្កើតឯកសារអត្តសញ្ញាណជាតិ និងភាពត្រឹមត្រូវនៃទិន្នន័យប្រជាពលរដ្ឋ ព្រមទាំងការបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោត។
- បង្កើតបានជាប្រភពទិន្នន័យដែលគេចង់បានសម្រាប់ប្រើប្រាស់ក្នុងការវិភាគទាំងឡាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការធ្វើរបាយការណ៍អំពីស្ថិតិអត្រានុកូលដ្ឋាន និងរបាយការណ៍អំពីប្រជាពលរដ្ឋ។

កំណត់ត្រាចុះបញ្ជីអត្រានុកូលដ្ឋានរបស់ប្រទេសកម្ពុជា បានត្រូវបំផ្លាញទាំងស្រុងនៅក្នុងរបបខ្មែរក្រហម ហើយប្រព័ន្ធចុះបញ្ជីនេះក៏ទើបនឹងបានរៀបចំឡើងវិញក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។ យុទ្ធនាការរបស់រដ្ឋាភិបាលក្រោមកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍នានា បានសម្រេចជោគជ័យក្នុងការចុះបញ្ជីប្រជាពលរដ្ឋរាប់លាននាក់។ នេះជាជោគជ័យដ៏ធំមួយនៅក្នុងចំណោមប្រទេសដែលទើបងើបផុតពីសង្គ្រាមដូចគ្នា។ ភាគរយនៃការចុះបញ្ជីកុមារអាយុក្រោម៥ឆ្នាំ បានកើនឡើងយ៉ាងគំហុកពី២២%ក្នុងឆ្នាំ២០០០ មក៦០%ក្នុងឆ្នាំ២០០៦ និងបានកើនដល់៧៣%ក្នុងឆ្នាំ២០១៤។ កិច្ចខិតខំប្រឹងប្រែងជាបន្តបន្ទាប់ត្រូវបានធ្វើឡើងដើម្បីកែលម្អប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មបុគ្គល ហើយការរីកចម្រើនគួរឱ្យកត់សម្គាល់នេះ ត្រូវបានគេសង្កេតឃើញថាមានការកើនឡើងជាលំដាប់។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ បានជំរុញឱ្យមានការរៀបចំបង្កើតផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៥-២០២៤ (ផ.យ.ជ.អ. ២០១៥-២០២៤) តាមរបៀបមួយដែលប្រទេសនានានៅក្នុងពេលបច្ចុប្បន្ននេះ អាចចាប់យកជំហានបន្តបន្ទាប់មួយឆ្ពោះទៅសម្រេចបង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មដែលនឹងចាប់ផ្តើមបំពេញនូវចន្លោះខ្វះខាតដែលកំពុងតែមាននៅក្នុងពេលបច្ចុប្បន្ន និងធ្វើដំណើរឆ្ពោះទៅរកប្រព័ន្ធនៃការចុះបញ្ជី និងអត្តសញ្ញាណកម្មមួយដែលមានលក្ខណៈជាសកល។

ក៏នៅមានបញ្ហាប្រឈមមួយចំនួនសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្រថ្នាក់ជាតិនេះ ហើយបញ្ហាប្រឈមទាំងអស់នេះភាគច្រើនគឺជាប់ជំពាក់ទៅនឹងការយល់ដឹងតិចតួចនៅក្នុងសង្គមទាំងមូលអំពីសារៈសំខាន់ និងអំពីប្រព័ន្ធនៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម សមត្ថភាពនៅទន់ខ្សោយជាពិសេសនៅថ្នាក់មូលដ្ឋានកម្រិតមធ្យមទាក់ទងជាមួយនឹងចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មាន និងការភ្ជាប់ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតនៅតំបន់ដាច់ស្រយាលមួយចំនួន ការខ្វះខាតដំណើរការ និងនីតិវិធីច្បាស់លាស់ ព្រមទាំងរចនាសម្ព័ន្ធអភិបាលកិច្ចសម្រាប់ការងារអត្តសញ្ញាណកម្ម រួមទាំងការផ្តល់ហិរញ្ញប្បទាននៅមានកម្រិតសម្រាប់វិស័យសំខាន់ៗនៃអត្តសញ្ញាណកម្ម។ បញ្ហាប្រឈមទាំងនេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុង ផ.យ.ជ.អ. ២០១៥-២០២៤ ហើយនឹងត្រូវការពិចារណាឱ្យបានពេញលេញនៅពេលដែលរៀបចំបង្កើតផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ។

សរុបមក ផ.យ.ជ.អ. ២០១៥-២០២៤ មានគោលបំណងកសាងនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មមួយដែលមានភាពទំនើប មានមុខងារល្អ និងមានការឆ្លើយតប ដោយអនុលោមតាមស្តង់ដាជាអន្តរជាតិ និងធានាថា បុគ្គលគ្រប់រូបរស់នៅក្នុងប្រទេសកម្ពុជានឹងមានអត្តសញ្ញាណស្របច្បាប់ បុគ្គលគ្រប់រូបត្រូវបានផ្តល់ឱ្យនូវឯកសារផ្លូវច្បាប់ស្របតាមការចុះបញ្ជីអត្រានុកូលដ្ឋាន ហើយស្ថិតិអត្រានុកូលដ្ឋានបានត្រូវផលិតឡើងត្រឹមត្រូវ ទាន់ពេលវេលា និងអាចចែករំលែកបាន។ ដើម្បីធានានូវអធិបតេយ្យភាពនៃប្រព័ន្ធអត្តសញ្ញាណកម្ម

ប្រជាពលរដ្ឋ ផ.យ.ជ.អ. ២០១៥-២០២៤ បានពង្រីកខ្លួនលើសពីត្រឹមតែបង្កើតនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែលមានមុខងារល្អតាមរយៈការអនុវត្តនូវវិធីសាស្ត្រទូលំទូលាយ រហូតដល់មានគោលបំណងនៅក្នុងការធ្វើទំនើបកម្មប្រព័ន្ធទាំងមូលទៀតផង ដែលពេលបច្ចុប្បន្នប្រព័ន្ធនេះបានចូលរួមចំណែកជានាដល់ការចេញឯកសារបញ្ជាក់អំពីអត្តសញ្ញាណបុគ្គល ក្នុងគោលដៅដើម្បីធ្វើឱ្យវាក្លាយទៅជាប្រភពតែមួយគត់នៃព័ត៌មានដែលគួរឱ្យទុកចិត្តអំពីបុគ្គល និងប្រជាពលរដ្ឋ។ វិធីសាស្ត្រដែលផ្តោតទៅលើសេវាកម្មនេះត្រូវការរៀបចំឡើងឱ្យបានមត់ចត់នៅពេលផ្តល់សេវាសាធារណៈជូនទៅប្រជាពលរដ្ឋ។ ការយល់ដឹងអំពីសារៈសំខាន់ និងតម្រូវការនៃការចុះបញ្ជី និងអត្តសញ្ញាណកម្ម គួរតែបានការលើកកម្ពស់ជាបន្តបន្ទាប់នៅក្នុងអំឡុងពេលនៃការអនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ នេះ។

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មដែលមានមុខងារល្អ ទាមទារឱ្យមានការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការក្នុងចំណោមវិស័យសាធារណៈជាច្រើន និងកម្រិតរដ្ឋបាលផ្សេងៗគ្នាចាប់ពីថ្នាក់កណ្តាល រហូតដល់ថ្នាក់មូលដ្ឋាន ជាមួយដៃគូអភិវឌ្ឍន៍ វិស័យឯកជន សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងប្រជាពលរដ្ឋទាំងមូលផងដែរ។ ដូច្នេះ ការសហការ និងការចូលរួមយ៉ាងសកម្មពីគ្រប់វិស័យទាំងអស់នៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះគឺមានសារៈសំខាន់ខ្លាំងជាទីបំផុត។

ផ.យ.ជ.អ. ២០១៥-២០២៤ គឺជាផែនការដ៏ស្មុគស្មាញ និងប្រកបដោយមហិច្ឆិតា។ ផែនការនេះនឹងអនុវត្តក្នុងរយៈពេល១០ឆ្នាំ ក្នុងការខិតខំបង្កើតមុខងារថ្មីៗ កែលម្អទៅលើមុខងារផ្សេងៗមួយចំនួនទៀត និងរៀបចំបង្កើត និងប្រើប្រាស់ដំណោះស្រាយដែលពឹងផ្អែកទៅលើប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ ក្រៅអំពីការបង្កើតដោយផ្ទាល់ និងការរួមចំណែកដោយផ្ទាល់ទៅលើមុខងារទាំងឡាយ ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះនឹងមានផលប៉ះពាល់យ៉ាងសំខាន់ទៅលើកម្រិតផ្សេងៗគ្នាជាច្រើននៃកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ថាប័នដែលកន្លងមកមិនធ្លាប់មានចំណងផ្លូវការជាមួយគ្នា។ ដូច្នេះ អភិបាលកិច្ច និងក្របខ័ណ្ឌតាមដានត្រួតពិនិត្យដ៏រឹងមាំមួយ ត្រូវតែបង្កើតឡើងដើម្បីធានាឱ្យការអភិវឌ្ឍនេះមានភាពកាន់តែរឹងមាំ។

ក្របខ័ណ្ឌហិរញ្ញវត្ថុត្រូវតែមានការកំណត់ឱ្យច្បាស់លាស់ និងរក្សាឱ្យបាននូវកម្រិតធនធានសមស្របក្នុងគោលបំណងដើម្បីធានានិរន្តរភាពនៃប្រព័ន្ធអត្តសញ្ញាណកម្មនៅក្នុងប្រទេសកម្ពុជា។ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល រួមជាមួយនិងការគាំទ្រពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយនានា នឹងអនុញ្ញាតឱ្យមានការកែលម្អយ៉ាងសំខាន់ដល់ប្រព័ន្ធបច្ចុប្បន្ន និងបង្កើតឱ្យមាននូវប្រព័ន្ធរួមមួយ។ នេះគឺជាប្រការសំខាន់ណាស់ក្នុងការធានាថា ផែនការយុទ្ធសាស្ត្រជាតិនេះបានក្លាយទៅជាចំណែកមួយនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រតាមវិស័យពាក់ព័ន្ធផ្សេងៗទៀត ដើម្បីធានាឱ្យមានការអនុវត្តប្រកបដោយជោគជ័យ។

ផែនការយុទ្ធសាស្ត្រជាតិនេះត្រូវបានរចនាឡើងតាមរបៀបមួយដើម្បីឈានទៅដល់ការកែលម្អមួយដែលអាចមើលឃើញច្បាស់ចាប់តាំងពីដំណាក់កាលដំបូងទៅ ជាជាងការដែលមើលឃើញនៅដំណាក់កាលចុងក្រោយនៃកម្មវិធី។ ការរចនានេះជួយធានាឱ្យមាននិរន្តរភាពទៅដល់ចលករដែលមានភាពចំបាច់សម្រាប់អនុវត្តរយៈពេលវែង ការប្រមូលផ្តុំ ការគាំទ្រ ភាគីពាក់ព័ន្ធ និងការបង្ហាញអំពីតម្លៃនៃគម្រោងនេះ តាំងតែពីដំណាក់កាលដំបូងទៅ។ ផែនការសកម្មភាពនឹងត្រូវរៀបចំបង្កើតឡើងសម្រាប់គោលបំណងយុទ្ធសាស្ត្រនីមួយៗក្នុងការអនុវត្ត។

ការអនុវត្តផែនការដ៏មានមហិច្ឆិតានេះ បើកឱ្យមានលទ្ធភាពមួយសម្រាប់ប្រទេសកម្ពុជាធ្វើឱ្យខ្លួនមានភាពរឹងមាំសម្រាប់ជាឧទាហរណ៍មួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍នានា ដោយសារប្រទេសកម្ពុជានឹងមាន

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មមួយដែលគួរឱ្យទុកចិត្តបាន និងមានដំណើរការល្អតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងដំណោះស្រាយដែលប្រកបដោយភាពច្នៃប្រឌិត។ ការអនុវត្តកម្មវិធីតាមរយៈការបង្កើតស្តង់ដាផ្តល់សេវាកម្មសាធារណៈ ការផ្តល់ទិន្នន័យដែលគួរឱ្យទុកចិត្តបានសម្រាប់វិស័យផ្សេងៗទៀតនៅក្នុងការធ្វើផែនការ និងលទ្ធភាពសម្រាប់ការបង្កើតនូវដំណោះស្រាយរួមមួយក្នុងចំណោមប្រព័ន្ធនៃវិស័យផ្សេងៗនេះ អាចរួមចំណែកជាវិជ្ជមានទៅដល់ការពន្លឿនការរីកចម្រើនរបស់ប្រទេស ឆ្ពោះទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដែលផ្តោតទៅលើប្រជាពលរដ្ឋ។

## II. អក្សរកាត់

| | |
|---|---|
| ប.រ.អ.ព. | ប្រព័ន្ធរួមអត្តសញ្ញាណកម្មពលរដ្ឋ ( Intergrated Population Information System - IPIS ) |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ( National Strategic Deveopment Plan 2014-2018 ) |
| ផ.យ.ជ.អ. | ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ២០១៥-២០២៤ ( National Strategic Plan for Identification - NSPI 2015-2024 ) |
| ប.ច.អ.ស. | ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ( Civil Registration and Vital Statistic - CRVS ) |
| គ.ជ.ដ.អ | គណៈកម្មាធិការជាតិដឹកនាំតម្រង់ទិសការងារអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកលដ្ឋាន និងអត្តសញ្ញាណកម្ម ( National Steering Committee on CRVS and Identification - NSCI ) |
| ក.ប.អ.ក. | ក្រុមការងារបច្ចេកទេសអន្តរក្រសួងថ្នាក់ជាតិសម្រាប់អនុវត្តកម្មវិធី ( National Technical Program Implementation Team - TPIT ) |
| ប.វ.គ.ព. | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ( Information and Communication Technology - ICT ) |
| ល.ក.អ.ខ. | លេខកូដអត្តសញ្ញាណខ្មែរ ( Khmer Identification Code - KIDC ) |

## III. បរិបទយុទ្ធសាស្ត្រ

របៀបវារៈអភិវឌ្ឍន៍ជាសកល បានលេចឡើងតាមរយៈគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពថ្មីមួយដែលជាបណ្តុំនៃគោលបំណងជាសកល គោលដៅ និងសូចនាករនានា ដែលរដ្ឋជាសមាជិកនៃអង្គការសហប្រជាជាតិរំពឹងថា នឹងប្រើប្រាស់វានៅក្នុងការកំណត់នូវរបៀបវារៈ និងគោលនយោបាយរបស់ខ្លួនសម្រាប់រយៈពេល១៥ឆ្នាំទៅមុខទៀត។ គោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពបានបង្កើតនូវចំណាប់អារម្មណ៍សារជាថ្មី ទៅលើគុណភាព និងភាពអាចរកបាននៃស្ថិតិទាំងឡាយសម្រាប់បម្រើឱ្យការងារគ្រប់គ្រង ការរៀបចំកម្មវិធី និងការងារតាមដានត្រួតពិនិត្យ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ស្ថិតិចាំបាច់ភាគច្រើនបំផុតត្រូវបានផលិតឡើងពីប្រព័ន្ធស្ថិតិជាតិ ហើយទិន្នន័យទាំងនោះ គឺជាសមាសធាតុដ៏មានសារៈសំខាន់បំផុតសម្រាប់អភិបាលកិច្ចល្អ។ ប្រសិនបើគ្មានព័ត៌មានអំពីកន្លែងប្រជាពលរដ្ឋរស់នៅ ចំណូលដែលគេអាចរកបាន និងសេវាកម្មដែលគេអាចទទួលបានទេនោះ រាជរដ្ឋាភិបាលពិតជាមិនអាចឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋបានឡើយ។ ដូច្នេះកំណើននៃតម្រូវការក្នុងការកែលម្អគុណភាពស្ថិតិទាំងនោះ នឹងទាមទារឱ្យមានការសម្រេចចិត្តនិងដំណោះស្រាយជាច្រើនទាក់ទងនឹងសមត្ថភាពផ្នែកស្ថិតិជាតិ។

ជាងនេះទៀត ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដែលមានលក្ខណៈជាសកល និងមានការឆ្លើយតប នឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្រេចឱ្យបាននូវការអភិវឌ្ឍដែលមានលក្ខណៈប្រមូលផ្តុំ មានសមធម៌ និងឆ្លើយតបបានទៅនឹងតម្រូវការប្រជាពលរដ្ឋ។ បើពិនិត្យមើលមួយភ្លែតឃើញថា ដំណាក់កាលនៃការផ្តល់កំណត់ត្រាអត្រានុកូលដ្ឋាននេះហាក់ដូចជាសាមញ្ញណាស់ ប៉ុន្តែការពិតទៅ នេះគឺជាការលើកកម្ពស់ការការពារ និងការគ្របដណ្តប់ផ្នែកសង្គម តាមរយៈការសម្របសម្រួលឱ្យទទួលបាននូវសេវាសំខាន់ៗដូចជា ការអប់រំ ការថែទាំសុខភាព និងសេវាផ្សេងៗទៀត ព្រមទាំងផ្តល់នូវលទ្ធភាពនៅក្នុងការកែលម្អជីវិតរស់នៅប្រកបដោយនិរន្តរភាព ជាពិសេសសម្រាប់ប្រជាជនដែលរស់នៅក្នុងភាពក្រីក្រ។ កម្មវិធីអត្តសញ្ញាណកម្មជាតិដែលមានលក្ខណៈទូលំទូលាយ ដើរតួជាបុរេល័ក្ខខ័ណ្ឌមួយក្នុងការការពារបុគ្គល សិទ្ធិពលរដ្ឋ សិទ្ធិផ្នែកច្បាប់ សិទ្ធិសង្គម និងសិទ្ធិនយោបាយដល់ជនគ្រប់រូប ក៏ដូចជាធានាឱ្យជនគ្រប់រូបទទួលបាននូវសេវាកម្មទាំងឡាយដែលពួកគេត្រូវទទួលបានតាមផ្លូវច្បាប់។ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មដែលមានដំណើរការល្អ អាចជួយជំរុញ និងរួមចំណែកជាវិជ្ជមានដល់អភិបាលកិច្ចល្អ និងប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធនេះក៏ជួយពង្រឹងរដ្ឋបាលសាធារណៈ ធានាឱ្យមានកា ចូលរួមការបោះឆ្នោត សម្រួលដល់ការផ្តល់សេវាសាធារណៈ និងរួមចំណែកដល់សន្តិសុខ និងសុវត្ថិភាពរបស់ប្រទេសទាំងមូល។ ការអនុវត្តសិទ្ធិមនុស្សជាច្រើនទៀត ក៏ត្រូវពឹងផ្អែកដោយផ្ទាល់ទៅលើវត្តមាននៃការចុះបញ្ជីអត្រានុកូលដ្ឋានដែលមានដំណើរការល្អផងដែរ។ ប្រព័ន្ធនេះក៏ជួយលើកកម្ពស់សមភាពយេនឌ័រ ការពារ និងកាត់បន្ថយហានិភ័យនៃភាពគ្មានរដ្ឋ ការជួញដូរមនុស្ស ការរៀបអាពាហ៍ពិពាហ៍កុមារ និងការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង ពលកម្មកុមារ និងបញ្ហាផ្សេងៗទៀត។ ហេតុផលទាំងនេះបង្ហាញឱ្យឃើញថា ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដែលមានដំណើរការល្អ មានប្រសិទ្ធភាពនិងមានលក្ខណៈប្រមូលផ្តុំ នឹងរួមចំណែកដ៏ទូលំទូលាយដល់ការអភិវឌ្ឍធនធានមនុស្ស ក៏ដូចជារួមចំណែកទៅដល់គោលដៅអភិវឌ្ឍន៍ទាំងឡាយរបស់ប្រទេស។

សារៈសំខាន់នៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែលមានដំណើរការល្អ ជាបណ្តាញដ៏មានប្រសិទ្ធភាព គឺត្រូវមានការយល់ដឹង និងប្រើប្រាស់ដូចៗគ្នា និងមានការចែករំលែកដល់បណ្តាប្រទេសនានាក្នុងតំបន់ និងប្រទេសផ្សេងៗទៀត។ នៅក្នុងឆ្នាំ២០១៤ សន្និសីទថ្នាក់រដ្ឋមន្ត្រីស្តីពីអត្រានុកូលដ្ឋាន និងស្ថិតិអត្រា

នុកូលដ្ឋាន បានប្តេជ្ញាចិត្តលើក្របខ័ណ្ឌសកម្មភាពថ្នាក់តំបន់ប៉ាស៊ីហ្វិក ដោយបានកំណត់ឡើងនូវគោលបំណង (Goals) គោលដៅ (Targets) និងផែនការសកម្មភាព (Areas of action) ថ្នាក់ជាតិ ដើម្បីជួយពន្លឿនការកែលម្អប្រព័ន្ធនៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន នៅក្នុងទ្វីបអាស៊ីនិងប៉ាស៊ីហ្វិកឱ្យបានត្រឹមឆ្នាំ២០២៤។ ប្រទេសកម្ពុជាគឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនិងការប្តេជ្ញាចិត្តនេះ។

សន្និសីទអន្តរជាតិស្តីពីការគ្រប់គ្រងអត្តសញ្ញាណកម្មដែលបានធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ២០១៤ នៅទីក្រុងសេអ៊ូល បានក្រើនរំលឹកដល់រាជរដ្ឋាភិបាលនៃប្រទេសនីមួយៗឱ្យបង្កើនកិច្ចខំប្រឹងប្រែងរបស់ខ្លួននៅក្នុងការអភិវឌ្ឍ និងអនុវត្តនូវវិធីសាស្រ្តគ្រប់ជ្រុងជ្រោយមួយសម្រាប់ការបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណកម្មដ៏រឹងមាំមួយ ដោយចាប់ផ្តើមពីការប៉ាន់ប្រមាណឱ្យបានស៊ីជម្រៅ ហើយនិងដាក់ចេញនូវផែនការសកម្មភាពថ្នាក់ជាតិដើម្បីអនុវត្ត និងមានការកំណត់ធនធានឱ្យបានច្បាស់លាស់សម្រាប់ប្រើប្រាស់នៅក្នុងគោលបំណងពន្លឿនការកែលម្អប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ព្រមទាំងការគ្រប់គ្រងអត្តសញ្ញាណ។ សន្និសីទនេះក៏បានលើកទឹកចិត្តឱ្យរដ្ឋាភិបាលដាក់ចេញនូវគោលនយោបាយចាំបាច់ ព្រមទាំងក្របខ័ណ្ឌច្បាប់ស្តីពីការការពារទិន្នន័យបុគ្គល និងការសម្ងាត់ឯកជននៅក្នុងប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណកម្មពលរដ្ឋនេះ។ សន្និសីទនេះក៏បានគូសបញ្ជាក់អំពីការពង្រឹងនូវកិច្ចសម្របសម្រួលរវាងអាជ្ញាធរអត្តសញ្ញាណជាតិ និងអាជ្ញាធរចុះបញ្ជីអត្រានុកូលដ្ឋាន ព្រមទាំងភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងការគ្រប់គ្រងអត្តសញ្ញាណ និងដើម្បីធានាអំពីការចុះបញ្ជីព្រឹត្តិការណ៍រស់នៅសំខាន់ៗឱ្យមានប្រសិទ្ធភាព។ សន្និសីទនេះ ក៏បានសង្កត់ធ្ងន់លើកិច្ចប្រតិបត្តិការរវាងប្រព័ន្ធអាជ្ញាធរអត្តសញ្ញាណកម្មជាតិ ជាមួយអាជ្ញាធរចុះបញ្ជីអត្រានុកូលដ្ឋាន និងអ្នកពាក់ព័ន្ធគន្លឹះៗដទៃទៀត ក្នុងការគ្រប់គ្រង ចាត់ចែងការងារអត្តសញ្ញាណកម្ម និងធានាប្រសិទ្ធភាពនៃការចុះបញ្ជីព្រឹត្តិការណ៍ជីវិតទាំងឡាយ ដែលធ្វើឱ្យមានតម្រូវការអន្តរប្រតិបត្តិការរវាងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ប្រព័ន្ធអត្តសញ្ញាណកម្មស៊ីវិល និងប្រព័ន្ធផ្សេងទៀត ដើម្បីពង្រឹងការផ្តល់សេវា និងធានាបាននូវទិន្នន័យទាន់ពេលវេលា ត្រឹមត្រូវ និងអាចជឿទុកចិត្តបានសម្រាប់ប្រើប្រាស់ក្នុងការធ្វើការសម្រេចចិត្ត។

ប្រទេសកម្ពុជាបានទទួលស្គាល់ពីភាពចាំបាច់ក្នុងការកែលម្អប្រព័ន្ធគ្របគ្រងអត្តសញ្ញាណកម្មប្រជាពលរដ្ឋ និងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។ នាពេលថ្មីៗនេះ អត្រានៃការចុះបញ្ជីកំណើតក្នុងប្រទេសកម្ពុជា សម្រេចបានក្នុងកម្រិតប្រមាណ៧៤ភាគរយ ក្នុងចំណោមក្មេងដែលមានអាយុក្រោម៥ឆ្នាំ។ នៅមានការខុសគ្នាខ្លាំងរវាងតំបន់នានាដូចជា តំបន់ជនបទ និងតំបន់ទីប្រជុំជន ហើយក៏មានភាពខុសប្លែកគ្នាផ្នែកសង្គមផងដែរនៅលើអត្រានៃការចុះបញ្ជីកំណើតនេះ។ នៅមានការផ្តល់តម្លៃតិចតួចបំផុតចំពោះការចុះបញ្ជីកុមារនៅកម្ពុជា ហើយបញ្ហាពាក់ព័ន្ធនឹងបរិបទវប្បធម៌ លទ្ធភាពទទួលបានសេវា ឬក៏ការដាក់ចេញនូវការផាកពិន័យ ក៏ជាកត្តាដែលនាំឱ្យជះឥទ្ធិពលដល់លទ្ធផលនេះដែរ។

ដូច្នេះ ផែនការថ្នាក់ជាតិសម្រាប់កែលម្អប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណកម្ម និងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានតម្រូវឱ្យមានការបង្កើត និងពង្រឹងប្រព័ន្ធចម្រុះមួយ ដែលតម្រូវឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ផែនការបែបនេះត្រូវតែកសាងឡើងបន្ថែមទៅលើចំនុចខ្លាំង និងការអនុវត្តជាក់ស្តែងនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែលមានស្រាប់ ព្រមទាំងផ្តល់នូវដំណោះស្រាយមួយដ៏ល្អបំផុត មានប្រសិទ្ធភាពខ្ពស់ អាចវាស់វែងបាន និងមានគណនេយ្យភាព ដែលអាចជួយឱ្យសម្រេចបាននូវលទ្ធផលជាក់ស្តែង ថែមទាំងអាចលើកកម្ពស់ជីវិតរស់នៅរបស់ប្រជាពលរដ្ឋផងដែរ។

ផ.អ.យ.ជ. ២០១៤-២០១៨ របស់រាជរដ្ឋាភិបាលកម្ពុជា បានស្តែងចេញនូវបញ្ហាប្រឈមមួយចំនួន ដែលកម្ពុជាកំពុងតែជួបប្រទះក្នុងពេលបច្ចុប្បន្ននេះ។ ការអភិវឌ្ឍ និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណកម្មដែលមានដំណើរការល្អ មានការប្រមូលផ្តុំ និងមានប្រសិទ្ធភាព នឹងរួមចំណែកជាវិជ្ជមាននៅក្នុងការដោះស្រាយបញ្ហាទាំងអស់នេះ មានដូចជា ៖

- ផ.យ.អ.ជ. បានចែងថា សេដ្ឋកិច្ចកម្ពុជានឹងធ្វើដំណើរឆ្ពោះទៅមុខឱ្យក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបក្នុងពេលឆាប់ៗនេះ។ នៅពេលនោះប្រទេសកម្ពុជានឹងក្លាយទៅជាប្រទេសដែលមិនសូវទទួលបានជំនួយឥតសំណងទៀតទេ ដោយត្រូវពឹងផ្អែកខ្លាំងទៅលើប្រាក់កម្ចី (កម្ចីសម្បទាន ឬកម្ចីផ្សេងទៀត) វិញ ហេតុនេះកម្ពុជាត្រូវតែខិតខំបង្កើនធនធានរបស់ខ្លួនឱ្យកាន់តែច្រើនថែមទៀតនៅកម្រិតទីផ្សារ (ឬជាមួយនឹងការផ្តល់សម្បទានមួយចំនួនប៉ុន្តែផ្អែកទៅលើមូលដ្ឋានសងវិញ) ទាំងពីប្រភពក្នុងស្រុក និងប្រភពក្រៅស្រុក ដើម្បីផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគទៅលើផែនការវិស័យសាធារណៈ។ បន្ទាប់មក ត្រូវបណ្តុះឡើងនូវប្រសិទ្ធភាពនៃការប្រើប្រាស់ទៅលើធនធានទាំងអស់នោះ។ ប្រសិទ្ធផល និងប្រសិទ្ធភាពនៃប្រព័ន្ធអត្តសញ្ញាណកម្ម ពិតជាមានសារៈសំខាន់សម្រាប់ការគៀងគរធនធានពីខាងក្នុង និងដើម្បីធ្វើឱ្យការចំណាយសារធារណៈកាន់តែមានប្រសិទ្ធភាព និងចំគោលដៅ។
- ប្រទេសកម្ពុជានឹងធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅត្រឹមឆ្នាំ២០១៥ ដែលនៅក្នុងពេលនេះ របាំងជាច្រើនរវាងប្រទេសនានានៅក្នុងតំបន់នឹងត្រូវទម្លាក់ចោល។ ដូច្នេះ រដ្ឋាភិបាលត្រូវត្រៀមរៀបចំខ្លួនឱ្យបានគ្រប់គ្រាន់ សម្រាប់លំហូដោយសេរីនៃកម្មករជំនាញ មូលធន និងការតម្រឹមអត្រាពន្ធ។ ចំនុចទាំងអស់នេះនឹងបង្កជាបញ្ហាជាច្រើនសម្រាប់ទីផ្សារការងារ ការប្រើប្រាស់ដីធ្លី និងចំណូលថវិកាជាតិ។ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មដែលមានប្រសិទ្ធភាព និងប្រសិទ្ធផល គឺជាសមាសធាតុដ៏ខ្លាំងមួយសម្រាប់ការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងហិរញ្ញវត្ថុនេះ។
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក៏បានចែងផងដែរថា នៅដំណាក់កាលបន្ទាប់ វិស័យអភិបាលកិច្ចល្អត្រូវទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងដ៏មុតមាំ ក្នុងការនាំយកមកនូវអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិច ដើម្បីធ្វើឱ្យអភិបាលកិច្ចកាន់តែមានប្រសិទ្ធភាព។ ដើម្បីធ្វើឱ្យរឿងនេះសម្រេចទៅបាន រដ្ឋាភិបាលចាំបាច់ត្រូវតភ្ជាប់ខ្សែបណ្តាញអេឡិចត្រូនិច "electronic-wiring" នៅទូទាំងប្រទេស ជាមួយនឹងការបង្កើតប្រព័ន្ធទិន្នន័យអនឡាញ (oline databases) ព្រមទាំងការផ្តល់នូវសេវាកម្មតាមប្រព័ន្ធអេឡិចត្រូនិច។ ការវិនិយោគទៅលើសមត្ថភាពជំនាញនៅក្នុងរាជរដ្ឋាភិបាល និងការវិនិយោគនៅលើផ្នែករូបវន្តចាំបាច់សម្រាប់បម្រើឱ្យការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច គឺជាប្រការដ៏មានសារៈសំខាន់មួយ។ ការអភិវឌ្ឍ និងការអនុវត្តនូវប្រព័ន្ធអត្តសញ្ញាណកម្មដែលមានប្រសិទ្ធភាព និងប្រសិទ្ធផល គឺជាផ្នែកជាយុទ្ធសាស្ត្រនៃកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះ។ ការអនុវត្តប្រព័ន្ធអត្តសញ្ញាណកម្មដែលមានមុខងារដំណើរការល្អ មានលក្ខណៈផ្ទៃក្នុង និងដែលមានប្រសិទ្ធផល នឹងដើរតួនាទីក្នុងការបម្រើដល់កំណែទម្រង់សំខាន់ៗមួយចំនួនដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

## IV. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

### ៤.១. ចក្ខុវិស័យ និងបេសកកម្ម

ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជារហូតដល់ឆ្នាំ២០៣០ គឺកម្ពុជាត្រូវសម្រេចឱ្យក្លាយជាប្រទេសមួយដែលមានភាពរស់រវើកខាងផ្នែកវប្បធម៌ មានភាពរីកចម្រើនខាងផ្នែកអប់រំ និងមានភាពស៊ីសង្វាក់ផ្នែកសង្គម ដោយមិនមានភាពក្រីក្រ មិនមានអនក្ខរភាព និងមិនមានបញ្ហាសុខភាព ព្រមទាំងជាទីកន្លែងមួយដែលប្រជាជនកម្ពុជារស់នៅប្រកបដោយភាពសុខដុមរមនា មិនមានការអត់ឃ្លាន មិនមានវិសមភាព មិនមានការផាត់ចេញ មិនមានភាពងាយរងគ្រោះ និងជាកន្លែងដែលពលរដ្ឋទាំងអស់អាចសម្រេចបាននូវសក្តានុពលពេញលេញរបស់ពួកគេតាមរយៈការងារដែលពួកគេជ្រើសរើសដើម្បីរួមចំណែកអភិវឌ្ឍប្រទេស ព្រមទាំងស្ដារស្ថានភាពជីវភាពកាន់តែរីកចម្រើនឡើង ក៏ដូចជាដើម្បីអភិវឌ្ឍសង្គមមួយប្រកបដោយនិរន្តរភាពដែលអាចធានាបាននូវស្ថេរភាពរយៈពេលវែងនៃធនធានធម្មជាតិ និងបរិស្ថាន ដែលសកម្មភាពផ្នែកសេដ្ឋកិច្ចទាំងអស់ត្រូវពឹងផ្អែកទៅលើធនធានទាំងនេះ និងដើម្បីអភិវឌ្ឍឱ្យមាននូវសកម្មភាពហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពសេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព ដោយមិនមានផលប៉ះពាល់សង្គម និងផលប៉ះពាល់បរិស្ថានជាអវិជ្ជមានឡើយ។

ក្នុងគោលបំណងដើម្បីសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងសម្រាប់ប្រទេសកម្ពុជាគឺ ៖

"មនុស្សគ្រប់រូបត្រូវបានកំណត់អត្តសញ្ញាណ"

ការធ្វើបែបនេះនឹងបង្កើតឱ្យមាននូវព័ត៌មានជាមូលដ្ឋានមួយសម្រាប់បុគ្គលគ្រប់រូប និងសម្រាប់ប្រជាពលរដ្ឋជាទូទៅដែលជាកត្តាមួយអាចជំរុញឱ្យវិស័យផ្សេងៗដែលពាក់ព័ន្ធទៅនឹងសង្គម សុខភាព អប់រំ ការងារ យុត្តិធម៌ សេដ្ឋកិច្ច និងសន្តិសុខ អាចរៀបចំផែនការបាន និងអាចអនុវត្តនូវយុទ្ធសាស្ត្រទាំងឡាយរបស់វិស័យខ្លួនបានដើម្បីធានាឱ្យមានអភិបាលកិច្ចមួយដែលផ្ដោតទៅលើប្រជាជន។

ចក្ខុវិស័យនៃការងារអត្តសញ្ញាណកម្មនៅក្នុងប្រទេសកម្ពុជាគឺ ៖

*"ជាស្ថាប័នរដ្ឋបាលសាធារណៈដែលផ្ដោតទៅលើសេវាកម្ម និងមានភាពទំនើប នៅក្នុងប្រទេសកម្ពុជា ក្នុងគ្រប់គ្រងទិន្នន័យអត្តសញ្ញាណប្រជាពលរដ្ឋនិងព្រឹត្តិការណ៍ជីវិត ព្រមទាំងផលិតនូវកំណត់ត្រាប្រជាពលរដ្ឋ និងកំណត់ត្រាសំខាន់ៗទុកចិត្តបាន និងផលិតនូវស្ថិតិអត្រានុកូលដ្ឋាន"*

បេសកកម្មនៃការងារអត្តសញ្ញាណកម្មនៅក្នុងប្រទេសកម្ពុជាគឺ ៖

*"ចុះបញ្ជីអត្រានុកូលដ្ឋានដល់មនុស្សគ្រប់រូប និងប្រមូលស្ថិតិអត្រានុកូលដ្ឋាន តាមវិធីប្រកបដោយតម្លាភាព មិនរើសអើង និងមានប្រសិទ្ធភាព ក្នុងគោលបំណងផ្ដល់នូវភស្តុតាងអត្តសញ្ញាណ សម្រាប់ធានាឱ្យមានសិទ្ធិស្មើគ្នានៅក្នុងសង្គម និងផ្ដល់នូវទិន្នន័យទុកចិត្តបាន និងមានសុវត្ថិភាព ដល់អភិបាលកិច្ចល្អ និងដល់ការអភិវឌ្ឍវិស័យឯកជននិងសាធារណៈនៅក្នុងប្រទេសកម្ពុជា"*

អត្តសញ្ញាណកម្មពលរដ្ឋដែលមានលក្ខណៈសកល គឺជាធាតុដ៏មានសារៈសំខាន់មួយសម្រាប់កិច្ចខំប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីអភិវឌ្ឍដែលផ្តោតទៅលើមនុស្សនៅក្នុងប្រទេសកម្ពុជា។ ការយកចិត្តទុកដាក់លើកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជានៅក្នុងការរៀបចំបង្កើតឱ្យមានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ព្រមទាំងបញ្ហាប្រឈមដែលកំពុងតែកើតមាននៅក្នុងពេលបច្ចុប្បន្ននេះ បានបង្កើតឡើងនូវគោលបំណង និងគោលដៅដែលមានតថភាពជាក់ស្តែង ព្រមទាំងបានបង្កើតសកម្មភាពសម្រាប់អនុវត្តជាច្រើន ដើម្បីឈានទៅសម្រេចបាននូវគោលបំណង និងគោលដៅដែលបានកំណត់ឡើងទាំងអស់នេះ។

តួនាទីរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលនៅគ្រប់កម្រិត ត្រូវតែឆ្លុះបញ្ចាំង និងកំណត់ឱ្យបានច្បាស់អំពីការធ្វើសមាហរណកម្មនៃគោលបំណងទាំងអស់នេះចូលទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីរបស់ខ្លួន និងដើម្បីធានាឱ្យបាននូវការរួមចំណែកដ៏សំខាន់ដល់ការរីកចម្រើននៃវិស័យអត្តសញ្ញាណកម្មនៅក្នុងប្រទេសកម្ពុជា។ សហគ្រាសឯកជន អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាន ក៏ត្រូវរួមចំណែកក្នុងការសម្រេចឱ្យបាននៅបេសកម្មទាំងនេះដែរ។

## ៤.២. ក្របខ័ណ្ឌសកម្មភាពសំខាន់ៗ

គណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក បានអនុម័តនូវសេចក្តីសម្រេចមួយដែលអំពាវនាវឱ្យមានផែនការសកម្មភាពជាក់លាក់មួយចំនួនដែលឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។ តាមរយៈផែនការសកម្មភាពយុទ្ធសាស្ត្រនេះ ចង្កោមសកម្មភាពនានា ត្រូវតែកំណត់ឱ្យបានទូលំទូលាយនៅក្នុងគោលបំណងជាយុទ្ធសាស្ត្រ គោលដៅ និងសកម្មភាព។

### *៤.២.១. ការប្តេជ្ញាចិត្តខាងនយោបាយ*

ភាពជាអ្នកដឹកនាំផ្នែកនយោបាយ និងឆន្ទៈនយោបាយ ដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាថា ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែលមានដំណើរការល្អ មានការឆ្លើយតប រួមទាំងប្រព័ន្ធអត្តសញ្ញាណកម្មផងដែរ ត្រូវបានចាត់ទុកជាបំណងប្រាថ្នាជាអាទិភាពរបស់រាជរដ្ឋាភិបាល។ តួនាទីនៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានក្នុងការធានាសិទ្ធិមនុស្ស សិទ្ធិសេដ្ឋកិច្ច សិទ្ធិសង្គម និងសិទ្ធិពលរដ្ឋ ការធានាប្រសិទ្ធភាពនិងប្រសិទ្ធផលនៃការរៀបចំផែនការទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និង ការធាននានូវអភិបាលកិច្ចល្អនិងតម្លាភាព គឺត្រូវតែបានការយល់ដឹងឱ្យបានទូលំទូលាយ ហើយនិងមានការប្តេជ្ញាចិត្តខ្ពស់ចំពោះតួនាទីនេះ។ ការប្តេជ្ញាចិត្តផ្នែកនយោបាយមានន័យថា ជាការធានាឱ្យមានធនធានគ្រប់គ្រាន់ ទាំងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដែលត្រូវវិភាជសម្រាប់ការអនុវត្ត និងការប្រព្រឹត្តទៅនៃប្រព័ន្ធនេះប្រកបដោយគុណភាព និរន្តរភាព អចិន្ត្រៃយ៍ និងសុវត្ថិភាពនៃកំណត់ត្រាព័ត៌មានទាំងអស់។

ការប្តេជ្ញាចិត្តផ្នែកនយោបាយ ត្រូវបង្រួមមកឱ្យអាចបង្កើតបាននូវរចនាសម្ព័ន្ធអភិបាលកិច្ចច្បាស់លាស់តែមួយគត់សម្រាប់អនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ នេះ។ គណៈកម្មាធិការជាតិដឹកនាំដែលមានសមាសភាពជា ឥស្សរជនជាន់ខ្ពស់មកពីក្រសួងពាក់ព័ន្ធ និងមានប្រធានជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងការឃ្លាំមើលដំណើរការជាទូទៅ និងពិនិត្យមើលលើការអនុវត្ត និងតាមដានការរីកចម្រើននានាដើម្បីឆ្ពោះទៅសម្រេចបានគោលបំណង និងគោលដៅដែលបានបង្កើតឡើង។ រចនាសម្ព័ន្ធគាំទ្រអភិបាលកិច្ចនៅក្នុងកម្រិត

ប្រតិបត្តិការ ក៏ត្រូវតែរៀបចំឡើងឱ្យមានការទទួលខុសត្រូវច្បាស់លាស់ផងដែរ។ ការរៀបចំនេះរួមមាន កម្រិតនៃការទទួលខុសត្រូវតាមថ្នាក់រដ្ឋបាលនានាក្នុងការកសាងផែនការ គោលបំណងការងារ និងអាណត្តិការងារនៅគ្រប់ខ្សែរសង្វាក់ប្រតិបត្តិការ ព្រមទាំងការទទួលខុសត្រូវក្នុងការតាមដានវាយតម្លៃ ក៏ដូចជាការកែតម្រូវផ្សេងៗ។

ជាទូទៅ ការប្តេជ្ញាចិត្តផ្នែកនយោបាយ ត្រូវបានបរិយាយចេញទៅជាសកម្មភាពនានានៅក្នុង ផ.យ.ជ.អ. ២០១៥-២០២៤ ដូចខាងក្រោម ៖

(ក). ថ្នាក់ដឹកនាំកំពូល ត្រូវមានភាពជាអ្នកដឹកនាំខ្ពស់ក្នុងការប្តេជ្ញាចិត្តចំពោះការងារលើកកម្ពស់ការចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មនៅកម្ពុជា ព្រមទាំងធ្វើការប្រកាស និងបកស្រាយពន្យល់ឱ្យបានទូលំទូលាយអំពីកិច្ចការនេះ។

(ខ). ត្រូវបង្កើតគណៈកម្មាធិការជាតិដឹកនាំតម្រង់ទិសការងារអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ( National Steering Committee on CRVS and Identification ) សម្រាប់ឃ្លាំមើលទូទៅលើការងារអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

(គ). ត្រូវបង្កើតរចនាសម្ព័ន្ធអភិបាលកិច្ចប្រកបដោយការទទួលខុសត្រូវ និងមានអាណត្តិជាក់លាក់ ព្រមទាំងកំណត់ឱ្យបានច្បាស់លាស់ពីប្រព័ន្ធរបាយការណ៍។

(ឃ). ត្រូវអនុម័ត ផ.យ.ជ.អ. ២០១៥-២០២៤ ជាមួយនឹងកម្មវិធីថវិកាលម្អិត និងការប្តេជ្ញាចិត្តក្នុងការអនុវត្តផែនការនេះ។

### *៤.២.២. ការចូលរួមរបស់សាធារណជន និងការជំរុញឱ្យមានតម្រូវការ*

ការបង្កើនឡើងនូវអត្រាគ្របដណ្តប់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន តម្រូវឱ្យបុគ្គលម្នាក់ៗ ព្រមទាំងក្រុមគ្រួសារទាំងឡាយ ត្រូវមានការយល់ដឹងអំពីគុណតម្លៃនៃការប្រកាស និងមានចេតនាប្រកាសអំពីព្រឹត្តិការណ៍ជីវិតឱ្យដល់អាជ្ញាធរមានសមត្ថកិច្ច។ គុណតម្លៃនេះត្រូវតែខិតខំប្រឹងប្រែងធ្វើឱ្យមានឡើង និងធ្វើការផ្សព្វផ្សាយ។ ប្រជាពលរដ្ឋនៃសង្គមដែលបានទទួលព័ត៌មានសមស្រប អាចនឹងប្រើប្រាស់ព័ត៌មានទាំងនោះសម្រាប់ធ្វើការសម្រេចចិត្តដ៏មានប្រយោជន៍ចំពោះខ្លួន ក៏ដូចជាសមាជិកគ្រួសាររបស់ពួកគេ។ ដូច្នេះ ការលើកកម្ពស់យុទ្ធនាការផ្សព្វផ្សាយជាសាធារណៈ និងមានគោលដៅជាក់លាក់ គឺជាប្រការដ៏ចាំបាច់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីអត្ថន័យនៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងការងារអត្តសញ្ញាណកម្ម។ ជាបន្ថែមទៀត ការប្រាស្រ័យទាក់ទងផ្ទៃក្នុងនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មដ៏រឹងមាំមួយ នឹងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកសាងសមត្ថភាព និងការធានាគុណភាពនៃសេវាកម្មដែលត្រូវផ្តល់។ ការចូលរួមពាក់ព័ន្ធពីសាធារណជនតាមរយៈលទ្ធភាពនៅក្នុងការផ្តល់មតិយោបល់ត្រឡប់ ក៏ដើរតួនាទីយ៉ាងសំខាន់គួរឱ្យកត់សម្គាល់ផងដែរនៅក្នុងការកែលម្អគុណភាពសេវាកម្មដែលផ្តល់ដោយអាជ្ញាធរ។ ហេតុនេះ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែលមានលក្ខណៈជាសកល និងមានការឆ្លើយតប ត្រូវតែពឹងផ្អែកទៅលើទំនាក់ទំនងនៃជំនឿទុកចិត្តទៅលើគ្នាទៅវិញទៅមក ព្រមទាំងគណនេយ្យភាពរវាងអាជ្ញាធរ និងសាធារណជន។

នៅពេលដែលសំណូមពរ ឬតម្រូវការឱ្យមានការចុះបញ្ជីអត្រានុកូលដ្ឋាន សម្រាប់ធ្វើជាមូលដ្ឋានក្នុងការផ្តល់សេវារបស់វិស័យសាធារណៈ និងឯកជននោះ វានឹងមានការជំរុញឱ្យមានកំណើនតម្រូវការនៃការចុះបញ្ជីអត្រានុកូលដ្ឋាននេះជាពុំខាន។ នៅក្នុងន័យនេះ កិច្ចសហការ និងការផ្លាស់ប្តូរព័ត៌មានគ្នាជាប្រចាំរវាងអាជ្ញាធរទទួល

បន្ទុកការងារចុះបញ្ជីអត្រានុកូលដ្ឋាន និងវិស័យសាធារណៈ ក៏ដូចជាវិស័យឯកជនដទៃទៀត ត្រូវរំពឹងថានឹងកើតមានឡើងតាមរយៈការអនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ នេះ។

សកម្មភាពដ៏សកម្មក្នុងការជំរុញឱ្យមានកំណើនតម្រូវការនេះ មានការជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពលើកកម្ពស់ការផ្តល់សេវាកម្ម ហេតុនេះ គុណភាពនៃសេវាកម្មនេះនឹងត្រូវរួមចំណែកដល់អត្រាកំណើនចំនួនអ្នកចុះបញ្ជីជាពុំខាន។

ការចូលរួមពាក់ព័ន្ធពីសាធារណៈ និងការបង្កើតតម្រូវការ អាចបរិយាយទៅជាសកម្មភាពទាំងឡាយនៅក្នុង ផ.យ.ជ.អ. ២០១៥-២០២៤ ដូចខាងក្រោម ៖

(ក). ត្រូវរៀបចំឱ្យមាននូវយុទ្ធនាការផ្តល់ព័ត៌មានថ្នាក់ជាតិដើម្បីពន្យល់ណែនាំអំពីសារៈសំខាន់នៃការចុះបញ្ជីព្រឹត្តិការណ៍រស់នៅរបស់បុគ្គលម្នាក់ៗ និងក្រុមគ្រួសារ ព្រមទាំងលើកទឹកចិត្តដល់ពួកគេឱ្យចូលរួមក្នុងការប្រកាស និងចុះបញ្ជីព្រឹត្តិការណ៍រស់នៅរបស់ខ្លួន។

(ខ). ត្រូវរៀបចំវិធីសាស្រ្ត និងកំណត់គោលដៅ ស្របតាមវត្ថុបំណងនៃការលើកកម្ពស់ការយល់ដឹងដោយធ្វើយ៉ាងណាឱ្យបានជ្រួតជ្រាបដល់ក្រុមជនដែលមានការចុះបញ្ជីទាប ដូចជា ក្រុមជនបាត់បង់សមត្ថភាពពលកម្ម ឬក្រុមដែលបានទទួលការយកចិត្តទុកដាក់តិចតួច។

(គ). ត្រូវរៀបចំឱ្យមាននូវវិធាននានាក្នុងការតស៊ូមតិ និងការផ្សព្វផ្សាយដល់មូលដ្ឋាន មុននឹងចាប់ផ្តើមអនុវត្តគោលបំណងយុទ្ធសាស្រ្តធំៗទាំងអស់ ដើម្បីជានាការយល់ដឹងនៅក្នុងសង្គម។

(ឃ). ត្រូវរៀបចំឱ្យមានការពិភាក្សានៅកម្រិតជាតិ ដើម្បីវិភាគទៅលើផលប្រយោជន៍ដែលអាចមានទាក់ទងជាមួយនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន និងបញ្ជីព្រឹត្តិការណ៍ជីវិត។

(ង). ត្រូវរៀបចំឱ្យមានបណ្តាញគាំទ្រ តាមរយៈការចូលរួម និងការពាក់ព័ន្ធពីសហគមន៍នៅមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាល រួមទាំងអ្នកតំណាងសហគមន៍សាសនា ក្នុងគោលបំណងដើម្បីអនុវត្តនូវសកម្មភាពផ្សព្វផ្សាយ ជាពិសេសនៅតំបន់ខ្សត់ខ្សោយ និងក្រុមជនដែលពិបាកទៅដល់ ដូចជាក្រុមជនបាត់បង់លទ្ធភាពពលកម្ម ឬ និងក្រុមជនដែលទទួលបានការយកចិត្តទុកដាក់តិចតួច។

(ច). ត្រូវរៀបចំឱ្យមាននូវកិច្ចសហការជាមួយនឹងវិស័យសាធារណៈពាក់ព័ន្ធនានា ដូចជា វិស័យសុខាភិបាល និងអប់រំ និងសកម្មភាពផ្សព្វផ្សាយនៅក្នុងវិស័យទាំងអស់នោះ ក្នុងគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងអំពីតួនាទីរបស់ពួកគេក្នុងការជំរុញឱ្យមានកំណើនតម្រូវការក្នុងការចុះបញ្ជីព្រឹត្តិការណ៍រស់នៅ។

(ឆ). ត្រូវរៀបចំបង្កើតឡើងនូវប្រព័ន្ធផ្តល់យោបល់ត្រលប់ពីប្រជាពលរដ្ឋ តាមរយៈការដាក់ឱ្យប្រើប្រាស់ខ្សែទូរស័ព្ទឥតគិតថ្លៃ និងការចូលរួមពីតំណាងសហគមន៍ដែលកំពុងបំពេញការងារជាមួយក្រុមជនងាយរងគ្រោះ ដូចជា សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ដោយត្រូវបញ្ចូលពួកគេទៅក្នុងយន្តការសម្របសម្រួលថ្នាក់ជាតិស្តីពីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។

(ជ). ត្រូវរៀបចំឱ្យមាននូវសកម្មភាពផ្សព្វផ្សាយដើម្បីលើកកម្ពស់អត្រាគ្របដណ្តប់លើការចុះបញ្ជីអត្រានុកូលដ្ឋាន និងបញ្ចូលស្ថាប័នរដ្ឋបាលមូលដ្ឋាន អង្គការសង្គមស៊ីវិល អ្នកផ្តល់ព័ត៌មាន និងអតិថិជនទៅក្នុងសកម្មភាពនេះ។

(ឈ).ត្រូវដាក់ឱ្យដំណើរការនូវប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) និងបច្ចេកវិទ្យាចល័ត សម្រាប់ពង្រឹងប្រព័ន្ធអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ដើម្បីបម្រើឱ្យការផ្តល់សេវាចុះបញ្ជីព្រឹត្តិការណ៍រស់នៅសំខាន់ៗដល់ក្រុមជនពិបាកទៅដល់ ក្រុមជនបាត់បង់លទ្ធភាពពលកម្ម ឬក្រុមជនដែលបានទទួលការយកចិត្តទុកដាក់តិចតួច។

(ញ). ផែនការបង្កើតលេខកូដអត្តសញ្ញាណខ្មែរ (Khmer Identification Code - KIDC) នឹងផ្តល់លទ្ធភាពក្នុងការកំណត់អត្តសញ្ញាណបុគ្គលជាមួយនឹងលេខកូដនេះដោយមិនទាន់មានឈ្មោះ ព្រោះវាអាចផ្តល់ជម្រើសឱ្យឪពុកម្តាយ ឬអាណាព្យាបាលអាចដាក់ឈ្មោះកូនទើបកើតតាមក្រោយ ដោយសារតែប្រពៃណីទំនៀមទំលាប់ជនជាតិដើមភាគតិចមួយចំនួន អាចធ្វើឱ្យការដាក់ឈ្មោះកូនមិនបានទាន់ពេលវេលាក្នុងអំឡុងពេលចុះបញ្ជីកំណើត។

(ដ). ត្រូវកំណត់ឱ្យមាននូវកម្រិតកម្រៃសេវារដ្ឋបាល និងការផាកពិន័យច្រើនប្រភេទ ស្របតាមគោលការណ៍សមធម៌។ ហេតុនេះ នៅពេលបង្កើតបាននូវប្រព័ន្ធដែលអាចជួយពង្រឹងដល់វិស័យសុវត្ថិភាពសង្គមបែបនេះ នឹងជួយគាំទ្រដល់ក្រុមជនដែលត្រូវការការគាំពារពីរាជរដ្ឋាភិបាល។ បន្ទាប់មក អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវបង្កើតប្រព័ន្ធលើកទឹកចិត្តមួយដោយផ្អែកទៅតាមការកំណត់តាមប្រភេទទាំងនេះ។ ខណៈពេលដែលប្រព័ន្ធលើកទឹកចិត្តនេះមិនទាន់អាចបង្កើតបាន ប្រព័ន្ធអត្តសញ្ញាណជនក្រីក្រ (ID Poor) អាចត្រូវពិនិត្យឡើងវិញ និងភ្ជាប់ទៅនឹងការចុះបញ្ជីកំណើត និងអត្តសញ្ញាណកម្ម ព្រមទាំងផ្តល់នូវការលើកទឹកចិត្តសម្រាប់អ្នកកាន់ប័ណ្ណសមធម៌ទាំងនោះផង។

### *៤.២.៣. ការសម្របសម្រួល*

ដោយសារតែមានស្ថាប័ន និងតួអង្គជាច្រើនជាប់ពាក់ព័ន្ធ ហើយក៏ជាអ្នកទទួលបានផលប្រយោជន៍ពីប្រព័ន្ធអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននោះ ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពគឺជាល័ក្ខខ័ណ្ឌដ៏សំខាន់មួយដើម្បីធានាបាននូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មដែលមានលក្ខណៈសកល និងមានការឆ្លើយតប។ ការសម្របសម្រួលគឺត្រូវធ្វើឡើងនៅក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ដែលទទួលខុសត្រូវលើការងារនេះនៅគ្រប់កម្រិតរដ្ឋបាល ក៏ដូចជាក្នុងចំណោមដៃគូអភិវឌ្ឍន៍ និងរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ផងដែរ។

នៅក្នុងប្រទេសកម្ពុជា ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវធ្វើឡើងក្នុងចំណោមរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក ខណ្ឌ រដ្ឋបាលរាជធានី ខេត្ត និងភាគីពាក់ព័ន្ធនៅថ្នាក់ជាតិដែលត្រូវចូលរួមក្នុងការធ្វើគោលនយោបាយ ការកត់ត្រា និងការចុះបញ្ជីនៅពេលមានព្រឹត្តិការណ៍ជីវិតដែលបានកើតឡើង។ ការចូលរួមជាបន្តបន្ទាប់ពីភាគីពាក់ព័ន្ធនៅគ្រប់កម្រិតរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន រួមទាំងដៃគូអភិវឌ្ឍដែលបានចូលរួមក្នុងការរៀបចំ ផ.យ.ជ.អ. ២០១៥-២០២៤ រំពឹងថានឹងបានយល់ដឹងពីផែនការនេះ ព្រមទាំងចូលរួមនៅក្នុងអំឡុងពេលអនុវត្ត។

*⋆ ក្មេងកំព្រា និងកុមារងាយរងគ្រោះ រួមមាន ៖ ក្មេងកំព្រា និងកុមារដែលមានឪពុកម្តាយ ឬអ្នកថែទាំមានជំងឺរ៉ាំរ៉ៃ រួមទាំងកុមារមានជំងឺហ៊ីវ កុមាររស់នៅក្រៅការថែទាំរបស់គ្រួសារ មានដូចជាកុមាររស់នៅក្នុងមណ្ឌល និងកុមាររស់នៅតាមចញ្ចើមថ្នល់ កុមាររស់នៅក្នុងគ្រួសារក្រីក្រ កុមារត្រូវបានរំលោភបំពានឬកេងប្រវ័ញ្ច កុមារទំនាស់*

*ជាមួយច្បាប់ មានដូចជា កុមារត្រូវបានចោទប្រកាន់/ប្រព្រឹត្តអំពើល្មើស កុមារញៀនគ្រឿងញៀន និងកុមារប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងកុមារពិការ។ មានចែងក្នុងប្រកាសលេខ២០១១ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្ដីពីនីតិវិធីនៃការអនុវត្តគោលនយោបាយថែទាំជំនួសចំពោះកុមារ។*

ការប្ដេជ្ញាចិត្តក្នុងការសម្របសម្រួលនេះត្រូវបរិយាយចេញជាសកម្មភាពនានា ដូចខាងក្រោម ៖

(ក). គ.ជ.ជ.អ. រួមមានឥស្សរជនជាន់ខ្ពស់មកពីក្រសួងពាក់ព័ន្ធ មានតួនាទីរក្សាការសម្របសម្រួលនៅកម្រិតខ្ពស់បំផុតនៃអភិបាលកិច្ច ក្នុងការធានាឱ្យមានការសម្របសម្រួលជាបន្តបន្ទាប់ នៅក្នុងអំឡុងពេលអនុវត្តប្រព័ន្ធទាំងមូល ហើយនិងមានតួនាទីទទួលខុសត្រូវលើការកែតម្រូវចាំបាច់ទាំងឡាយនៅក្នុងដំណើរការនេះ។

(ខ). បន្ទាប់មកត្រូវបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងថ្នាក់ជាតិសម្រាប់អនុវត្តកម្មវិធី ( National Technical Project Implementation Team ) ដែលជារចនាសម្ព័ន្ធតំណាងឱ្យ គ.ជ.ជ.អ. ដើម្បីសម្របសម្រួល និងមើលការខុសត្រូវទៅលើកម្មវិធីទាំងអស់ដែលស្ថិតក្រោម ផ.យ.ជ.អ. ២០១៥-២០២៤ ហើយនិងទទួលខុសត្រូវក្នុងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលនានា។

(គ). ត្រូវកំណត់ឱ្យមានការទទួលខុសត្រូវ និងអាណត្តិច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធអនុវត្តទាំងមូល ដើម្បីធានាការសម្របសម្រួលនៅគ្រប់ចរន្តការងារទាំងអស់។

(ឃ). យន្តការមួយចំនួនដែលបានបង្កើតឡើងនេះ គឺជាមូលដ្ឋានសម្រាប់ការសម្របសម្រួលអន្តរវិស័យ នៅពេលវិស័យពាក់ព័ន្ធរៀបចំធ្វើផែនការយុទ្ធសាស្ត្ររបស់ខ្លួន (ជាពិសេស វិស័យសុខាភិបាល វិស័យអប់រំ និងវិស័យសង្គមផ្សេងៗទៀត) ដែលផែនការយុទ្ធសាស្ត្រវិស័យទាំងនោះត្រូវតែតម្រឹមជាមួយ ផ.យ.ជ.អ. ២០១៥-២០២៤ នេះ។

(ង). ត្រូវបង្កើតឡើងនូវផែនការតាមដានត្រួតពិនិត្យនិងវាយតម្លៃមួយ ដើម្បីធានានូវការអនុវត្តសកម្មភាពឱ្យបានសមស្រប រួមទាំងការដកបទពិសោធន៍ជាបន្តបន្ទាប់។

### ៤.២.៤. គោលនយោបាយ ច្បាប់ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា

ក្របខ័ណ្ឌច្បាប់ដែលរឹងមាំ នឹងផ្ដល់ជាមូលដ្ឋានសម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានប្រកបដោយលក្ខណៈជាសកល និងឆ្លើយតប ព្រមទាំងជួយធានានូវការសំងាត់នៃទិន្នន័យ អត្រាគ្រប់ដណ្ដប់នៃការចុះបញ្ជីព្រឹត្តិការណ៍ជីវិតរស់នៅ និងការផ្ដល់នូវការលើកទឹកចិត្តនានា។ ក្របខ័ណ្ឌច្បាប់នេះក៏ជួយលុបបំបាត់នូវរនាំងនៃការរើសអើងក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន។ នេះគឺជាបុរេលក្ខខ័ណ្ឌសម្រាប់ការអភិវឌ្ឍប្រព័ន្ធផ្សេងទៀតនៅក្រោម ផ.យ.ជ.អ. ២០១៥-២០២៤ និងសម្រាប់ជាវេទិកាបន្ថែមទៀតក្នុងការផ្លាស់ប្ដូរ និងការចែករំលែកនូវព័ត៌មានអំពីប្រជាពលរដ្ឋ។

ក្របខ័ណ្ឌច្បាប់ចាំបាច់ត្រូវធានាថា ការចុះបញ្ជីអត្រានុកូលដ្ឋាននៃព្រឹត្តិការណ៍រស់នៅ គឺជាការងារដែលខ្វះមិនបាន។ ក្របខ័ណ្ឌច្បាប់ក៏ត្រូវកំណត់អំពីមុខងារ ភារកិច្ច និងការទទួលខុសត្រូវរបស់អាជ្ញាធរទទួលបន្ទុកការចុះបញ្ជីអត្រានុកូលដ្ឋាន ព្រមទាំង តួអង្គទាំងឡាយណាដែលត្រូវមានកាតព្វកិច្ចក្នុងការចុះបញ្ជី ដោយធ្វើយ៉ាងណាជួយឱ្យពួកគេមានសមត្ថកិច្ចគ្រប់គ្រាន់លើការងារចុះបញ្ជីនេះ និងលើកកម្ពស់ភាពត្រឹមត្រូវនៃព័ត៌មានដែលមាននៅក្នុងកំណត់ត្រាស៊ីវិលនេះ។

គោលនយោបាយ ច្បាប់ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា ត្រូវបរិយាយចេញជាសកម្មភាពនានាដូចខាងក្រោម ៖

(ក). ត្រូវពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មលើច្បាប់ គោលនយោបាយ និងបទប្បញ្ញត្តិនានាធ្វើយ៉ាងណាឱ្យស្របតាមស្តង់ដាអន្តរជាតិ ដូចបានកំណត់ដោយអង្គការសហប្រជាជាតិ ដើម្បីធានាបាននូវការចុះបញ្ជីសម្រាប់មនុស្សគ្រប់រូបដោយគ្មានការរើសអើង។

(ខ). កំណែទម្រង់ច្បាប់ត្រូវធ្វើឡើងក្នុងគោលបំណងធ្វើសេចក្តីព្រាង ឬធ្វើវិសោធនកម្មច្បាប់គោលមួយចំនួន រួមទាំងលិខិតបទដ្ឋានក្រោមច្បាប់ផ្សេងៗទៀត (អនុក្រឹត្យ) សម្រាប់ការបង្កើត និងប្រតិបត្តិការនៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងប្រព័ន្ធអត្តសញ្ញាណកម្ម ក៏ដូចជាប្រតិបត្តិការនៃការចុះបញ្ជីប្រជាពលរដ្ឋដែលមានលក្ខណៈប្រមូលផ្តុំ ព្រមទាំងសេវាចែករំលែកទិន្នន័យផងដែរ។

(គ). ច្បាប់ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន ត្រូវដាក់ចេញនូវគោលបំណង ប្រព័ន្ធ និងគោលការណ៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។ ចំពោះខ្លឹមសារលម្អិតត្រូវទុកចែងនៅក្នុងលិខិតបទដ្ឋានក្រោមច្បាប់ (ងាយស្រួលធ្វើវិសោធនកម្ម) ដែលសម្រេចដោយរដ្ឋាភិបាល នៅក្នុងទម្រង់ជាអនុក្រឹត្យស្តីអំពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។

(ឃ). ត្រូវធ្វើវិសោធកម្មច្បាប់សញ្ជាតិ អនុក្រឹត្យស្តីពីលិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងការចុះបញ្ជីការស្នាក់នៅ ដើម្បីឱ្យមានទិន្នន័យជាក់លាក់មួយចំនួននៅក្នុងប្រព័ន្ធទិន្នន័យទាំងអស់នោះសម្រាប់ចម្លងបញ្ចូលទៅក្នុង ប.វ.អ.ព.(IPIS) ក៏ដូចជាក្នុងការផ្លាស់ប្តូរទិន្នន័យរវាងស្ថាប័នសាធារណៈដែលទទួលខុសត្រូវទៅលើវិស័យនេះ និង មួយផ្នែកទៀតរវាងផ្នែកសាធារណៈ និងផ្នែកឯកជន។

(ង). មូលដ្ឋានច្បាប់សម្រាប់បញ្ហានេះ គឺការកំណត់អត្តសញ្ញាណបុគ្គលដោយផ្អែកទៅលើការចុះបញ្ជីកំណើត ដោយមានការផ្តល់លេខកូដអត្តសញាណបុគ្គលដែលជាលេខកូដពិសេសមួយសម្រាប់បុគ្គលម្នាក់ៗ ហើយលេខកូដនេះមិនអាចផ្លាស់ប្តូរបានឡើយពេញមួយជីវិតរបស់បុគ្គលនោះ។

(ច). ការត្រួតពិនិត្យឡើងវិញ និងការធ្វើវិសោធកម្មទៅលើគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ត្រូវតែធ្វើឡើងក្នុងគោលដៅរក្សាការសម្ងាត់ទិន្នន័យបុគ្គលដ៏ខ្ពស់បំផុត។

(ឆ). ត្រូវវិភាគ និងពិនិត្យមើលឡើងវិញទៅលើច្បាប់ លិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលពាក់ព័ន្ធជាមួយការងារចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន (ដូចជា ច្បាប់ស្តីពីសុំកូន ច្បាប់ពាក់ព័ន្ធនឹងសុខាភិបាល និងក្នុងវិស័យផ្សេងទៀត)។

(ជ). តាមរយៈការពង្រឹងដោយកំណែទម្រង់ច្បាប់ និងប្រព័ន្ធ ប.វ.គ.ព.(ICT) នឹងនាំឱ្យប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋានថ្មី អាចមានលទ្ធភាពក្នុងការដោះស្រាយបញ្ហា និងកង្វះខាតនានានៅក្នុងប្រព័ន្ធបច្ចុប្បន្ន ហើយអាចធានាឱ្យមានតម្លាភាព ព្រមទាំងទប់ស្កាត់មិនឱ្យមានការចុះបញ្ជីជាន់គ្នា ឬការកែកំណត់ត្រាដែលធ្វើឡើងមិនត្រឹមត្រូវតាមច្បាប់ (ឧទាហរណ៍ កំណត់ត្រានៃការចុះបញ្ជីកំណើតជាដើម)។

(ឈ).គួរពន្យាររយៈពេលចុះបញ្ជីកំណើត (បច្ចុប្បន្ននេះ មានរយៈពេល៣០ថ្ងៃ) ដោយត្រូវពិចារណាឡើងវិញក្នុងអំឡុងពេលធ្វើកំណែទម្រង់ច្បាប់។

(៣). កំណែទម្រង់ច្បាប់ត្រូវធ្វើឡើងក្រោមកិច្ចសហការយ៉ាងជិតស្និទជាមួយនឹងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកជំនាញការអន្តរជាតិផ្សេងៗទៀត។

### ៤.២.៤. *ហេដ្ឋារចនាសម្ព័ន្ធ និងធនធាន*

ការចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម ស្ថិតិអត្រានុកូលដ្ឋាន និងប្រព័ន្ធព័ត៌មានពលរដ្ឋ ត្រូវការហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដ៏រឹងមាំមួយ។ ត្រូវតែធានាឱ្យបាននូវមជ្ឈមណ្ឌលចុះបញ្ជីដែលអាចចូលមើលទិន្នន័យបាន សមត្ថភាពបុគ្គលិក និងអ្នកផ្តល់ព័ត៌មាន(Informants)ដែលមានគុណភាព ហេដ្ឋារចនាសម្ព័ន្ធ ប.វ.គ.ព. (ICT) ការភ្ជាប់ទំនាក់ទំនង និងការផ្តល់ហិរញ្ញប្បទានដែលធានាឱ្យប្រព័ន្ធមានដំណើរការជាប្រចាំ និងជាអចិន្ត្រៃយ៍ក្នុងការចុះបញ្ជី។ ការវិនិយោគប្រកបដោយនិរន្តភាព និងប្រសិទ្ធភាព ពិតជាមានសារៈសំខាន់ណាស់ក្នុងការជំរុញឱ្យមានការកែលម្អជាបន្តបន្ទាប់ដល់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន នៅក្នុងវិស័យធនធានមនុស្ស ហេដ្ឋារចនាសម្ព័ន្ធ សម្ភារៈ និងការផ្គត់ផ្គង់ជាដើម។ ធនធានមនុស្ស ធនធាន ប.វ.គ.ព. (ICT) និងធនធានផ្សេងៗទៀត ត្រូវតែមានសម្រាប់ធ្វើឱ្យការចុះបញ្ជីមានប្រសិទ្ធភាព។ ការកសាងសមត្ថភាពត្រូវតែគិតគូររៀបចំឡើងនៅគ្រប់ស្ថាប័នទាំងអស់ ដែលត្រូវចូលរួមដោយផ្ទាល់នៅក្នុងដំណើរការនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ដោយរួមបញ្ចូលទាំងអ្នកផ្តល់ព័ត៌មាន (Informants) ជាពិសេសគ្រូពេទ្យដែលត្រូវកំណត់ឱ្យបានត្រឹមត្រូវ និងកត់ត្រាភ្លាមៗអំពីមូលហេតុនៃមរណៈភាព។ ការកសាងសម្ថភាពដល់មន្ត្រីក៏មានសារៈសំខាន់ផងដែរ ដើម្បីឱ្យពួកគាត់មានលទ្ធភាពក្នុងការបង្កើត ថែរក្សា និងតាមដានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននេះ។

ទាក់ទងទៅនឹងធនធានមនុស្សសម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ត្រូវតែពឹងផ្អែកទៅលើមន្ត្រីជំនាញដែលមានគុណភាព និងមានចំនួនសមស្រប។ យន្តការសម្រាប់ការអភិវឌ្ឍអាជីព និងការលើកសរសើរ ចាំបាច់ត្រូវចាត់ទុកជាផ្នែកមួយសម្រាប់ធ្វើវិមជ្ឈការជាបន្តបន្ទាប់ និងសម្រាប់កំណែទម្រង់ដែលពាក់ព័ន្ធទៅនឹងសេវាសាធារណៈ។

ហេដ្ឋារចនាសម្ព័ន្ធ និងធនធានត្រូវបរិយាយចេញជាសកម្មភាពនានាដូចខាងក្រោម ៖

(ក). ធានាឱ្យទីតាំងនៃការចុះបញ្ជីមានចំងាយសមល្មមសម្រាប់ប្រជាពលរដ្ឋនៅគ្រប់ឃុំ សង្កាត់ទាំងអស់ និងត្រូវកែលម្អប្រព័ន្ធចុះបញ្ជីមកប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រវិញ ដែលអាចអនុញ្ញាតឱ្យធ្វើការចុះបញ្ជីអត្រានុកូលដ្ឋាននៅតំបន់ដាច់ស្រយាល និងក្រុមប្រជាជនដែលទទួលបានការយកចិត្តទុកដាក់តិចតួចបាន។

(ខ). ត្រូវប្រើប្រាស់ការិយាល័យច្រកចេញចូលតែមួយដែលមានស្រាប់ ក្នុងការផ្តល់ឯកសារអត្តសញ្ញាណកម្ម (ដូចជា អត្តសញ្ញាណប័ណ្ណ) ដើម្បីផ្តល់នូវសេវាកម្មជូនដល់ប្រជាពលរដ្ឋប្រកបដោយគុណភាព និងចំណាយតិចនៅតាមបណ្តារាជធានី ខេត្តនានាដែលមានសេវាទាំងអស់នេះ ហើយជាបណ្តើរៗ ត្រូវរៀបចំផែនការចម្លងយកយន្តការច្រកចេញចូលតែមួយនេះ ទៅអនុវត្តនៅថ្នាក់មូលដ្ឋានផ្សេងៗទៀត ដោយចាប់ផ្តើមពីអាជ្ញាធរមូលដ្ឋានដែលមានស្នាដៃល្អបំផុត។

(គ). ដើម្បីធានាការទទួលបានសេវាកាន់តែងាយស្រួល ទីតាំងជំនួសមួយចំនួនសម្រាប់ការផ្តល់សេវា

ចម្បងៗរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម (ដូចជា ការចុះបញ្ជីអត្រានុកូលដ្ឋាន ការចេញអត្តសញ្ញាណប័ណ្ណ ការផ្តល់សៀវភៅស្នាក់នៅ) ត្រូវធ្វើឡើងនៅការិយាល័យច្រកចេញចូលតែមួយនៅថ្នាក់ឃុំ សង្កាត់ ដែលត្រូវផ្តល់ឱ្យតាមរយៈមន្ត្រីរាជការស៊ីវិល។

(ឃ). ការប្តេជ្ញាចិត្តផ្នែកនយោបាយ គឺជាការជំរុញឱ្យមានការរៀបចំផែនការផ្តល់ហិរញ្ញប្បទានមួយដែលអាចធានាឱ្យមានការវិភាជធនធានហិរញ្ញវត្ថុជាតិឱ្យបានគ្រប់គ្រាន់សម្រាប់អនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ និងដើម្បីធានាឱ្យមាននិរន្តភាពចំពោះកិច្ចខិតខំប្រឹងប្រែងទាំងអស់នេះផង។

(ង). ការកសាងសមត្ថភាព និងកម្មវិធីបណ្តុះបណ្តាលបុគ្គលិកនៅតាមមូលដ្ឋាន ត្រូវតែធ្វើឡើងជាទៀងទាត់ ដោយកម្មវិធីបណ្តុះបណ្តាលនោះត្រូវផ្តោតទៅលើបញ្ហាក្របខ័ណ្ឌច្បាប់ ការអនុវត្តជាក់ស្តែង និងនីតិវិធីនៃការចុះបញ្ជី ដោយមានសម្ភារៈបណ្តុះបណ្តាលច្បាស់លាស់ លម្អិត និងអាចធ្វើការបណ្តុះបណ្តាលជាទៀងទាត់តាមប្រព័ន្ធអនឡាញផ្ទៃក្នុង ឬតាមវិធីសាស្ត្រដទៃទៀត ដូចជាតាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៅសាលារាជធានី ខេត្ត ដែលត្រូវដើរតួនាទីយ៉ាងសំខាន់ដល់ដំណើរការនេះ។

(ច). កសាងសមត្ថភាពមន្ត្រីនៅការិយាល័យច្រកចេញចូលតែមួយដើម្បីផ្តល់សេវាកម្មពាក់ព័ន្ធជាមួយការចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

(ឆ). ការកសាងសមត្ថភាពជាប្រចាំដល់មន្ត្រីអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវធ្វើឡើងស្របគ្នាជាមួយនឹងការអភិវឌ្ឍប្រព័ន្ធ រួមមាន ចំណេះដឹងអំពីក្របខ័ណ្ឌច្បាប់ថ្មី សមត្ថភាពថ្មីៗទាក់ទងនឹងស្ថិតិអត្រានុកូលដ្ឋាន ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅក្នុងការចុះបញ្ជី និងអត្តសញ្ញាណកម្មជាដើម។

(ជ). អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវផ្តល់ការបណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទិន្នន័យប្រជាពលរដ្ឋទៅដល់ស្ថាប័នសាធារណៈផ្សេងៗទៀត រួមទាំងផ្នែកឯកជនផងដែរ។

(ឈ). ត្រូវរៀបចំឱ្យមានកិច្ចសហប្រតិបត្តិការជាមួយវិស័យផ្សេងទៀត ដើម្បីលើកកម្ពស់ការចុះបញ្ជីព្រឹត្តិការណ៍ជីវិតរស់នៅ និងរៀបចំឱ្យមានស្ថិតិអត្រានុកូលដ្ឋាន តាមរយៈការអភិវឌ្ឍសមត្ថភាពនៅក្នុងវិស័យទាំងអស់នោះ (វិស័យជាចម្បងគឺវិស័យសុខាភិបាល)។

### *៤.២.៦. នីតិវិធីប្រតិបត្តិ ការអនុវត្ត និងការច្នៃប្រឌិត*

ផ.យ.ជ.អ. ២០១៥-២០២៤ បានបង្កើតឡើងនៅលើក្របខ័ណ្ឌច្បាប់ និងការរៀបចំស្ថាប័នមួយដ៏រឹងមាំដែលត្រូវធានាឱ្យបាននូវប្រសិទ្ធភាព និងមានភាពស៊ីសង្វាក់គ្នា នៅក្នុងដំណើរការនៃការអនុវត្តនីតិវិធីប្រតិបត្តិ និងការអនុវត្តជាក់ស្តែង។ នីតិវិធីប្រតិបត្តិនេះត្រូវតែបង្កើតឡើង និងត្រូវតែអនុវត្តតាម ដែលជាការធានានូវភាពចាំបាច់នៃមុខងារអត្រានុកូលដ្ឋានក្នុងការផ្តល់នូវឯកសារផ្លូវច្បាប់ដែលអាចជួយបង្កើតឱ្យមានអត្តសញ្ញាណផ្លូវច្បាប់ ស្ថានភាពស៊ីវិល ទំនាក់ទំនងគ្រួសារ និងសញ្ជាតិ ក៏ដូចជាការធានាការការពារនូវសិទ្ធិទាំងឡាយផងដែរ។ ស្រដៀងគ្នានេះដែរ ការបង្កើតឡើងនូវនីតិវិធីប្រតិបត្តិនេះក៏ដើម្បីជួយសម្រួលដល់ការផ្ទេរទិន្នន័យមកនាយកដ្ឋានដែលទទួលបន្ទុកពិនិត្យសម្រេចលើការផលិតស្ថិតិអត្រានុកូលដ្ឋាន និងការផ្សព្វផ្សាយអំពីព័ត៌មានប្រជាពលរដ្ឋទៅដល់វិស័យសាធារណៈ និងវិស័យឯកជននានា។

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម រួមទាំងការចុះអត្រានុកូលដ្ឋានតាមប្រព័ន្ធអ៊ីនធឺណែត

និងសេវាកម្មល្អប្រសើរ នឹងជួយគាំទ្រដល់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងដំណើរការអភិបាលកិច្ចតាមរយៈប្រព័ន្ធអេឡិចត្រូនិច។ លើសពីនេះទៀត ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន បានជួយសម្រួល និងកាត់បន្ថយការចំណាយលើសុវត្ថិភាពការផ្ទុក និងការការពារទិន្នន័យអត្រានុកូលដ្ឋាន និងព័ត៌មានអំពីប្រជាពលរដ្ឋ ឱ្យរួចផុតពីគ្រោះមហន្តរាយធម្មជាតិ ពីសង្គ្រាម និងពីការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណែត។

ការមកដល់នៃបច្ចេកវិទ្យាថ្មីៗ នៅក្នុងស្ថានភាពដែលមានការរឹតត្បិតផ្នែកធនធានបែបនេះ នឹងជួយបង្កឱ្យមានបរិយាកាសអំណោយផលមួយសម្រាប់បង្កើតនូវប្រព័ន្ធព័ត៌មានមួយដែលមានប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការគាំទ្រដល់ការចុះបញ្ជីអត្រានុកូលដ្ឋាន និងប្រព័ន្ធអត្តសញ្ញាណកម្ម។ បច្ចេកវិទ្យានេះមិនមែនមានវត្តមានតែសម្រាប់ពេលដែលសេដ្ឋកិច្ចរីកចម្រើនទើបអាចបង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននេះនោះទេ ប៉ុន្តែប្រទេសដែលមានប្រាក់ចំណូលទាប និងប្រាក់ចំណូលមធ្យមជាច្រើន ក៏អាចបោះជំហានទៅរកការប្រើប្រាស់ប្រព័ន្ធដែលកាន់តែមានប្រសិទ្ធភាពនេះផងដែរ។ បទពិសោធន៍ល្អៗជាច្រើនដែលកំពុងតែមានក្នុងពេលនេះ បានបង្ហាញពីរបៀបដែលគេអាចក្លាយធ្វើជាម្ចាស់នៃប្រព័ន្ធទាំងអស់នោះ ថាតើពួកគេត្រូវត្រៀមលក្ខណៈប្រើប្រាស់វាយ៉ាងដូចម្តេចដើម្បីធានាបាននូវការកត់ត្រាដ៏ត្រឹមត្រូវ និងទូលំទូលាយ ហើយតើត្រូវប្រើប្រាស់ និងធ្វើបច្ចុប្បន្នភាពកំណត់ត្រាទាំងអស់នោះដោយរបៀបណាដើម្បីឱ្យបានផលប្រយោជន៍ទៅដល់ប្រជាពលរដ្ឋ។ កត្តាទាំងនេះទាមទារឱ្យមានការរៀបចំប្រកបដោយការយកចិត្តទុកដាក់ និងមិនអាចសម្រេចបានតាមរយៈកម្មវិធីបណ្តោះអាសន្ននោះទេ (ធនាគារពិភពលោកឆ្នាំ២០១៤)។

នីតីវិធីប្រតិបត្តិ ការអនុវត្តជាក់ស្តែង ការច្នៃប្រឌិតនេះ ត្រូវបរិយាយទៅជាសកម្មភាពនានាដូចខាងក្រោម ៖

(ក). ក្នុងក្របខ័ណ្ឌកំណែទម្រង់ច្បាប់ ត្រូវធ្វើការពិនិត្យឡើងវិញ និងសម្របទៅតាមទម្រង់និងនីតិវិធីនៃការចុះបញ្ជីតាមស្តង់ដាអន្តរជាតិសម្រាប់គោលបំណងស្ថិតិ និងគោលបំណងផ្នែកច្បាប់។

(ខ). ត្រូវដាក់ឱ្យមានការអនុវត្តនូវវិធានការចាំបាច់ដើម្បីធានាគុណភាព និងអធិបតេយ្យភាពនៃឯកសារផ្លូវច្បាប់ណាមួយដែលកើតចេញមកពីប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដែលត្រូវតែថែរក្សាឱ្យបានត្រឹមត្រូវ។

(គ). ត្រូវកំណត់ និងអនុវត្តនូវសកម្មភាពមួយចំនួនដើម្បីការពារការសម្ងាត់ និងសុវត្ថិភាពព័ត៌មានចុះបញ្ជី និងកំណត់ត្រាទាំងអស់នោះ។

(ឃ).ការណែនាំអំពីគំនិតច្នៃប្រឌិតផ្សេងៗ ដូចជា ការប្រើប្រាស់ឧបករណ៍ចល័ត Tablet នៅក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន នឹងបង្កើនឱ្យមានការចុះបញ្ជីកាន់តែច្រើនឡើងតាមរយៈការអនុវត្តការចុះបញ្ជីតាមបែបចល័ត ហើយការប្រើប្រាស់ ប.វ.គ.ព.(ICT) សម្រាប់ការចុះបញ្ជី ការកំណត់អត្តសញ្ញាណ និងការថែរក្សានូវកំណត់ត្រាទាំងអស់ នឹងធានាឱ្យមាននិរន្តរភាព និងចីរភាពនៃដំណើរការនេះ។

(ង). ការណែនាំឱ្យប្រើប្រាស់ ប.វ.គ.ព.(ICT) នឹងជួយគាំទ្រយ៉ាងខ្លាំង និងជួយពង្រីកការចុះបញ្ជី និងការងារអត្តសញ្ញាណកម្មឱ្យកាន់តែទូលំទូលាយ រួមជាមួយក្របខ័ណ្ឌផ្លូវច្បាប់ដ៏រឹងមាំ និងនីតិវិធីជាក់លាក់ដើម្បីដោះស្រាយបញ្ហាសិទ្ធិរបស់បុគ្គល ដូចជាការការពារសិទ្ធិឯកជនភាពជាដើម។

(ច). សមត្ថភាពរបស់មន្ទីរពេទ្យ និងមណ្ឌលសុខភាពក្នុងនាមជាអ្នកផ្តល់ព័ត៌មាន (Informants) អំពីព្រឹត្តិការណ៍រស់នៅ និងសមត្ថភាពរបស់មន្ត្រីអត្រានុកូលដ្ឋានក្នុងការកត់ត្រាព្រឹត្តិការណ៍រស់នៅដែលពាក់ព័ន្ធជាមួយនឹងការដាក់លេខកូដ គឺត្រូវដោះស្រាយតាមរយៈកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយក្រសួងសុខាភិបាល។

(ជ). នីតិវិធីអនុវត្តសម្រាប់ការចុះបញ្ជីព្រឹត្តិការណ៍ជីវិតរស់នៅដល់ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅក្រៅប្រទេស ត្រូវធ្វើការសម្របសម្រួលជាមួយក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការបង្កើតកន្លែងចុះបញ្ជីនៅតាមស្ថានកុងស៊ុលនានា។

### ៤.២.៧. ការផលិត ការផ្សព្វផ្សាយ និងការប្រើប្រាស់ស្ថិតិអត្រានុកូលដ្ឋាន និងព័ត៌មានប្រជាពលរដ្ឋ

ទិន្នន័យរដ្ឋបាលដែលបានមកពីការចុះបញ្ជីអត្រានុកូលដ្ឋាន នៅពេលដែលប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានមានលក្ខណៈជាសកល គឺជាប្រភពទិន្នន័យស្ថិតិអត្រានុកូលដ្ឋានដែលមានភាពត្រឹមត្រូវ ពេញលេញ និងទាន់ពេលវេលាបំផុត។ គុណសម្បត្តិនៃស្ថិតិអត្រានុកូលដ្ឋានដែលពឹងផ្អែកលើការចុះបញ្ជីអត្រានុកូលដ្ឋាននោះ គឺជាទិន្នន័យដែលនឹងអាចបំបែកឱ្យទៅជាផ្នែកតូចៗទាក់ទងជាមួយនឹងប្រជាពលរដ្ឋ ឧទាហរណ៍ ការបែងចែកតាមថ្នាក់រដ្ឋបាលជាដើម។ វិធីសាស្ត្រតាមដំណាក់កាលនៅក្នុងការប្រើប្រាស់កំណត់ត្រានៃការចុះបញ្ជីអត្រានុកូលដ្ឋាន គឺជាប្រភពនៃស្ថិតិអត្រានុកូលដ្ឋាន នឹងត្រូវកំណត់ឡើងក្នុងគោលដៅធានាឱ្យព័ត៌មាននៃការចុះបញ្ជីព្រឹត្តិការណ៍រស់នៅថ្មីៗ ត្រូវបានប្រមូលចងក្រងឡើងតាមរបៀបមួយដែលអនុញ្ញាតឱ្យមានការផលិតនូវស្ថិតិអត្រានុកូលដ្ឋានសម្រាប់រយៈពេលវែង។

ប្រភពដែលគួរឱ្យទុកចិត្តបានតែមួយអំពីប្រជាពលរដ្ឋ (ការចុះបញ្ជីពលរដ្ឋ - Population Registry) ត្រូវតែបង្កើតឡើងតាមរយៈការអនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ នេះ ដែលទិន្នន័យជាមូលដ្ឋានស្តីពីបុគ្គលនឹងត្រូវផ្ទុកនិងអាចរកបានសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើអត្តសញ្ញាណបុគ្គល និងជាកន្លែងថែរក្សាព័ត៌មានអំពីប្រជាពលរដ្ឋតាមរយៈប្រព័ន្ធផ្សព្វផ្សាយទិន្នន័យ។ ច្បាប់នានាត្រូវតែមានការត្រួតពិនិត្យឡើងវិញ ជាមួយនឹងការរៀបចំឱ្យមាននីតិវិធី និងដំណើរការដ៏តឹងរឹង និងច្បាស់លាស់បំផុតសម្រាប់អ្នកចូលមកប្រើប្រាស់ព័ត៌មាននៅក្នុងបញ្ជីពលរដ្ឋដើម្បីធានាការការពារសិទ្ធិ និងភាពឯកជន។

ត្រូវតែប្រើប្រាស់នូវបច្ចេកវិទ្យាទំនើប រួមជាមួយនឹងវិធីសាស្ត្រច្បាស់លាស់ ទើបអាចជំនះបាននូវបញ្ហាផ្នែកបច្ចេកទេស និងភស្តុភារ ក្នុងការប្រមូលផ្តុំ និងការធានាគុណភាពនៃព័ត៌មានពេញលេញ និងជឿទុកចិត្តបានអំពីព្រឹត្តិការណ៍ជីវិត និងអំពីប្រជាពលរដ្ឋ។

ការផលិត ការផ្សព្វផ្សាយ និងការប្រើប្រាស់ស្ថិតិអត្រានុកូលដ្ឋាន និងព័ត៌មានអំពីប្រជាពលរដ្ឋត្រូវបរិយាយជាសកម្មភាពនានាដូចខាងក្រោម ៖

(ក). ត្រូវរៀបចំការកសាងសមត្ថភាព និងការអនុវត្តលើផ្នែកស្ថិតិអត្រានុកូលដ្ឋាន តាមរយៈការបង្កើតឱ្យមានអង្គភាពដែលបំពេញមុខងារក្នុងការទទួលខុសត្រូវការងារប្រមូល វិភាគ និងផ្សព្វផ្សាយព័ត៌មានដែលគួរឱ្យទុកចិត្តបានអំពីព្រឹត្តិការណ៍រស់នៅ។

(ខ). ត្រូវលើកកម្ពស់ការប្រើប្រាស់ស្ថិតិអត្រានុកូលដ្ឋាន ក្នុងគោលដៅជួយគាំទ្រដល់ការសម្រេចចិត្តនៅក្នុងវិស័យសង្គម គោលនយោបាយសេដ្ឋកិច្ច និងសុខាភិបាល ព្រមទាំងការតាមដានការរីកចម្រើនឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ដែលបានយល់ព្រមព្រៀងនៅថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

(គ). ការប្រើប្រាស់ប្រព័ន្ធ ប.វ.គ.ព.(ICT) នៅក្នុងការចុះបញ្ជីព្រឹត្តិការណ៍ជីវិតនេះនឹងជួយពន្លឿនដល់ការប្រមូលផ្តុំព័ត៌មាន ការវិភាគ និងការបោះពុម្ពផ្សាយស្ថិតិអត្រានុកូលដ្ឋាន ដែលកើតចេញមកពីការចុះបញ្ជីអត្រានុកូលដ្ឋាន។

(ឃ).ស្ថិតិអត្រានុកូលដ្ឋាននឹងត្រូវផ្តល់ទៅឱ្យវិទ្យាស្ថានជាតិស្ថិតិ ព្រមទាំងអាចឱ្យអ្នកប្រើប្រាស់អាចស្វែងរកទិន្នន័យនេះបានតាមរយៈការបោះពុម្ពផ្សាយស្ថិតិអត្រានុកូលដ្ឋាននៅលើប្រព័ន្ធអ៊ីនធឺណែត។

(ង). ត្រូវធ្វើការកសាងសមត្ថភាពដល់វិស័យសាធារណៈ និងឯកជននានា ដើម្បីអាចប្រើប្រាស់ប្រព័ន្ធនេះសម្រាប់ធ្វើការផ្ទៀងផ្ទាត់ព័ត៌មានបុគ្គល និងទទួលបានព័ត៌មានប្រជាពលរដ្ឋតាមរយៈប្រព័ន្ធផ្សព្វផ្សាយទិន្នន័យ។

(ច). បញ្ជីប្រជាពលរដ្ឋ នឹងក្លាយទៅជាប្រភពនៃព័ត៌មានប្រជាពលរដ្ឋដែលគួរឱ្យទុកចិត្តបានតែមួយគត់ ហើយត្រូវតែពង្រីកការយល់ដឹង និងចំណេះដឹងអំពីការចុះបញ្ជីនេះនៅក្នុងចំណោមអតិថិជនដែលមានសក្តានុពល ទាំងក្នុងវិស័យសាធារណៈ និងឯកជន។

(ឆ). ត្រូវរៀបចំឡើងនូវច្បាប់ គោលការណ៍ណែនាំស្តីពីការផ្តល់សេវា និងនីតិវិធីនានា ដោយធ្វើការកំណត់ឱ្យបានច្បាស់លាស់អំពីការប្រើប្រាស់ទិន្នន័យនៃការចុះបញ្ជីប្រជាពលរដ្ឋ តាមរយៈប្រព័ន្ធផ្សព្វផ្សាយទិន្នន័យ។

(ជ). ត្រូវធ្វើការពង្រីកសមត្ថភាពរបស់មន្ត្រីដែលត្រូវចូលរួមដោយផ្ទាល់នៅក្នុងដំណើរការគ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន។

## V. គោលបំណងយុទ្ធសាស្ត្រ

គោលបំណង គឺជាទិសដៅបែបយុទ្ធសាស្ត្រដែលទាមទារឱ្យមានការកំណត់ពេលវេលា និងជំហានអនុវត្តជាក់លាក់។ គោលបំណងយុទ្ធសាស្ត្រនេះមានលក្ខណៈដាច់ដោយឡែកពីគ្នា ប៉ុន្តែការអនុវត្តគោលបំណងទាំងនេះនឹងត្រូវពឹងផ្អែកលើការអភិវឌ្ឍនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ដែលប្រកបដោយមុខងារដំណើរការល្អ មានភាពជឿទុកចិត្តបាន និងមានលក្ខណៈជាសកលនៅក្នុងប្រទេសកម្ពុជា។ គោលបំណងខាងក្រោមនេះត្រូវតែសម្រេចឱ្យបានក្នុងអំឡុងពេលនៃការអនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ មានជាអាទិ៍ ៖

### ១. *រៀបចំក្របខ័ណ្ឌច្បាប់សម្រាប់កំណត់អត្តសញ្ញាណបុគ្គល*

រាជរដ្ឋាភិបាលបានបន្ថែមនូវកាតព្វកិច្ចដ៏ជាក់លាក់ទាក់ទងជាមួយនឹងបញ្ហាសិទ្ធិមនុស្សដូចដែលមានបញ្ជាក់ជាមូលដ្ឋាននៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងស្របជាមួយនឹងច្បាប់អន្តរជាតិផ្សេងៗទៀតដែលប្រទេសកម្ពុជាមានកាតព្វកិច្ចអនុវត្ត។ សិទ្ធិមនុស្សជាមូលដ្ឋានមួយក្នុងចំណោមសិទ្ធិជាច្រើនដែលទាក់ទងជាមួយនឹងការទទួលស្គាល់ និងការកំណត់អត្តសញ្ញាណក្នុងនាមជាបុគ្គលម្នាក់ៗ។ យោងតាមច្បាប់ និងការអនុវត្តជាលក្ខណៈអន្តរជាតិ សិទ្ធិមនុស្សគឺត្រូវបានកើតឡើងជាដំបូង និងមានសារៈសំខាន់បំផុត តាមរយៈការចុះបញ្ជីកំណើត។ ការចុះបញ្ជីកំណើតនេះ នឹងបង្កើតបានជាមូលដ្ឋានមួយសម្រាប់អត្តសញ្ញាណរបស់បុគ្គលដែលមានបង្ហាញតាមរយៈសំបុត្រកំណើត។

ច្បាប់បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ត្រូវបានគេមើលឃើញថា នៅមិនទាន់គ្រប់គ្រាន់នៅឡើយសម្រាប់ជាមូលដ្ឋាននៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានទំនើបតាមកុំព្យូទ័រ និងការងារអត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋានតាមប្រព័ន្ធទំនើបនៅឡើយ។ រាជរដ្ឋាភិបាលបានទទួលស្គាល់អំពីតម្រូវការជាបន្ទាន់នៃការកែទម្រង់ដ៏ទូលំទូលាយមួយលើផ្នែកច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។

ដោយយល់ឃើញថាតួនាទីនៃក្របខ័ណ្ឌច្បាប់គឺជាមូលដ្ឋានសម្រាប់ចុះអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាបានខំប្រឹងប្រែងក្នុងការនាំយកមកនូវក្របខ័ណ្ឌច្បាប់ដែលមានលក្ខណៈទាន់សម័យ និងអាចឆ្លើយតបបានពេញលេញទៅតាមតម្រូវការ និងការចង់បានរបស់ខ្លួន ព្រមទាំងស្របទៅនឹងប្រព័ន្ធផ្សេងៗនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងច្បាប់អន្តរជាតិនានាដែលប្រទេសកម្ពុជាបានប្តេជ្ញាចិត្តអនុវត្តតាម ហើយកិច្ចការទាំងអស់នេះនឹងត្រូវការធនធានជាច្រើន។ ដូច្នេះ តម្រូវការដែលមិនសូវមានភាពធ្ងន់ធ្ងរនោះ គឺការអនុម័តច្បាប់ថ្មីស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន ជាជាងការពិនិត្យទៅលើច្បាប់ទាំងអស់ដែលកំពុងតែអនុវត្តក្នុងពេលបច្ចុប្បន្ន ឬជាជាងការទៅធ្វើបច្ចុប្បន្នភាពទៅលើ ឬក៏បង្រួមច្បាប់ទាំងអស់នោះ។ ប៉ុន្តែ នេះមិនមែនមានន័យថា កិច្ចខិតខំប្រឹងប្រែងដែលបានធ្វើរួចមកហើយនោះត្រូវចាត់ទុកជាមោឃៈ ដោយសារតែច្បាប់ទាំងនោះបានកើតឡើងមុនការធ្វើកំណែទម្រង់មួយនេះនោះទេ។ ការអនុម័តច្បាប់ថ្មីនេះឡើង ក៏ជាប្រការល្អមួយដែលធ្វើឱ្យសាធារណៈជនបានដឹង និងមើលឃើញអំពីសារៈសំខាន់នៃអត្រានុកូលដ្ឋានដែលជាផ្នែកមួយនៃការរៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹងផងដែរ។

យោងតាមអនុសាសន៍នៃ ផ.យ.ជ.អ. ២០១៥-២០២៤ នេះ ក្របខ័ណ្ឌច្បាប់គួរតែរៀបចំតាមជំហាននានាដូចខាងក្រោម ៖

- រៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន និងសេចក្តីព្រាងអនុក្រឹត្យ ព្រមទាំងធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តនានានៃក្របខ័ណ្ឌច្បាប់មួយចំនួនដែលនឹងមានអន្តរកម្មជាមួយប្រព័ន្ធចុះអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋាន និង ប.រ.អ.ព.(IPIS) ព្រមទាំងប្រតិបត្តិការរបស់ ប.រ.អ.ព.(IPIS) ដូចមានរៀបរាប់នៅក្នុងគោលបំណងទី៣។

## ២. បង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋានដោយផ្អែកទៅលើប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន មានលក្ខណៈជាសកល និងមានការឆ្លើយតប

គោលបំណងទី២សំដៅទៅលើតួនាទីយ៉ាងសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាននៅក្នុងប្រទេសកម្ពុជា និងឆ្លុះបញ្ចាំងអំពីសេចក្តីសម្រេចដែលត្រូវបានអនុម័តដោយគណៈកម្មការសេដ្ឋកិច្ច និងសង្គមសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក កាលពីឆ្នាំ២០១៤។ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋានដែលមានលក្ខណៈជាសកល និងមានការឆ្លើយតបដែលអាចជួយដល់ការគោរពសិទ្ធិមនុស្ស និងគាំទ្រដល់អភិបាលកិច្ចល្អ និងជានាឱ្យមានការអភិវឌ្ឍមួយដែលមានលក្ខណៈប្រមូលផ្តុំ មានសមធម៌ និងផ្តោតទៅលើមនុស្ស គួរតែត្រូវបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាហើយដែលអាចអនុវត្តបានដូចខាងក្រោម ៖

- ផ្តល់ឯកសារ និងកំណត់ត្រាអចិន្ត្រៃយ៍មួយសម្រាប់បុគ្គល ដើម្បីបង្កើតនូវអត្តសញ្ញាណផ្លូវច្បាប់នៃស្ថានភាពពលរដ្ឋ និងទំនាក់ទំនងគ្រួសារ ថែមទាំងជួយលើកកម្ពស់ការការពារផ្នែកសង្គម និងការបង្កលក្ខណៈងាយស្រួលដល់ការទទួលបាននូវសេវាសំខាន់ៗដូចជា សេវាអប់រំ ថែទាំសុខភាព និងសេវាផ្សេងៗទៀត។
- ជំរុញឱ្យមានអភិបាលកិច្ចល្អ និងពង្រឹងរដ្ឋបាលសាធារណៈតាមរយៈការចូលរួមផ្នែកនយោបាយ និងគណនេយ្យភាពកាន់តែប្រសើរជាងមុន ព្រមទាំងបង្កើតឱ្យមានតម្រូវការប្រើប្រាស់ទិន្នន័យប្រជាពលរដ្ឋកម្មវិធីអត្តសញ្ញាណកម្មជាតិ និងអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិច ដើម្បីជួយសម្រួលដល់ការផ្តល់សេវាសាធារណៈ។
- ផ្តល់ស្ថិតិអត្រានុកូលដ្ឋានអំពីប្រជាសាស្ត្រ និងសុខភាពពលរដ្ឋ និងព័ត៌មានផ្សេងៗទៀតដែលផ្តល់កស្តុតាងជាមូលដ្ឋានមួយសម្រាប់ការធ្វើគោលនយោបាយនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ដោយរួមបញ្ចូលទាំងអន្តរាគមន៍ការពារក្រុមគោលដៅនានា ដើម្បីជួយដោះស្រាយបញ្ហាវិសមភាពសង្គម សេដ្ឋកិច្ច និងសុខាភិបាល ជាពិសេស សហគមន៍នៅតំបន់ដាច់ស្រយាល ជនបាត់បង់លទ្ធភាពពលកម្ម និងក្រុមជនដែលត្រូវបានការយកចិត្តទុកដាក់តិចតួច។
- ជួយជំរុញការអនុវត្តសេវាគ្របដណ្តប់ផ្នែកសុខាភិបាលដែលមានលក្ខណៈសកល និងផ្តល់នូវទិន្នន័យដែលគួរឱ្យទុកចិត្តបំផុតដើម្បីតាមដាន និងដោះស្រាយបញ្ហាមរណភាពមាតា ដោយរួមបញ្ចូលទាំងការផ្តល់នូវទិន្នន័យមូលដ្ឋានសម្រាប់រៀបចំវិធានការក្នុងការលើកកម្ពស់សុខភាពទារកទើបកើត កុមារ និងសុខភាពមាតា។

- លើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងសិទ្ធិអំណាចដល់ស្ត្រី និងកុមារី តាមរយៈការផ្តល់នូវឯកសារបញ្ជាក់ពីទំនាក់ទំនងគ្រួសារ និងស្ថានភាពពលរដ្ឋ ព្រមទាំងផលិតស្ថិតិដែលមានការបែងចែកតាមអាយុ ភេទ និងទីតាំងភូមិសាស្ត្រជាដើម។
- ទប់ស្កាត់ និងកាត់បន្ថយហានិភ័យនៃភាពគ្មានរដ្ឋ ការជួញដូរមនុស្ស អាពាហ៍ពិពាហ៍កុមារ ឬអាពាហ៍ពិពាហ៍នៅវ័យក្មេង ពលកម្មកុមារ។ល។ ព្រមទាំងលើកកម្ពស់ដំណោះស្រាយសម្រាប់ជនភៀសខ្លួនជាប្រចាំ ដោយការរៀបចំឯកសារនានាឱ្យភ្ជាប់ទៅនឹងប្រទេសដើមរបស់ពួកគេ។
- ផ្តល់នូវព័ត៌មានសម្រាប់ការធ្វើផែនការផ្នែកមនុស្សធម៌ ការកាត់បន្ថយ និងគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ និងការផ្តល់ជំនួយដល់ការឆ្លើយតបទៅនឹងគ្រោះមហន្តរាយទាំងឡាយ។

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋានដែលមានលក្ខណៈជាសកល និងមានការឆ្លើយតប ត្រូវរៀបចំឡើងដោយអាចដំណើរការបានជាមួយប្រព័ន្ធវេបសាយ (Web-enabled) សម្រាប់ដាក់ឱ្យចុះបញ្ជីបានដូចៗគ្នានៅតាមថ្នាក់ឃុំ សង្កាត់ទាំងអស់។ ដោយបានពិចារណាក្នុងការតម្រឹមការងារអត្តសញ្ញាណកម្មឱ្យស្របតាមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើវិមជ្ឈការអំណាច និងការលើកកម្ពស់សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនោះ វិធីសាស្ត្របែបវិមជ្ឈការក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន និងការងារអត្តសញ្ញាណកម្មត្រូវតែរក្សាការអនុវត្តតាមរបៀបនេះដដែល ដោយគ្រាន់តែបន្ថែមកិច្ចខិតខំប្រឹងប្រែងកសាងសម្ថភាព និងពង្រឹងការប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រតែប៉ុណ្ណោះ។

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែលមានលក្ខណៈជាសកល និងមានការឆ្លើយតប ត្រូវតែមានប្រព័ន្ធទិន្នន័យព័ត៌មានអត្រានុកូលដ្ឋានជាតិមួយរបស់ព្រះរាជាណាចក្រកម្ពុជា ដោយធ្វើទំនើបកម្មការងារចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធកុំព្យូទ័រ ដែលអាចប្រមូល ស្តុកទុក និងបង្កើតព័ត៌មានស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានបាននៅទូទាំងប្រទេស ព្រមទាំងមានលទ្ធភាពផ្តល់ព័ត៌មានអំពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានទៅដល់ស្ថាប័នរបស់រាជរដ្ឋាភិបាលនានា និងអង្គភាពមានសមត្ថកិច្ចផ្សេងៗទៀត។

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន គួរតែមានការឆ្លើយតបតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងធានាឱ្យបាននូវប្រការមួយចំនួនដូចខាងក្រោមនេះ ៖

- សេវាចុះបញ្ជីអត្រានុកូលដ្ឋានត្រូវអនុវត្តឱ្យបានដូចៗគ្នានៅតាមសាលាឃុំ សង្កាត់ ទាំង១៦៣៣ នៅទូទាំងប្រទេស ដោយធានាមិនឱ្យមានភាពខុសគ្នានៅតាមឃុំ សង្កាត់ណាមួយឡើយ។
- ការបង្កើត និងការផ្តល់លេខកូដអត្តសញ្ញាណខ្មែរ (ល.ក.អ.ខ. KIDC) (ដែលផ្តល់ដោយប្រព័ន្ធរួមអត្តសញ្ញាណកម្មពលរដ្ឋ (ប.រ.អ.ព.) នៅពេលចុះបញ្ជីកំណើត។
- សេវាត្រូវធ្វើឡើងតាមប្រព័ន្ធវេបសាយ និងដោយពឹងផ្អែកទៅឧបករណ៍ចល័តដោយភ្ជាប់អ៊ីនធឺណែត (ទូរស័ព្ទដៃ ឬ Tablet) សម្រាប់ការបញ្ជូនទិន្នន័យ និងការស្នើសុំការចុះបញ្ជី។
- ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានជាតិដែលមានទៅដោយមន្ត្រីអត្រានុកូលដ្ឋានដែលមានសុពលភាពផ្នែកច្បាប់ នឹងត្រូវប្រតិបត្តិការតាមលក្ខណៈបច្ចេកទេសនៅថ្នាក់ជាតិ។
- លើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃនីតិវិធីក្នុងការចុះបញ្ជី និងកាត់បន្ថយនូវហានិភ័យនៃការធ្វើអត្តសញ្ញាណស្ទួន។

- ជំរុញឱ្យមានតម្រូវការពាក់ព័ន្ធនឹងអត្ថប្រយោជន៍ដល់វិស័យសាធារណៈ និងវិស័យឯកជន។
- លើកកម្ពស់ការយល់ដឹង និងសកម្មភាពផ្សព្វផ្សាយ ដើម្បីជូនដំណឹង និងកសាងសមត្ថភាពអំពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។
- គាំទ្រដោយបណ្តាញអ្នកជូនដំណឹង (Informants) ផ្លូវការ និងមិនផ្លូវការ។
- ត្រូវមានការកែលម្អជាប្រចាំដោយផ្អែកទៅលើមតិយោបល់ត្រលប់ពីប្រជាពលរដ្ឋ។

ទស្សនទាននៃការរៀបចំប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន យ៉ាងហោចណាស់ត្រូវមានសមាសធាតុនៃសេវាកម្មធំៗចំនួន៤ គឺ ៖

- **សេវាផ្តល់ដំណឹង ៖** សេវានេះដោះស្រាយលើការជូនដំណឹងដែលទទួលបានមកពីអាជ្ញាធរដែលបានឃើញការកើតឡើងនៃព្រឹត្តិការណ៍ជីវិត។ ការជូនដំណឹងត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និងផ្ទុកទិន្នន័យនោះទុករហូតដល់ឪពុកម្តាយ ឬអាណាព្យាលមកដាក់ពាក្យសុំដោយនាំយកមកជាមួយនូវឯកសារសំណៅដើម ហើយស្នើសុំចុះបញ្ជីទៅលើព្រឹត្តិការណ៍ជីវិតនោះ។
- **សេវាចុះបញ្ជី ៖** សេវានេះដោះស្រាយលើការប្រមូលសំណុំឯកសារនៃការដាក់ពាក្យសុំចុះបញ្ជីព្រឹត្តិការណ៍ជីវិត ដោះស្រាយលើការបញ្ចូលទិន្នន័យ និងការដាក់បញ្ចូលនូវឯកសារឧបសម្ព័ន្ធ ការថតចម្លង រឺក៏ scan ក៏ដូចជាដំណើរការផ្ទៀងផ្ទាត់ទិន្នន័យ ដំណើរការអនុម័តទៅលើការចុះបញ្ជី និងការចេញលិខិតចុះបញ្ជី។ តាមរយៈប្រព័ន្ធអ៊ីនធឺណែត ការិយាល័យចុះបញ្ជីនៅថ្នាក់ឃុំ សង្កាត់ទាំង ១៦៣៣ កន្លែង ត្រូវតភ្ជាប់ទៅនឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដើម្បីបំពេញមុខងារចុះបញ្ជី។ ល.ក.អ.ខ. (KIDC) ដែលត្រូវបានផ្តល់ជូនបន្ទាប់ពីមានការសម្រេចយល់ព្រមចំពោះពាក្យសុំចុះបញ្ជីព្រឹត្តិការណ៍កំណើតនោះ។ មន្ត្រីអត្រានុកូលដ្ឋានអាចបដិសេធការស្នើសុំចុះបញ្ជីបាន ប្រសិនបើរកឃើញថាឯកសារណាមួយត្រូវបានធ្វើឡើងដោយវិធីមិនស្របច្បាប់។ សេចក្តីសម្រេចចិត្តនៅក្នុងការបដិសេធ និងហេតុផលនៃការសម្រេចចិត្តនេះ គឺត្រូវផ្អែកទៅលើប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ហើយត្រូវកត់ត្រាចូលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននេះ។ សេចក្តីសម្រេចចិត្តនេះត្រូវតែបោះពុម្ពចេញមកលើក្រដាស។
- **សេវាផ្តល់ព័ត៌មាន ៖** សេវានេះដោះស្រាយលើសំណើសុំព័ត៌មាន ដែលស្នើឡើងដោយអ្នកប្រើប្រាស់ក្នុងផ្នែកសាធារណៈ តាមរយៈសេវាកម្មព័ត៌មានពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។ សំណូមពរនេះនឹងត្រូវបានទទួលយកដោយដៃ (នៅលើក្រដាស) ឬតាមរយៈប្រព័ន្ធអ៊ីនធឺណែត។ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននឹងមានលទ្ធភាពជូនដំណឹងបានគ្រប់គ្រាន់អំពីព្រឹត្តិការណ៍ជីវិតដល់ស្ថាប័ននានា ស្របតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការដែលមានចុះហត្ថលេខា។ ការជូនដំណឹងអាចត្រូវធ្វើឡើងតាមរយៈច្រកជូនដំណឹងដែលត្រូវបានកំណត់ច្បាស់លាស់។
- **សេវាស្ថិតិអត្រានុកូលដ្ឋាន ៖** សេវានេះដោះស្រាយអំពីការបង្កើតព័ត៌មានដោយយោងទៅតាមតារាងផែនការស្ថិតិអត្រានុកូលដ្ឋាន ដែលក្រោយមកនឹងត្រូវបានផ្សព្វផ្សាយតាមប្រព័ន្ធអ៊ីនធឺណែត សម្រាប់សាធារណជនស្វែងរក។

ប្រព័ន្ធចុះបញ្ជីអគ្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន នឹងត្រូវភ្ជាប់ជាមួយ ប.រ.អ.ព.(IPIS) ដោយផ្អែកលើមូលដ្ឋានពីប្រព័ន្ធទៅប្រព័ន្ធ ស្របទៅតាមការរៀបចំលក្ខណៈបច្ចេកទេសលម្អិត និងដែលបានផ្តល់ឱ្យរួមគ្នាជាមួយនឹងប្រព័ន្ធអត្តសញ្ញាណប្រជាពលរដ្ឋនេះ។




*រូបភាពទី១ ទស្សនទាននៃការរៀបចំប្រព័ន្ធអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋាននៅកម្ពុជា*

## ៣. បង្កើតប្រព័ន្ធរួមអត្តសញ្ញាណកម្មពលរដ្ឋ

គោលបំណងទី៣គឺដើម្បីដោះស្រាយនូវតម្រូវការបង្កើតឡើងព័ត៌មានប្រជាពលរដ្ឋ និងអត្តសញ្ញាណពិសេស ដែលអាចជឿទុកចិត្តបានសម្រាប់មនុស្សទាំងអស់នៅក្នុងប្រទេសកម្ពុជា។ ប្រព័ន្ធកំណត់អត្តសញ្ញាណពលរដ្ឋ ដែលមានលក្ខណៈរួម ត្រូវតែបង្កើតឡើងដើម្បីបម្រើជាកន្លែងប្រមូលផ្តុំព័ត៌មានពលរដ្ឋមួយសម្រាប់ស្ថាប័នផ្សេងៗ និងសម្រាប់ប្រព័ន្ធរបស់ស្ថាប័ននោះប្រើប្រាស់ជាប្រភពទិន្នន័យចម្បង និងតែមួយគត់។

បណ្តុំទិន្នន័យជាអប្បបរមានៃព័ត៌មានស្តីពីបុគ្គលត្រូវតែបានកំណត់ និងស្តុកទុកនៅទីតាំងកណ្តាលមួយនៃ ប.រ.អ.ព.(IPIS) (បញ្ជីពលរដ្ឋ) ដែលរួមមាន ៖ នាម គោត្តនាម ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត សញ្ជាតិ ភាពជាពលរដ្ឋ ស្ថានភាពអាពាហ៍ពិពាហ៍ ឈ្មោះឪពុក ម្តាយ កូន អសយដ្ឋាន ទីសំណាក់ និងទិន្នន័យអំពីឯកសារ អត្តសញ្ញាណកម្មនានាដែលបានចេញឱ្យដោយអាជ្ញាធរ។ ទិន្នន័យនៅក្នុងបញ្ជីពលរដ្ឋគឺត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ (ជាការល្អត្រូវធ្វើគ្រប់ពេលវេលា) ពីប្រព័ន្ធដទៃទៀត។ ព័ត៌មានផ្សេងទៀតដែលទាក់ទងជាមួយនឹងអត្តសញ្ញាណរបស់បុគ្គល គឺព័ត៌មានជីវសាស្ត្រ (ដូចជាទិន្នន័យខ្ចៅដៃ រូបថតជាដើម) ត្រូវតែបន្តស្តុកទុក និងរក្សាទុកនៅក្នុងប្រព័ន្ធព័ត៌មានដើម ដោយមិនចាំបាច់យកមកបញ្ចូលក្នុងប្រព័ន្ធទិន្នន័យកណ្តាលរបស់ ប.រ.អ.ព.(IPIS) ឡើយ លើកលែងតែមានការកំណត់ផ្សេងពីនេះនៅក្នុងក្របខ័ណ្ឌច្បាប់។

ប្រព័ន្ធកុំព្យូទ័រដែលមានស្រាប់ និងប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធនឹងការងារអត្តសញ្ញាណកម្មដែលនឹងត្រូវបង្កើតឡើង ត្រូវតែភ្ជាប់ទំនាក់ទំនងបញ្ចូលគ្នាទៅក្នុង ប.រ.អ.ព.(IPIS) នៅលើមូលដ្ឋានពីប្រព័ន្ធមួយទៅប្រព័ន្ធមួយ នៅក្នុងគោលបំណងធានាឱ្យមានលទ្ធភាពនៅក្នុងការស្វែងរកព័ត៌មានត្រឹមត្រូវ និងពិតប្រាកដអំពីបុគ្គល។ ប្រព័ន្ធទាំងនោះរួមមាន ៖

- ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន
- ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅ
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យសញ្ជាតិ
- ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។

ទស្សនទាននៃការរៀបចំ ប.រ.អ.ព.(IPIS) ដែលមានលក្ខណៈរួមពីប្រព័ន្ធទាំងអស់ដែលមានការពាក់ព័ន្ធនៅក្នុងការកត់ត្រាជាបន្តបន្ទាប់នៃព័ត៌មានដែលទាក់ទងជាមួយនឹងសមាជិកគ្រួសារនីមួយៗ នៃប្រជាជនដែលរស់នៅក្នុងប្រទេស នឹងធ្វើឱ្យយើងអាចកំណត់បាននូវព័ត៌មានបច្ចុប្បន្នភាពអំពីទំហំ និងលក្ខណៈនៃប្រជាពលរដ្ឋនៅក្នុងទីតាំងជ្រើសរើសណាមួយ និងនៅក្នុងពេលវេលាណាមួយបាន។ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដើរតួនាទីជាចំណុចចាប់ផ្តើមដំបូងមួយដែលកំណត់ត្រាថ្មីៗរបស់បុគ្គលដែលត្រូវបង្កើតឡើងនៅក្នុង ប.រ.អ.ព.(IPIS) ហើយនឹងមានការបង្កើត និងផ្តល់ ល.ក.អ.ខ.(KIDC) មួយផងដែរ។

ល.ក.អ.ខ.(KIDC) នឹងត្រូវបង្កើតឡើងដោយ ប.រ.អ.ព.(IPIS) ហើយត្រូវផ្តល់ឱ្យបុគ្គលគ្រប់រូបនៅក្នុងប្រព័ន្ធនេះ ។ លេខកូដនេះត្រូវមានចំនួនដប់ខ្ទង់ ដែលត្រូវបានបង្កើតឡើងដោយរបៀបចៃដន្យ ក្នុងនោះ មួយខ្ទង់ជាលេខបម្រុង ប្រាំបីខ្ទង់ជាលេខកំណត់ដោយចៃដន្យ និងចំនួនមួយខ្ទង់ទៀតជាលេខផ្ទៀងផ្ទាត់ (checksum)

ដោយផ្អែកលើរូបមន្ត Modoul11 Alcorate។ លេខបម្រុង (Reserve digit) ដែលគេបានជ្រើសរើសកំណត់ឡើងនេះនឹងត្រូវប្រើដើម្បីបែងចែកការរស់នៅជាបណ្តោះអាសន្ន និងជនបរទេសដែលកំពុងធ្វើការនៅកម្ពុជា ឱ្យដាច់ពីពលរដ្ឋនៃប្រទេសកម្ពុជា។

ល.ក.អ.ខ.(KIDC) ត្រូវតែបង្កើតឱ្យតែមួយគត់ គឺនៅពេលចុះបញ្ជីកំណើត ហើយត្រូវតែរក្សាលេខដដែលនេះពេញមួយជីវិតរបស់មនុស្សម្នាក់ៗ។ អញ្ញត្រកម្មចំពោះការបង្កើត ល.ក.អ.ខ.(KIDC) ត្រូវកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ លេខនេះត្រូវតែជាលេខពិសេសមួយនៅថ្នាក់ជាតិ ហើយមិនអាចត្រូវបានគេប្រើប្រាស់ឡើងវិញជាដាច់ខាត ទោះជានៅក្នុងកាលៈទេសៈណាក៏ដោយ។ របៀបនៃការដាក់លេខកូដនេះធ្វើឡើងក្នុងគោលបំណងបញ្ចៀសការផ្ទុកនូវព័ត៌មានរសើបរបស់បុគ្គល ដែលអាចពាក់ព័ន្ធដល់លទ្ធភាពនៃការផ្លាស់ប្តូរស្ថានភាពជីវិតបុគ្គលម្នាក់ៗ ជាអាទិ៍ ការពារនូវរាល់ទម្រង់នៃការរើសអើងជាដើម។ ហេតុដូច្នេះ លេខនេះគឺជាលេខដែលកើតឡើង ឬក៏កំណត់ឡើងដោយរបៀបចៃដន្យសុទ្ធសាធ និងមិនអាចទស្សនទាយបានឡើយ។

ព័ត៌មានអំពីបុគ្គលនៅក្នុង ប.រ.អ.ព.(IPIS) ត្រូវតែធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ដោយប្រព័ន្ធគាំទ្របន្ថែមទៀត មានដូចជា ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋាន ប្រព័ន្ធចុះបញ្ជីការស្នាក់នៅ ប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ប្រព័ន្ធលិខិតឆ្លងដែន និងប្រព័ន្ធស្តីពីសញ្ជាតិ។




*រូបភាពទី២ ទស្សនទាននៃការរៀបចំ ប្រព័ន្ធរួមអត្តសញ្ញាណពលរដ្ឋ (IPIS) នៅកម្ពុជា*

ប្រព័ន្ធព័ត៌មានប្រជាពលរដ្ឋនេះនឹងជំរុញឱ្យស្ថាប័នផ្សេងៗអាចទទួលបាននូវព័ត៌មានដូចគ្នាៗអំពីបុគ្គល និង អាចស្វែងរក និងរួមចំណែកក្នុងការធ្វើបច្ចុប្បន្នភាពទៅលើព័ត៌មានបុគ្គល។ ប.រ.អ.ព.(IPIS) គួរតែជានាំអំពីការ បញ្ចេញព័ត៌មានប្រកបដោយសុវត្ថិភាពទៅដល់អ្នកទទួលព័ត៌មានដែលមានសមត្ថកិច្ចលើព័ត៌មានទាំងអស់នោះ ហេតុដូច្នេះហើយវាគួរតែភ្ជាប់ជាមួយនឹងប្រព័ន្ធបែងចែកព័ត៌មាន។

## ៤. ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឯកភាពបែងចែកទិន្នន័យពលរដ្ឋ

គោលបំណងទី៤ គឺដោះស្រាយអំពីតម្រូវការរបស់ភាគីពាក់ព័ន្ធក្នុងការទទួលបានទិន្នន័យអំពីប្រជាពលរដ្ឋ ដែលគួរឱ្យទុកចិត្តបំផុតនៅក្នុងប្រទេសកម្ពុជា។ គោលបំណងនេះមានចេតនាបង្កើតនូវប្រព័ន្ធមួយទៀតដែលមាន មុខងារបញ្ចេញព័ត៌មានដ៏មានប្រសិទ្ធភាព ដែលព័ត៌មានទាំងនោះបានប្រមូលផ្តុំមកពីគ្រប់ប្រព័ន្ធរងផ្សេងៗទៀត របស់ ប.រ.អ.ព.(IPIS) នៅក្នុងមណ្ឌលបែងចែកព័ត៌មានកណ្តាលដែលមានលក្ខណៈឯកភាពមួយ។

ប្រព័ន្ធបែងចែកទិន្នន័យត្រូវគ្របដណ្តប់ទៅលើមូលដ្ឋានទិន្នន័យពលរដ្ឋ ដែលទិន្នន័យនោះគឺជាទិន្នន័យ ចម្លង (Replicated Data) ចេញពីការចុះបញ្ជីពលរដ្ឋ (Population Registry) នៃប្រទេសកម្ពុជា និងធ្វើឱ្យ ទិន្នន័យទាំងអស់នោះអាចស្វែងរកបានយ៉ាងឆាប់រហ័ស ឬអាចផ្ទៀងផ្ទាត់ទៅលើអត្តសញ្ញាណ ក៏ដូចជាការធ្វើ របាយការណ៍សេវាកម្មផ្សេងៗ។ ប្រព័ន្ធនេះនឹងជួយដល់ការគ្រប់គ្រងអ្នកប្រើប្រាស់ (User Management) ហើយនិងមានមុខងារខ្ពស់អាចតាមដានគ្រប់ពេលវាលា និងអាចធ្វើសវនកម្មទៅលើដំណើរការស្វែងរកព័ត៌មាន បានគ្រប់ពេលវេលា។ ប្រការនេះនឹងជួយធានាពង្រឹងសុវត្ថិភាពចំពោះអ្នកប្រើប្រាស់ដែលមានការអនុញ្ញាត (Authorized User) និងការសម្ងាត់នៃទិន្នន័យទាំងអស់ ក៏ដូចជាជួយឱ្យគ្រប់គ្រងបាននូវការកត់ត្រាចំនួននៃការ ផ្ទៀងផ្ទាត់ទិន្នន័យនៅក្នុងគណនីអ្នកប្រើប្រាស់នីមួយៗសម្រាប់ជានាគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ។

ដើម្បីសម្រេចបានគោលបំណងនេះ តម្រូវឱ្យមានការអនុវត្តបែបបច្ចេកទេសនៅលើប្រព័ន្ធបែងចែកទិន្នន័យ នេះ ជាមួយនឹងការកិច្ចខិតខំប្រឹងប្រែងដ៏សម្បើមនៅក្នុងការគ្រប់គ្រងភាគីពាក់ព័ន្ធ ការគ្រប់គ្រងកិច្ចសន្យា ការ លើកកម្ពស់ការយល់ដឹង និងការបណ្តុះបណ្តាលជាដើម។

## ៥. កែសម្រួលរបៀបរបបការងារ និងដាក់ឱ្យដំណើរការប្រព័ន្ធអេឡិចត្រូនិកសម្រាប់ផ្តល់សេវា ជូនអតិថិជនប្រកបដោយប្រសិទ្ធភាព និងតម្លាភាព

គោលបំណងទី៥គឺដើម្បីដោះស្រាយអំពីតម្រូវការនៃការកែលម្អការផ្តល់សេវាកម្មតាមរយៈការពង្រឹង និងការ កែសម្រួលរបៀបរបបការងារតាមវិធីសាស្ត្រដែលផ្តោតទៅលើអតិថិជន ជាមួយនឹងការដាក់ឱ្យដំណើរការសេវាកម្ម តាមប្រព័ន្ធអេឡិចត្រូនិច។

សេវាចុះបញ្ជីអត្រានុកូលដ្ឋាន និងការចេញឯកសារអត្តសញ្ញាណកម្មគឺជាផ្នែកមួយនៃសេវាកម្មរបស់រាជរដ្ឋា ភិបាលចំពោះប្រជាពលរដ្ឋ ហេតុនេះ គួរតែធ្វើឱ្យមានស្តង់ដា និងគុណភាពខ្ពស់ ប្រកបដោយប្រសិទ្ធភាព និង មានតម្លាភាព។

ដើម្បីធ្វើឱ្យការចុះបញ្ជីមានលក្ខណៈជាសកល និងខានមិនបាននោះ សេវាកម្មទាំងឡាយត្រូវតែនាំយកឱ្យ

ទៅជិតប្រជាពលរដ្ឋ កាន់តែជិតកាន់តែល្អ។ សេវាទាំងឡាយត្រូវតែផ្តល់ឱ្យក្នុងរយៈពេលខ្លី ហើយធ្វើឡើងដោយមានតម្លាភាព ខណៈពេលដែលអតិថិជនទទួលបានការជូនដំណឹងអំពីសារៈសំខាន់នៃសេវាកម្មទាំងអស់នេះ ព្រមទាំងអំពីដំណើរការ និងនីតិវិធីនៃចុះបញ្ជីផងដែរ។ ត្រូវតែចាត់ទុកអតិថិជនថាជាអ្នករួមចំណែកលើកស្ទួយការផ្តល់សេវាទាំងអស់នេះឱ្យកាន់តែប្រសិទ្ធភាព ហើយអតិថិជនក៏ត្រូវតែមានលទ្ធភាពផ្តល់មតិយោបល់ត្រលប់អំពីគុណភាពនៃសេវាកម្មទាំងអស់  ដែលនេះគឺជាការចូលរួមនៅក្នុងការកែលម្អសេវាកម្មទាំងអស់នោះពីសំណាក់ប្រជាពលរដ្ឋ។ ការកើនឡើងការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងទៅលើការងារវិមជ្ឈការ ដូច្នេះការចុះបញ្ជីអត្រានុកូលដ្ឋាន និងសេវាកម្មពាក់ព័ន្ធផ្សេងៗទៀត ក៏ត្រូវតែបានទទួលចំណែកពីកិច្ចសហប្រតិបត្តិការគ្នាយ៉ាងជិតស្និទពីសមាជិកផ្សេងៗគ្នានៅក្នុសង្គម និងអង្គភាពផ្សេងៗគ្នាដែលជាតំណាងឱ្យប្រជាពលរដ្ឋទាំងអស់។

រាល់ការផ្តល់សេវាទាំងអស់ពាក់ព័ន្ធទៅនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ត្រូវមានទីកន្លែងសមរម្យងាយស្រួលដល់ប្រជាពលរដ្ឋទៅប្រើប្រាស់ ហើយត្រូវតែអនុវត្តតាមស្តង់ដាខ្ពស់។ ការរៀបចំការផ្តល់សេវាទាំងអស់គួរតែតម្រឹមស្របជាមួយការអនុវត្តល្អៗដែលគេបានទទួលស្គាល់កន្លងមក ឬគួរតែត្រូវបានធ្វើតាមស្តង់ដាដូចគ្នាមួយដែលរចនាសម្ព័ន្ធក្នុងពេលបច្ចុប្បន្ននេះមិនទាន់មាន។ ដូច្នេះហើយ ការប្រើប្រាស់ប្រព័ន្ធការិយាល័យច្រកចេញចូលតែមួយនឹងត្រូវបង្កើនឡើង។ នៅក្នុងរយៈពេលវែង គោលដៅរួមគឺត្រូវផ្តល់នូវសេវាទាំងអស់តាមរយៈមន្ត្រីរាជការស៊ីវិលដែលមានការបណ្តុះបណ្តាលអំពីសេវានោះប្រកបដោយគុណសម្បត្តិគ្រប់គ្រាន់ក្នុងខណៈពេលដែលការងារផ្នែកបច្ចេកទេសត្រូវតែបន្តអនុវត្តដោយអ្នកឯកទេស។

រាជរដ្ឋាភិបាលកម្ពុជា ក៏កំពុងតែចាប់យកលទ្ធភាពក្នុងការអនុវត្តអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិច តាមរយៈការប្រើប្រាស់ ប.វ.គ.ព.(ICT) សម្រាប់ផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋ ដូច្នេះការចុះបញ្ជីអត្រានុកូលដ្ឋាន ការចេញឯកសារអត្តសញ្ញាណកម្ម និងសេវាកម្មដទៃទៀត ត្រូវតែធ្វើឡើងនៅតាមប្រព័ន្ធអ៊ីនធឺណេត។ ការធ្វើបែបនេះនឹងរួមចំណែកឱ្យបានសម្រេចនូវគោលដៅនៃអភិបាលកិច្ចល្អ តម្លាភាព និងគណនេយ្យភាព។

## VI. គោលដៅ និងសកម្មភាព

គោលដៅ គឺជាអ្វីដែលអាចវាស់វែងបាន និងមានគុណតម្លៃ ទៅតាមក្របខ័ណ្ឌពេលវេលាជាក់លាក់ ដែលអាចជួយឱ្យសម្រេចឱ្យបាននូវគោលបំណងរួម។ គោលដៅត្រូវបានកំណត់សម្រាប់គោលបំណងនីមួយៗនៃ ផ.យ.ជ.អ. ២០១៥-២០២៤។ សកម្មភាពទាំងឡាយត្រូវកំណត់ឡើងដើម្បីធានាអនុវត្តសម្រេចតាមគោលដៅទាំងអស់ដែលបានដាក់ចេញ។ សកម្មភាពទាំងឡាយដែលបានកំណត់ឡើងនៅក្នុង ផ.យ.ជ.អ. ២០១៥-២០២៤ ត្រូវបានរៀបចំឡើងសម្រាប់អនុវត្តគោលដៅនីមួយៗ។

### ៦.១. គោលបំណងទី១ ៖ រៀបចំក្របខ័ណ្ឌច្បាប់សម្រាប់កំណត់អត្តសញ្ញាណបុគ្គល

គោលបំណងជារួមនៃការធ្វើឱ្យមានបរិយាកាសផ្នែកច្បាប់ដែលមានអំណោយផលថ្មីមួយសម្រាប់វិស័យនេះ គឺត្រូវបង្កើតឱ្យមានឡើងនូវក្របខ័ណ្ឌច្បាប់ដែលចាំបាច់សម្រាប់រៀបចំមូលដ្ឋាននៃប្រព័ន្ធអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានទំនើប ដើម្បីបម្រើតម្រូវការរបស់ប្រទេសកម្ពុជា ក៏ដូចជាពលរដ្ឋរបស់ខ្លួន។ កិច្ចការនេះក៏ជួយសម្រួលដល់ប្រតិបត្តិការរបស់ IPIS ផងដែរ។

គោលបំណងគឺត្រូវព្រាង និងធ្វើវិសោធនកម្មច្បាប់ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តនានា (អនុក្រឹត្យ) សម្រាប់ការបង្កើតនិងប្រតិបត្តិការប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និងប្រតិបត្តិការ IPIS។

#### *៦.១.១. គោលដៅទី១ ៖ អនុម័តច្បាប់ថ្មីស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន ឱ្យបានមុនឆ្នាំ២០១៧*

ច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន ត្រូវចែងអំពីគោលបំណង ប្រព័ន្ធ និងគោលការណ៍សម្រាប់ការចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។

**តារាងទី១**

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| ព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន | បង្កើតក្រុមការងារដែលមានអ្នកជំនាញជាតិ និងអន្តរជាតិ ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ពេញលេញមួយសម្រាប់ក្រសួងមហាផ្ទៃ។ ក្នុងអំឡុងពេលនេះត្រូវរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលាផ្សេងៗជាមួយភាគីពាក់ព័ន្ធ។ |
| រៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណម្ម និងស្ថិតិអត្រានុកូលដ្ឋានសម្រាប់ដាក់ជូនរាជរដ្ឋាភិបាល និងសភាជាតិ | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងក្រសួងមហាផ្ទៃ តាមរយៈកិច្ចសហប្រតិបត្តិការ ឬការពិគ្រោះយោបល់ជាមួយនឹងភាគីពាក់ព័ន្ធផ្សេងៗទៀត ត្រូវពិនិត្យបញ្ចប់សេចក្តីព្រាងដែលក្រុមការងារបានរៀបចំឡើង និងត្រូវបញ្ជូនទៅឱ្យរាជរដ្ឋាភិបាល និងសភាជាតិ។ |
| អនុម័តច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្ត | ច្បាប់នេះត្រូវដំណើរការពិនិត្យដោយគណៈរដ្ឋមន្ត្រី និងបន្តពិនិត្យដោយ |

| សកម្មភាព | ការពណ៌នាសកម្មភាព |
| --- | --- |
| សញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន | គណៈកម្មការ និងកិច្ចប្រជុំពេញអង្គរបស់រដ្ឋសភា និងព្រឹទ្ធសភា ដើម្បីឈានទៅអនុម័តច្បាប់នេះ។ |
| ដាក់ឱ្យច្បាប់នេះចូលជាធរមាន | ច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន នឹងចូលជាធរមាន (នៅពេលដែលប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានបានដាក់ឱ្យអនុវត្ត)។ មាត្រាស្តីពីអន្តរកម្មជាមួយ ប.រ.អ.ព.(IPIS) ត្រូវចូលជាធរមាននៅពេលដែល ប.រ.អ.ព.(IPIS) ត្រូវបានដាក់ឱ្យដំណើរការ។ |

### ៦.១.២. *គោលដៅទី២ ៖ អនុម័តអនុក្រឹត្យថ្មីស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន ឱ្យបានមុនឆ្នាំ២០១៧*

ដើម្បីអនុវត្តច្បាប់ថ្មីខាងលើនេះ ចាំបាច់ត្រូវរៀបចំលិខិតបទដ្ឋានក្រោមច្បាប់មួយទៀតដើម្បីចែងលម្អិតអំពីការចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន (ងាយស្រួលធ្វើវិសោធនកម្ម) ដែលលិខិតបទដ្ឋាននេះត្រូវសម្រេចដោយរាជរដ្ឋាភិបាលក្នុងទម្រង់ជាអនុក្រឹត្យ។ គោលដៅនេះនឹងធានាបង្កើតឱ្យមាននូវភស្តុតាងនៃព្រឹត្តិការណ៍ជីវិតរបស់បុគ្គលម្នាក់ៗពេញមួយជីវិតរបស់ពួកគេ (រួមមាន ការចុះបញ្ជីកំណើត អាពាហ៍ពិពាហ៍ មរណភាព។ល។) ព្រមទាំងចែងអំពីដំណើរការ និងបើកផ្លូវឱ្យមានការទទួលបាននូវព័ត៌មានទាំងអស់សម្រាប់គោលដៅចេញសំបុត្រអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។

**តារាងទី២**

| សកម្មភាព | ការពណ៌នាសកម្មភាព |
| --- | --- |
| រៀបចំសេចក្តីព្រាងអនុក្រឹត្យ | យោងតាមក្រុមការងារដែលបានរៀបរាប់នៅក្នុងតារាងទី១ អគ្គនាយកដ្ឋានត្រូវចាប់ផ្តើមព្រាងអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន បន្ទាប់ពីបានទទួលសេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន និងពិនិត្យកែសម្រួលលើសេចក្តីព្រាងនេះ។ ក្នុងអំឡុងពេលធ្វើការងារនេះ ក្រុមការងារនឹងត្រូវរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលាជាមួយភាគីពាក់ព័ន្ធ។ |
| បញ្ចប់សេចក្តីព្រាងអនុក្រឹត្យ | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងក្រសួងមហាផ្ទៃ ដោយមានកិច្ចសហប្រតិបត្តិការ ឬការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ត្រូវបញ្ចប់សេចក្តីព្រាងនេះ។ |
| កែសម្រួលអនុក្រឹត្យចុងក្រោយ | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងក្រសួងមហាផ្ទៃត្រូវកែសម្រួល |

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| | សេចក្ដីព្រាងចុងក្រោយនៃអនុក្រឹត្យនេះ។ |
| អនុម័តអនុក្រឹត្យ | អនុក្រឹត្យនេះត្រូវបានបង្កើតឡើង និងដាក់ចូលជាធរមានឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីច្បាប់ស្ដីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋានអនុម័ត។ មាត្រាដែលចែងពីអន្តរកម្មជាមួយ ប.រ.អ.ព.(IPIS) នឹងត្រូវចូលជាធរមាននៅពេលដែល ប.រ.អ.ព.(IPIS) ដាក់ឱ្យដំណើរការ។ |
| បង្កើតសេចក្ដីណែនាំប្រតិបត្តិ | សេចក្ដីណែនាំប្រតិបត្តិសម្រាប់អនុវត្តអនុក្រឹត្យនេះ ត្រូវតែបង្កើតឡើង និងដាក់ឱ្យប្រើប្រាស់។ |

### *៦.១.៣. គោលដៅទី៣ ៖ អនុម័តវិសោធនកម្មច្បាប់ដែលចាំបាច់សម្រាប់ការបង្កើត ប.រ.អ.ព. (IPIS) ឱ្យបានមុនឆ្នាំ២០១៧*

គោលបំណងមួយទៀតនៃកំណែទម្រង់ច្បាប់ គឺដើម្បីសម្របសម្រួលអន្តរកម្មរវាងប្រភពទិន្នន័យនានាសម្រាប់ធ្វើឱ្យ ប.រ.អ.ព.(IPIS) ក្លាយទៅជាប្រព័ន្ធមួយដែលអាចពិនិត្យ និងផ្ទៀងផ្ទាត់ព័ត៌មានបានជាក់លាក់ទៅវិញទៅមកអំពីប្រជាពលរដ្ឋ។ ប្រការនេះតម្រូវការឱ្យមាននូវបទបញ្ញាមួយចំនួនស្ដីពីការទាញយកទិន្នន័យពីក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានបញ្ចូលទៅនៅក្នុង ប.រ.អ.ព.(IPIS)។ ការទាញទិន្នន័យនេះតម្រូវឱ្យមានវិធានមួយចំនួនស្ដីពីការចម្លងទិន្នន័យជាក់លាក់ពីក្នុងប្រព័ន្ធ ប.ច.អ.ស.(CRVS) បញ្ចូលទៅក្នុង ប.រ.អ.ព.(IPIS)។ វាក៏ត្រូវការចាំបាច់ផងដែរក្នុងការកំណត់វិធានសម្រាប់ការបង្កើត និងការប្រើប្រាស់ ល.ក.អ.ខ.(KIDC) នេះ។ ចំពោះបញ្ហាព័ត៌មានសម្ងាត់របស់បុគ្គល និងសុវត្ថិភាព ក៏ត្រូវតែធ្វើការកំណត់ឱ្យបានច្បាស់លាស់។ វិធានក្នុងការកំណត់ផ្នែកណាមួយនៃព័ត៌មាន និងការប្រើប្រាស់ព័ត៌មាននោះសម្រាប់បម្រើឱ្យការពិនិត្យបញ្ជាក់ភាពត្រឹមត្រូវនៃព័ត៌មានបុគ្គលដោយផ្នែកសាធារណៈ និងផ្នែកឯកជន ក៏ត្រូវតែបង្កើតឡើងផងដែរ។

**តារាងទី៣**

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| កំណត់សម្គាល់លើច្បាប់ទាំងឡាយដែលនឹងត្រូវធ្វើវិសោធនកម្មសម្រាប់គាំទ្រការបង្កើត ប.រ.អ.ព.(IPIS) | ក្រុមការងារនឹងត្រូវកត់សម្គាល់លើច្បាប់ទាំងឡាយដែលមានភាពចាំបាច់សម្រាប់គាំទ្រការបង្កើត ប.រ.អ.ព.(IPIS)។ នៅពេលបច្ចុប្បន្ននេះច្បាប់ស្ដីពីសញ្ជាតិអាចចាត់ទុកថាជាច្បាប់មួយដែលត្រូវធ្វើវិសោធនកម្ម។ |
| ធ្វើសេចក្ដីព្រាងខ្លឹមសារបទបញ្ញត្តិនានានៃច្បាប់ដែលត្រូវធ្វើវិសោធនកម្ម | ផ្អែកលើក្រុមការងារដែលបានចែងនៅក្នុងតារាងទី១។ |

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| រៀបចំកែសម្រួលខ្លឹមសារបទបញ្ញត្តិច្បាប់ដែលត្រូវធ្វើវិសោធនកម្មដើម្បីគាំទ្រការបង្កើត ប.រ.អ.ព.(IPIS) | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងក្រសួងមហាផ្ទៃ ព្រមទាំងភាគីពាក់ព័ន្ធផ្សេងៗទៀតត្រូវពិនិត្យបញ្ចប់លើសេចក្តីព្រាងរបស់ក្រុមការងាររួចបញ្ជូនទៅរាជរដ្ឋាភិបាល និងសភាជាតិ។ |
| អនុម័តវិសោធនកម្មច្បាប់ | ច្បាប់នេះនឹងត្រូវដំណើរការពិនិត្យអនុម័តដោយគណៈរដ្ឋមន្ត្រី និងបន្តដោយគណៈកម្មការ និងសម័យប្រជុំពេញអង្គរបស់រដ្ឋសភា និងព្រឹទ្ធសភា។ វិសោធនកម្មច្បាប់នឹងត្រូវបានអនុម័ត។ |
| ការចូលជាធរមាននៃបទបញ្ញត្តិដែលបានធ្វើវិសោធនកម្ម | បទប្បញ្ញត្តិដែលបានធ្វើវិសោធនកម្មហើយ នឹងត្រូវចូលជាធរមាន (នៅពេលដែល ប.រ.អ.ព.(IPIS) ត្រូវបានដាក់ឱ្យដំណើរការ)។ |

### ៦.១.៤. គោលដៅទី៤ ៖ ធ្វើវិសោធនកម្មអនុក្រឹត្យដែលមានការចាំបាច់ក្នុងការបង្កើត ប.រ.អ.ព. (IPIS) ឱ្យបានមុនឆ្នាំ២០១៧

លិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ មានដូចជា ច្បាប់ស្តីពីសញ្ជាតិ អនុក្រឹត្យស្តីពីលិខិតឆ្លងដែន អនុក្រឹត្យស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងអនុក្រឹត្យស្តីពីការស្នាក់នៅជាដើម ចាំបាច់ត្រូវតែធ្វើវិសោធនកម្មដើម្បីបើកផ្លូវឱ្យចម្លងយកទិន្នន័យជាក់លាក់មួយចំនួនពីក្នុងប្រព័ន្ធទិន្នន័យទាំងនោះ បញ្ចូលទៅក្នុង ប.រ.អ.ព.(IPIS) ដូចបានកំណត់នៅក្នុងវិធាននៃការបង្កើត ល.ក.អ.ខ.(KIDC) ព្រមទាំងអាចជានាំឱ្យមានការផ្លាស់ប្តូរទិន្នន័យទាំងនោះ ជាមួយស្ថាប័នសាធារណៈ ដែលទទួលបន្ទុកវិស័យនានា ក៏ដូចជាមួយផ្នែកសាធារណៈផ្សេងទៀត និងវិស័យឯកជនផងដែរ។

គោលដៅនៃកំណែទម្រង់ច្បាប់ត្រូវធ្វើឡើង និងត្រូវដាក់បញ្ចូលនូវគោលការណ៍ជាគន្លឹះៗ និងសកម្មភាពនានាមួយចំនួនដូចជា ៖

- ស្របតាមគោលការណ៍ជាសកលនៃច្បាប់អន្តរជាតិ និងការអនុវត្តជាអន្តរជាតិនានា។
- ច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន ត្រូវតែចែងអំពីគោលបំណង គោលការណ៍ និងមូលដ្ឋានខាងផ្លូវច្បាប់នានា ចំណែកឯអនុក្រឹត្យត្រូវរៀបរាប់លម្អិតបន្ថែមលើបញ្ហាទាំងអស់នេះ។
- ច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតអត្រានុកូលដ្ឋានគួរតែរៀបចំឱ្យមានផ្នែកច្រើនដូចជា មួយផ្នែកទាក់ទងនឹងកំណើត មួយផ្នែកទៀតទាក់ទងនឹងអាពាហ៍ពិពាហ៍ និងមួយផ្នែកទាក់ទងនឹងមរណភាព។ ហើយក៏ត្រូវមានផ្នែកមួយដទៃទៀតពាក់ព័ន្ធជាមួយនឹងស្ថិតិអត្រានុកូលដ្ឋាន និងការប្រើប្រាស់ទិន្នន័យអត្រានុកូលដ្ឋានផងដែរ។ ផ្នែកផ្សេងទៀតនឹងលើកឡើងអំពីការការពារទិន្នន័យ ការផ្សព្វផ្សាយទិន្នន័យដែលបានចុះបញ្ជី និងអន្តរកម្មជាមួយនឹង ប.រ.អ.ព.(IPIS)។ មូលដ្ឋានច្បាប់សម្រាប់អ្នកចុះបញ្ជីក៏នឹងត្រូវបញ្ចូលទៅក្នុងច្បាប់នេះដែរ។ អនុក្រឹត្យស្តីអំពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន នឹងត្រូវចែងអំពីបញ្ហាដូចគ្នា ដូចមានចែងនៅក្នុងកថាខ័ណ្ឌខាងលើ ហើយនិងចំណុចមួយចំនួនខាងក្រោមនេះផងដែរ ប៉ុន្តែត្រូវចែងនៅក្នុងកម្រិតមួយដែលមានលក្ខណៈកាន់តែលម្អិតបន្ថែមទៀត។

- តាមផ្លូវច្បាប់ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋាន នឹងត្រូវបង្កើតឱ្យមានបញ្ជីបីដាច់ដោយឡែកពីគ្នាគឺ ៖ បញ្ជីកំណើត បញ្ជីអាពាហ៍ពិពាហ៍ និងបញ្ជីមរណភាព។ ការជូនដំណឹង និងសំណើសុំចុះបញ្ជីព្រឹត្តិការណ៍ណាមួយ នឹងត្រូវធ្វើឡើងទៅលើបញ្ជីដែលមានការពាក់ព័ន្ធណាមួយ។ ការចេញសំបុត្រអត្រានុកូលដ្ឋានដោយមន្ត្រីអត្រានុកូលដ្ឋានសម្រាប់ព្រឹត្តិការណ៍ផ្សេងៗដែលបានចុះបញ្ជីនោះ គឺត្រូវធ្វើឡើងនៅក្នុងនាមអ្នកចុះបញ្ជីពិតប្រាកដ។ តាមបច្ចេកទេស បញ្ជីទាំងអស់នោះនឹងត្រូវមានទិន្នន័យមួយ។
- អត្តសញ្ញាណកម្មបុគ្គលនឹងត្រូវផ្អែកលើការចុះបញ្ជីកំណើត។ ក្នុងអំឡុងពេលនៃការចុះបញ្ជី បុគ្គលម្នាក់ៗនឹងត្រូវទទួលបាន ល.ក.អ.ខ.(KIDC) មួយ ដែលជាលេខពិសេសសម្រាប់បុគ្គលនោះ ហើយត្រូវ ប្រើប្រាស់លេខកូដនេះដោយមិនអាចកែប្រែបានពេញមួយជីវិតរបស់បុគ្គលនោះ។ លេខកូដនេះមិនអាចយកមកប្រើប្រាស់ម្តងទៀតឡើយទោះជាបុគ្គលនោះបានទទួលមរណភាពហើយក៏ដោយ។ មូលដ្ឋានច្បាប់សម្រាប់បញ្ហាទាំងអស់នេះ ត្រូវតែចែងនៅក្នុងច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។
- សំបុត្រកំណើតគឺជាភស្តុតាងច្បាប់ដើម និងស្របច្បាប់តែមួយគត់នៃអត្តសញ្ញាណកម្មបុគ្គលម្នាក់ៗ និងត្រូវប្រើប្រាស់នៅគ្រប់ករណីដែលមានតម្រូវការបង្ហាញភស្តុតាងនេះ។ លិខិតឆ្លងដែន ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគឺគ្រាន់តែជាឯកសារតំណាងនៃអត្តសញ្ញាណបុគ្គលតែប៉ុណ្ណោះ។ គោលការណ៍នេះត្រូវតែចែងនៅក្នុងច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។
- បទបញ្ជាស្តីពីការតព្វកិច្ចនៃការជូនដំណឹងអំពីកំណើត និងព្រឹត្តិការណ៍ជីវិតនានា (អ្នកណា នៅពេលណា និងតាមវិធីណា) ត្រូវតែកំណត់នៅក្នុងច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។
- ច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាននេះ នឹងត្រូវផ្អែកទៅលើគោលការណ៍នៃការចុះបញ្ជីព្រឹត្តការណ៍រស់នៅ (កំណើត អាពាហ៍ពិពាហ៍ និងមរណភាព) នៃបុគ្គលម្នាក់ៗពេញមួយជីវិតរបស់គេ។
- ការឱ្យឈ្មោះច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាននេះ បានបង្ហាញពីតួនាទីដ៏សំខាន់លើការងារស្ថិតិអត្រានុកូលដ្ឋាន ហើយត្រូវរៀបចំឱ្យមានផ្នែកដោយឡែកមួយអំពីបញ្ហាស្ថិតិអត្រានុកូលដ្ឋាននេះ។
- ការចុះបញ្ជីព្រឹត្តការណ៍រស់នៅ ត្រូវតែផ្ទុកក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានស្របតាមមូលដ្ឋានគតិយុត្តដែលបានកំណត់ឡើងដោយច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។ បញ្ជីនេះត្រូវមានតែព័ត៌មានអំពីព្រឹត្តការណ៍រស់នៅដែលមានសុពលភាពផ្លូវច្បាប់តែប៉ុណ្ណោះ។
- នៅក្នុងច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន ត្រូវបង្កើតឡើងនូវមូលដ្ឋានគតិយុត្តសម្រាប់ការបែងចែកទិន្នន័យនៃបញ្ជីកំណើត បញ្ជីអាពាហ៍ពិពាហ៍ និងបញ្ជីមរណភាពជាមួយការិយាល័យស្ថិតិជាតិ។

- ត្រូវរៀបរាប់អំពីហេដ្ឋារចនាសម្ព័ន្ធនៃការចុះបញ្ជីអត្រានុកូលដ្ឋាន អាណត្តិនៃអគ្គនាយកអត្រានុកូលដ្ឋាន (អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវមានមុខងារជាអគ្គនាយកអត្រានុកូលដ្ឋាន) និងមន្ត្រីអត្រានុកូលដ្ឋាននានា។ ព័ត៌មានលម្អិតអំពីមុខងារនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តបន្ទាប់បន្សំផ្សេងៗទៀត។
- ត្រូវបង្កើតឱ្យមានមូលដ្ឋានគតិយុត្តដ៏រឹងមាំមួយសម្រាប់ការផ្តល់សំបុត្រអត្រានុកូលដ្ឋានដោយប្រព័ន្ធចុះបញ្ជី។ ឧទាហរណ៍ សំបុត្រអត្រានុកូលដ្ឋានដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋាន តែត្រូវមានតម្លៃទទួលស្គាល់ដោយតុលាការ។
- ត្រូវផ្តល់ការចុះបញ្ជីដោយមិនមានការរើសអើង ដើម្បីធានាឱ្យកុមារទាំងអស់ដែលកើតនៅក្នុងប្រទេសកម្ពុជា មានសំបុត្រកំណើត។
- ផ្អែកតាមគោលការណ៍ច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន ក្រៅពីសិទ្ធិក្នុងការកំណត់អត្តសញ្ញាណថាជាបុគ្គលម្នាក់ គឺពុំមានសិទ្ធិអ្វីផ្សេងទៀតឡើយដែលអាចកើតចេញពីការចុះបញ្ជីកំណើត។ ឧទាហរណ៍ សញ្ជាតិនៃកុមារដែលបានចុះបញ្ជី នឹងត្រូវតែកំណត់ដោយច្បាប់ស្តីពីសញ្ជាតិ។
- ត្រូវធ្វើការប៉ាន់ប្រមាណនូវកម្រិតនៃការទទួលបាន និងភាពចាំបាច់នៃការសម្ងាត់ទិន្នន័យបុគ្គលនៅក្នុងបញ្ជីអត្រានុកូលដ្ឋាន និងរបៀបធ្វើតុល្យភាពនៃការពិចារណាទាំងអស់នេះ។
- ត្រូវបញ្ចូលនូវមូលដ្ឋានគតិយុត្តសម្រាប់ប្រត្តិបត្តិការចុះបញ្ជីដោយប្រព័ន្ធកុំព្យូទ័រ។ បញ្ហាដែលទាក់ទងនឹងនីតិវិធីទាំងអស់ ត្រូវកំណត់ដោយអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន។
- ត្រូវធានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពលើការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន តាមរយៈការកំណត់ពីការតព្វកិច្ចរបស់ឪពុកម្តាយ អ្នកមើលថែទាំ ឆ្មប វេជ្ជបណ្ឌិត និងមន្ទីរពេទ្យជាដើម ក្នុងការរាយការណ៍អំពីព្រឹត្តិការណ៍ដែលត្រូវចុះបញ្ជី ជាពិសេស កំណើត។
- ប្រការសំខាន់នៃក្របខ័ណ្ឌច្បាប់នៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន គឺការលម្អិតតម្រូវការផ្នែកបច្ចេកទេសទៅលើប្រព័ន្ធ ប.វ.គ.ព.(ICT) ក៏ដូចជាទិដ្ឋភាពរចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធទាំងមូល។ ក្នុងការរៀបចំបង្កើតប្រព័ន្ធទាំងអស់នេះ យើងត្រូវយល់ថា ការរៀបចំឱ្យមានសមាសធាតុផ្សេងៗជាច្រើនពាក់ព័ន្ធគ្នានៅក្នុងដំណាក់កាលរចនាតុបតែងប្រព័ន្ធទាំងមូល គឺមានគុណប្រយោជន៍ដ៏ធំធេង។
- ប.វ.គ.ព.(ICT)និងរចនាសម្ព័ន្ធគ្រប់គ្រងដែលកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់នេះនឹងផ្តល់អត្ថប្រយោជន៍ដល់ការរៀបចំសមាសធាតុទាំងអស់ ក៏ដូចជាប្រព័ន្ធទាំងមូល ដើម្បីធានាអំពីភាពបត់បែន និងភាពស៊ីសង្វាក់គ្នានៃសមាសធាតុទាំងនោះ។

**តារាងទី៤**

| សកម្មភាព | ការពណ៌នាសកម្មភាព |
| --- | --- |
| កំណត់នូវអនុក្រឹត្យមួយចំនួនដែលត្រូវធ្វើវិសោធនកម្មសម្រាប់គាំទ្របង្កើត ប.រ.អ.ព. (IPIS) និងត្រូវចាប់ផ្តើមព្រាងខ្លឹមសារដែលត្រូវកែសម្រួល | ផ្អែកលើក្រុមការងារដែលបានរៀបរាប់ក្នុងតារាងសកម្មភាពទី១ ត្រូវចាប់ផ្តើមសកម្មភាពនេះភ្លាមបន្ទាប់ពីបញ្ចប់សេចក្តីព្រាងច្បាប់ដែលត្រូវធ្វើវិសោធនកម្មសម្រាប់គាំទ្រការបង្កើត ប.រ.អ.ព.(IPIS)។ ក្នុងអំឡុងពេលបំពេញកិច្ចការនេះ ក្រុមការងារនឹងត្រូវរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលាជាមួយភាគីពាក់ព័ន្ធ។ អនុក្រឹត្យទាំងនោះអាចមានអនុក្រឹត្យស្តីពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លិខិតឆ្លងដែន ការស្នាក់នៅជាដើម។ |
| បញ្ចប់សេចក្តីព្រាងអនុក្រឹត្យនីមួយៗ | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងក្រសួងមហាផ្ទៃ ដោយមានកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធផ្សេងៗ ត្រូវពិនិត្យបញ្ចប់សេចក្តីព្រាងអនុក្រឹត្យរបស់ក្រុមការងារ។ |
| កែសម្រួលអនុក្រឹត្យចុងក្រោយ | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និងក្រសួងមហាផ្ទៃត្រូវកែសម្រួលសេចក្តីព្រាងចុងក្រោយនៃអនុក្រឹត្យទាំងឡាយដែលត្រូវធ្វើវិសោធនកម្មស្របតាមការអនុម័តច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋាន និងវិសោធនកម្មច្បាប់ទាំងឡាយដូចដែលមានរៀបរាប់នៅក្នុងតារាងសកម្មភាពទី៣។ |
| អនុម័តអនុក្រឹត្យ | អនុក្រឹត្យទាំងឡាយត្រូវបានដាក់ឱ្យចូលជាធរមាននៅពេលដែល ប.រ.អ.ព. (IPIS) ត្រូវបានគេអនុវត្ត។ |
| បង្កើតសេចក្តីណែនាំប្រតិបត្តិ | សេចក្តីណែនាំប្រតិបត្តិសម្រាប់ការអនុវត្តអនុក្រឹត្យ ត្រូវតែរៀបចំបង្កើតឡើង និងដាក់ឱ្យប្រើប្រាស់។ |

## ៦.២. គោលបំណងទី២ ៖ បង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋានដែលមានលក្ខណៈជាសកល និងមានការឆ្លើយតប

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែលមានលក្ខណៈជាសកល និងមានការឆ្លើយតបមានតួនាទីយ៉ាងសំខាន់ដើម្បីសម្រេចបាននូវការអភិវឌ្ឍប្រកបដោយសមធម៌ និងផ្តោតទៅលើប្រជាពលរដ្ឋ ហើយត្រូវការរៀបចំបង្កើតឡើង ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅក្នុងប្រទេសកម្ពុជា។

### *៦.២.១. គោលដៅទី១ ៖ បង្កើនអត្រាគ្របដណ្តប់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន នៅត្រឹមឆ្នាំ២០២៤*

នេះគឺជាគោលការណ៍ដែលបានទទួលស្គាល់ជាអន្តរជាតិអំពីអត្រាគ្របដណ្តប់ជាសកលនៃការចុះបញ្ជីអត្រានុកូលដ្ឋាន។ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានត្រូវធ្វើការចុះបញ្ជីនូវរាល់ព្រឹត្តិការណ៍រស់នៅទាំងអស់ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងយុត្តាធិការរបស់ខ្លួន រួមទាំង ក្រុមប្រជាជនដែល

ពិបាកទទួលបានការចុះបញ្ជី ក្រុមជនអសមត្ថភាពពលកម្ម និងក្រុមជនដែលមិនសូវបានការយកចិត្តទុកពីសង្គម។ អត្រាគ្របដណ្តប់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន ត្រូវតែបង្កើនឡើងជាលំដាប់ត្រឹមឆ្នាំ២០២៤ ដូចខាងក្រោមនេះ ៖

- ត្រឹមឆ្នាំ២០២៤ យ៉ាងហោចណាស់៩០%នៃកំណើតនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងដែនយុត្តាធិការរបស់ខ្លួន នៅក្នុងឆ្នាំនោះ ត្រូវតែចុះបញ្ជីហើយ និងបានចេញសំបុត្រកំណើតឱ្យ។
- មុនឆ្នាំ២០២៤ យ៉ាងហោចណាស់ក្មេងអាយុក្រោម៥ឆ្នាំចំនួន៩០%នៅក្នុងប្រទេសកម្ពុជា និងនៅក្នុងដែនយុត្តាធិការរបស់ខ្លួនបានចុះបញ្ជីកំណើត។
- ក.ប.អ.ក.(TPIT) នឹងត្រូវកំណត់លើគោលដៅ (Target) ដូចខាងក្រោមនេះ សម្រាប់ការអនុវត្តផែនផ.យ.ជ.អ. ២០១៥-២០២៤ ៖
- ត្រឹមឆ្នាំ២០២៤ យ៉ាងហោចណាស់ xx ភាគរយនៃមរណភាពដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា និងក្នុងដែនយុត្តាធិការរបស់ខ្លួន នៅក្នុងឆ្នាំនោះ ត្រូវបានចុះបញ្ជី និងបានចេញសំបុត្រមរណភាពឱ្យ។
- ត្រឹមឆ្នាំ២០២៤ យ៉ាងហោចណាស់ xx ភាគរយនៃមរណភាពទាំងអស់ត្រូវបានកត់ត្រាដោយវិស័យសុខាភិបាលនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងដែនយុត្តាធិការរបស់ខ្លួន នៅក្នុងឆ្នាំនោះ នឹងត្រូវមានការបញ្ជាក់តាមផ្នែកវេជ្ជសាស្ត្រអំពីមូលហេតុនៃការស្លាប់ត្រូវបានកត់ត្រាទុក ដោយប្រើប្រាស់ទម្រង់នៃលិខិតមរណភាពដែលមានលក្ខណៈជាអន្តរជាតិ។
- ត្រឹមឆ្នាំ២០២៤ យ៉ាងហោចណាស់ xx ភាគរយនៃអាពាហ៍ពិពាហ៍ទាំងអស់ត្រូវបានកត់ត្រាទុកនៅក្នុងប្រទេសកម្ពុជា និងនៅក្នុងដែនយុត្តាធិការរបស់ខ្លួន នៅក្នុងឆ្នាំនោះ ត្រូវបានចុះបញ្ជីហើយត្រូវមានការចេញសំបុត្រអាពាហ៍ពិពាហ៍។
- ត្រឹមឆ្នាំ២០២៤ យ៉ាងហោចណាស់ xx ភាគរយនៃការលែងលះទាំងអស់ក្នុងប្រទេសកម្ពុជា និងក្នុងដែនយុត្តាធិការរបស់ខ្លួន នៅក្នុងឆ្នាំនោះ ត្រូវបានចុះបញ្ជីហើយនិងត្រូវមានចេញសំបុត្រលែងលះឱ្យ។

ដើម្បីសម្រេចបាននូវគោលដៅ (Target) ដូចបានកំណត់ច្បាស់លាស់ខាងលើនេះ កិច្ចខំប្រឹងប្រែងឱ្យមានការចូលរួមពីសាធារណៈជន និងការបង្កើតឱ្យមានតម្រូវការ ត្រូវតែពង្រីក។ ការកសាងសមត្ថភាព និងការបណ្តុះបណ្តាលត្រូវតែរៀបចំឡើង ដូចមានកំណត់នៅក្នុងគោលដៅទី២ខាងក្រោមនេះ។

**តារាងទី៥**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
|---|---|
| កំណត់ទិន្នន័យដើមគ្រានៃវិសាលភាពគ្របដណ្តប់លើការងារអត្រានុកូលដ្ឋាន | ដោយផ្អែកទៅលើទិន្នន័យដែលមានស្រាប់ និងដោយយោងតាមតម្រូវការ និងវិធីសាស្ត្ររបស់ ESCAP អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនឹងត្រូវធ្វើការកំណត់ទិន្នន័យដើមគ្រានៃវិសាលភាពគ្របដណ្តប់លើការងារអត្រានុកូលដ្ឋាន សម្រាប់វាស់វែងការរីកចម្រើន សំដៅទៅសម្រេចបានគោលដៅដែលបានបង្កើតឡើង។ ក្នុងដំណាក់កាលទីមួយនេះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនឹងកំណត់អំពីកម្រិតវិសាលភាពគ្របដណ្តប់បឋមសិនសម្រាប់ការចុះបញ្ជីអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋាន ហើយនៅ |

| សកម្មភាព | ការពណ៌នាសកម្មភាព |
| --- | --- |
| | ក្នុងអំឡុងពេលនៃការអនុវត្តផែនការយុទ្ធសាស្ត្រនេះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវបង្កើតទិន្នន័យដើមគ្រា (ដោយមានការបែងចែកទិន្នន័យតាមប្រភេទ) ដូចបានតម្រូវដោយ ESCAP។ ទិន្នន័យដើមគ្រានឹងត្រូវប្រើសម្រាប់ការរាយការណ៍ជាទៀងទាត់អំពីការរីកចម្រើនទៅដល់ ESCAP។ |
| បង្កើនឱ្យមានការចូលរួមពីវិស័យសាធារណៈ ក្នុងការជូនដំណឹង និងដំណើរការផ្តល់ព័ត៌មាន | វិស័យសុខាភិបាល អប់រំ និងវិស័យសាធារណៈផ្សេងៗទៀត ក៏ដូចជាប្រព័ន្ធផ្សព្វផ្សាយ អ្នកធ្វើការងារសង្គម និងសង្គមស៊ីវិល ត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មានអំពីអត្ថប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងជំរុញដល់សាធារណជនឱ្យចុះបញ្ជីព្រឹត្តិការណ៍សំខាន់ៗក្នុងជីវិតរស់នៅរបស់ពួកគេ។ ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន អាជ្ញាធរមានសមត្ថកិច្ចដែលបានកំណត់ក្នុងក្របខ័ណ្ឌច្បាប់ត្រូវតែជំរុញឱ្យចូលរួម ត្រូវបានឃ្លាំមើល និងត្រូវបានក្រើនរំលឹកជាបន្តបន្ទាប់អំពីការជូនដំណឹងឱ្យបានទាន់ពេលវេលាក្នុងការចុះបញ្ជីព្រឹត្តិការណ៍រស់នៅនេះ។ |
| ជំរុញឱ្យមានការចូលរួមពីវិស័យសាធារណៈ និងវិស័យឯកជនដើម្បីជំរុញកំណើនតម្រូវការ | ការពិភាក្សាវែកញែកនៅក្នុងចំណោមស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ជាតិត្រូវតែចាប់ផ្តើមធ្វើឡើង ដើម្បីរិះរកវិធីសាស្ត្រលើកទឹកចិត្តដល់ការចុះបញ្ជីព្រឹត្តការណ៍រស់នៅ។ វិស័យឯកជនគួរតែអញ្ជើញឱ្យចូលរួមដើម្បីសហការជាមួយរដ្ឋាភិបាលក្នុងការរិះរកវិធីសាស្ត្រលើកទឹកចិត្តដែលអាចផ្តល់ឱ្យដោយក្រុមហ៊ុនឯកជន ទាក់ទងនឹងការចុះបញ្ជីព្រឹត្តិការណ៍រស់នៅរបស់បុគ្គល។ ប្រព័ន្ធដែលមានស្រាប់ (ដូចជា អត្តសញ្ញាណប័ណ្ណ) ត្រូវបានលើកទឹកចិត្តឱ្យក្លាយជាចំណែកនៃកិច្ចប្រឹងប្រែងសម្រាប់ជំរុញកំណើនតម្រូវការ តាមរយៈការស្នើសុំសំបុត្រកំណើត/ឯកសារអត្តសញ្ញាណរបស់គ្រួសារ។ |
| កសាងទំនុកចិត្ត និងលើកកម្ពស់ការយល់ដឹងអំពីអត្ថប្រយោជន៍នៃការចុះបញ្ជីអត្រានុកូលដ្ឋាន | យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈទូលំទូលាយ អំពីសារៈសំខាន់នៃការចុះបញ្ជីព្រឹត្តិការណ៍ជីវិត អំពីផលប្រយោជន៍ និងអំពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន រួមទាំងតម្រូវការ ដំណើរការ នីតិវិធីចាំបាច់នានា គួរតែរៀបចំឡើងក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ។ យុទ្ធនាការនៃការលើកកម្ពស់ការយល់ដឹងដែលបានកំណត់គោលដៅជាក់លាក់ ត្រូវតែអនុវត្តចំពោះប្រជាពលរដ្ឋជាក់លាក់មួយចំនួនដើម្បីជំរុញឱ្យមានតម្រូវការ។ បុគ្គល និងគ្រួសារ ត្រូវតែដឹងអំពីគុណតម្លៃនៃការប្រកាសព្រឹត្តិការណ៍រស់នៅរបស់ពួកគេដល់អាជ្ញាធរពាក់ព័ន្ធ ហើយត្រូវមានឆន្ទៈក្នុងការធ្វើដូច្នេះ។ ទំនាក់ទំនងរវាងការជឿទុកចិត្តគ្នាទៅវិញទៅមក និងគណនេយ្យភាពរវាងរដ្ឋបាលគ្រប់កម្រិតទាំងអស់នៃអង្គភាពចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និងសាធារណ |

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| | ជន ត្រូវតែបង្កើតឡើង ហើយរាល់សកម្មភាពទាំងអស់ត្រូវមានការរៀបចំ និងគ្រប់គ្រងនៅក្នុងរបៀបមួយដែលមានការគោរពចំពោះភាពខុសប្លែកគ្នាខាងវប្បធម៌។ |
| ការកសាងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន | គុណភាពនៃមន្ត្រីទទួលបន្ទុកការងារចុះបញ្ជី គឺជាកត្តាដ៏ចម្បងដែលទាមទារឱ្យមានការពង្រឹង ក្នុងអំឡុងពេលអនុវត្តផែនការនេះ។ ចាប់ពីដំបូងរហូតដល់ផែនការយុទ្ធសាស្ត្រជាតិនេះអនុវត្តចប់ ការកសាងសមត្ថភាព និងកម្មវិធីបណ្តុះបណ្តាល ត្រូវធ្វើឡើងជាអចិន្ត្រៃយ៍ និងបន្តបន្ទាប់ឱ្យបានទៀងទាត់ ជាពិសេសទៅដល់មន្ត្រីមូលដ្ឋាន ដោយត្រូវផ្តោតលើការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ក្របខ័ណ្ឌច្បាប់ ប្រព័ន្ធ ប.វ.គ.ព.(ICT) និងការផ្តល់សេវាកម្មដែលមានការពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ជាមួយនឹងការប្រើប្រាស់ឯកសារបណ្តុះបណ្តាលសមស្រប និងលម្អិត (ប្រើប្រាស់រូបភាពនានា)។ កម្មវិធីកសាងសមត្ថភាពទូទាំងប្រទេស ត្រូវអនុវត្តដោយរាប់បញ្ចូលទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ កម្មវិធីទាំងកសាងសមត្ថភាពនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងអំឡុងពេលកំពុងផ្សព្វផ្សាយនិងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែលប្រើប្រាស់ប្រព័ន្ធ ប.វ.គ.ព.(ICT)។ កម្មវិធីបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់រដ្ឋបាលមូលដ្ឋានក៏ត្រូវរៀបចំបង្កើតឡើងដើម្បីកសាងសមត្ថភាពទៅដល់មេឃុំ ចៅ សង្កាត់ និងអ្នកគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូលផងដែរ។ |
| រៀបចំសកម្មភាពផ្សព្វផ្សាយនៅមូលដ្ឋាន | សកម្មភាពផ្សព្វផ្សាយពិសេសៗ ត្រូវតែរៀបចំជាបន្តបន្ទាប់តាំងពីដំបូងនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ និងត្រូវការអនុវត្តដោយមានការសម្របសម្រួលនិងស៊ីសង្វាក់គ្នាជាមួយនឹងការកសាងសមត្ថភាពក្នុងការចុះបញ្ជី ការលើកកម្ពស់ការយល់ដឹង និងសកម្មភាពផ្តល់ព័ត៌មានតាមគោលដៅផ្សេងៗ។ សកម្មភាពទាំងឡាយត្រូវអនុវត្តឡើងដោយមានការចូលរួមពីសង្គមស៊ីវិល និងសហគមន៍ ក្នុងគោលបំណងបញ្ជូនព័ត៌មានទៅដល់ដៃក្រុមជនងាយរងគ្រោះ ក្រុមជនមិនសូវទទួលការយកចិត្តទុកដាក់ ឬក្រុមជនត្រូវបានគេផាត់ចេញនានា។ វិធានការក្នុងការផ្សព្វផ្សាយដែលបានប្រើនាពេលបច្ចុប្បន្ននេះ ដូចជាសៀវភៅកត់ត្រាទិន្នន័យភូមិ ឃើញថាបានរួមចំណែកជាវិជ្ជមានដល់អត្រាកំណើននៃការចុះបញ្ជី ដែលអត្រាកំណើននេះនឹងរក្សាបាននៅក្នុងរយៈពេលកំពុងអនុវត្តសៀវភៅនេះប៉ុណ្ណោះ ហើយសៀវភៅនេះអាចអនុវត្តបានដោយភ្ជាប់ជាមួយនឹងការកសាងសមត្ថភាព និងសកម្មភាពផ្តល់ព័ត៌មានដូចមានរៀបរាប់ខាងលើ។ |

### ៦.២.២. គោលដៅទី២ ៖ បង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានមានលក្ខណៈជាសកល ដោយប្រើប្រព័ន្ធ ប.វ.គ.ព. (ICT) ឱ្យបានត្រឹមឆ្នាំ២០១៨

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដែលបំពាក់ដោយបច្ចេកវិទ្យាដែលប្រើប្រាស់ប្រព័ន្ធវេបសាយ និងបច្ចេកវិទ្យាឧបករណ៍ចល័ត ការប្រើប្រាស់កុំព្យូទ័រ មានលក្ខណៈសកលទូទាំងប្រទេស ត្រូវតែជាសកម្មភាពជាអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយហេតុថាកំណត់ត្រានៃការចុះបញ្ជីអត្រានុកូលដ្ឋានទាំងអស់នឹងបង្កើតបានជាទិន្នន័យជាតិអំពីប្រជាពលរដ្ឋ កម្មវិធីអត្តសញ្ញាណកម្មជាតិ និងការផ្តល់សេវាកម្មតាមប្រព័ន្ធអេឡិចត្រូនិច។ ការបង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានដែលមានលក្ខណៈជាសកល និងមានការឆ្លើយតបនេះ ត្រូវតែលើកឡើងតាមរយៈការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការកសាងសមត្ថភាព និងប្រព័ន្ធព័ត៌មានដែលមានការពាក់ព័ន្ធទៅនឹងសកម្មភាពទាំងអស់នេះ។

**តារាងទី៦**

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| ចុះបញ្ជីអត្រានុកូលដ្ឋានតាមកុំព្យូទ័រដោយប្រើប្រាស់វេបសាយ និងបច្ចេកវិទ្យាចល័ត | ការប្រមូលទិន្នន័យជាឌីជីថល ការរក្សាទុក និងការផ្សព្វផ្សាយទិន្នន័យនឹងត្រូវបង្កើតឡើងតាមរយៈប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅលើវេបសាយ។ ប្រព័ន្ធកុំព្យូទ័រដំណើរការនៅលើវេបសាយនេះ ត្រូវរៀបចំឱ្យ មានវេបសាយមួយដែលអាចប្រើប្រាស់ភ្ជាប់ជាមួយនឹងឧបករណ៍បច្ចេកវិទ្យាចល័ត (tablet) បាន។ ឧបករណ៍បច្ចេកវិទ្យាចល័តបែបនេះនឹងជួយសម្រួលដល់ការចុះបញ្ជីព្រឹត្តិការណ៍រស់នៅនានា នៅតាមតំបន់ឆ្ងាយៗ ឬនៅក្នុងតំបន់ដាច់ស្រយាល តាមរយៈការរៀបចំឱ្យមានកាលវិភាគទៀងទាត់សម្រាប់ចុះបញ្ជីចល័តនៅគ្រប់ភូមិទាំងអស់នៃឃុំ សង្កាត់នីមួយៗ (ជាពិសេស ការចុះបញ្ជីដល់ជនពិការ ជនក្រីក្រ និងក្រុមដែលទទួលបានការយកចិត្តទុកដាក់តិចតួច)។ បច្ចេកវិទ្យាទំនើបដែលប្រើប្រាស់កុំព្យូទ័រ នឹងធ្វើឱ្យការចុះបញ្ជីកាន់តែមានប្រសិទ្ធភាព ដើម្បីធានាឱ្យមានគុណភាពទិន្នន័យ និងមានភាពសាមញ្ញ កាត់បន្ថយការចំណាយសម្រាប់ការរក្សាទុក និងការការពារឯកសារបញ្ជីអត្រានុកូលដ្ឋានទាំងអស់នោះឱ្យមានសុវត្ថិភាព ជៀសផុតពីគ្រោះមហន្តរាយធម្មជាតិ ឬក៏ការបំផ្លិចបំផ្លាញជារូបវន្តណាមួយ។ ការចុះបញ្ជីអត្រានុកូលដ្ឋានតាមប្រព័ន្ធកុំព្យូទ័រនេះអាចធ្វើទៅបានលុះត្រាតែមានការរៀបចំឡើងនូវ តម្រូវការបច្ចេកទេសលម្អិត (Specification) ការរចនា (Design) ការធ្វើឱ្យមានលក្ខណៈជាឌីជីថល (Digitization) និងប្រតិបត្តិការទិន្នន័យ (Data operation)។ ការចុះបញ្ជីតាមប្រព័ន្ធកុំព្យូទ័រនេះ នឹងត្រូវទាមទារឱ្យមានការកសាងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT infrastructure) និង |

| សកម្មភាព | ការពណ៌នាសកម្មភាព |
| --- | --- |
| | អភិវឌ្ឍសមត្ថភាពទូទាំងប្រទេស ព្រមទាំងផ្តល់ឱ្យឃុំ សង្កាត់នូវឧបករណ៍បច្ចេកវិទ្យាចល័ត (tablet) ដែលអាចប្រើភ្ជាប់ជាមួយវេបសាយសម្រាប់បម្រើឱ្យការចុះបញ្ជី និងការប្រមូលទិន្នន័យ ហើយនិងផ្តត់ផ្គង់សេវាអ៊ីនធឺណែត ឧបករណ៍បោះពុម្ព និងសម្ភារៈចាំបាច់ផ្សេងៗមួយចំនួនទៀត។ |
| ពង្រីកការងារមន្ត្រីអត្រានុកូលដ្ឋានដល់មន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ | សហការជាមួយក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការភ្ជាប់បណ្តាញមន្ត្រីអត្រានុកូលដ្ឋាននៅតាមស្ថានទូត និងស្ថានកុងស៊ុលរបស់កម្ពុជាដើម្បីចុះបញ្ជីអត្រានុកូលដ្ឋាននៅបរទេស។ កិច្ចការនេះចាំបាច់ត្រូវអភិវឌ្ឍសមត្ថភាពដល់ក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងរៀបចំឱ្យមានសៀវភៅណែនាំប្រតិបត្តិ និងការណែនាំឱ្យបានច្បាស់លាស់។ ក្នុងការរៀបចំក្របខ័ណ្ឌច្បាប់ (រួមទាំងនីតិវិធីប្រតិបត្តិ) ត្រូវតែកំណត់អំពីការប្រមូលកម្រៃសេវា។ នៅពេលមិនទាន់ដាក់ឱ្យដំណើរការពេញលេញប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានតាមប្រព័ន្ធ ប.វ.គ.ព.(ICT) មន្ត្រីអត្រានុកូលដ្ឋាននៅតាមស្ថានទូត និងស្ថានកុងស៊ុលនានា អាចរៀបចំចុះបញ្ជីដោយភ្ជាប់ជាមួយកម្មវិធីសាកល្បងចុះបញ្ជីតាមវេបសាយជាបណ្តោះអាសន្នសិន បន្ទាប់មកទើបធ្វើការកែសម្រួលតាមក្រោយ។ |
| ពង្រឹងសមត្ថភាពគ្រប់គ្រង និងប្រតិបត្តិការការងារចុះបញ្ជីអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋាន | ការលើកកម្ពស់ការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននឹងត្រូវពឹងផ្អែកទៅលើចំនួនបុគ្គលិកដែលមានសមត្ថភាពគ្រប់គ្រាន់ និងមានចំនួនសមស្រប។ ត្រូវយកចិត្តទុកដាក់ផងដែរដល់យន្តការអភិវឌ្ឍន៍អាជីព និងការលើកសរសើរ ក៏ដូចជាការបណ្តុះបណ្តាលជាបន្តបន្ទាប់ដើម្បីពង្រឹងជំនាញ និងថែរក្សាមន្ត្រីទាំងអស់ឱ្យនៅបំពេញការងារបានយូរ។ ស្របជាមួយនឹងដំណាក់កាលនានានៃ ផ.យ.ជ.អ. ២០១៥-២០២៤ នេះ កម្មវិធីកសាងសមត្ថភាពទូទាំងប្រទេសត្រូវតែបង្កើតឡើង និងអនុវត្តជាបន្តបន្ទាប់។ កម្មវិធីបណ្តុះបណ្តាលនេះត្រូវផ្តោតលើការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ក្របខ័ណ្ឌច្បាប់ ប្រព័ន្ធ ប.វ.គ.ព.(ICT) និងផ្នែកផ្តល់សេវាកម្មដែលទាក់ទងជាមួយនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន។ វគ្គបណ្តុះបណ្តាលពិសេសៗ គួរតែធ្វើឡើងដើម្បីពង្រឹង និងរក្សាសមត្ថភាពជំនាញបច្ចេកទេសសំខាន់ៗ ដូចជាការបណ្តុះបណ្តាលសម្រាប់គ្រូពេទ្យដើម្បីអាចកំណត់ឱ្យបានត្រឹមត្រូវ និងកត់ត្រានូវព័ត៌មានស្តីពីមូលហេតុមរណភាព ក៏ដូចជាកសាងសមត្ថភាពដល់មន្ត្រីដើម្បីឱ្យពួកគេមានសមត្ថភាពក្នុងការបង្កើត និងរក្សា តាមដានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។<br>បណ្តាញទំនាក់ទំនងផ្ទៃក្នុងរវាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ជាមួយ |

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| | រដ្ឋបាលនៅថ្នាក់ក្រោមជាតិដែលមានការពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ត្រូវតែបង្កើតឡើង ដើម្បីឱ្យមានការផ្លាស់ប្តូរព័ត៌មានជាបន្តបន្ទាប់ និងជាទៀងទាត់ សម្រាប់ជួយសម្រួលនិងជំរុញកំណែទម្រង់នេះឱ្យរលូន។ |
| បង្កើតសៀវភៅណែនាំស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងសេចក្តីណែនាំដែលមានលក្ខណៈឯកភាព | នីតីវិធីប្រតិបត្តិត្រូវតែបង្កើតឡើង និងអនុវត្តដើម្បីធានាឱ្យមុខងារនៃការចុះបញ្ជីអត្រានុកូលដ្ឋាន ក្លាយទៅជាប្រភពផ្តល់ឯកសារផ្លូវច្បាប់សម្រាប់កំណត់អត្តសញ្ញាណបុគ្គលស្របច្បាប់ ស្ថានភាពពលរដ្ឋ ទំនាក់ទំនងគ្រួសារ សញ្ជាតិ និងការធានាឱ្យទទួលបានសិទ្ធិនានា។ វិធានការផ្សេងទៀតក៏ត្រូវតែប្រើប្រាស់ផងដែរដើម្បីធានាភាពគ្មានស្ទួននៃកំណត់ត្រាកំណើត តាមរយៈការពង្រឹងល័ក្ខខ័ណ្ឌនៃការចុះបញ្ជី (ឧទាហរណ៍ ការកត់ត្រាលេខឯកសារ ឬ ល.ក.អ.ខ.(KIDC) របស់ឪពុកម្តាយ (ប្រសិនបើមាន) ឬក៏អាចប្រើប្រាស់ព័ត៌មានជីវសាស្ត្ររបស់ឪពុកម្តាយ ជាដើម)។ ស្រដៀងគ្នានេះដែរ នីតិវិធីនេះក៏ត្រូវកំណត់ពីរបៀបបញ្ជូនទិន្នន័យមកនាយកដ្ឋានមានសមត្ថកិច្ចដើម្បីអនុម័តបង្កើតជាស្ថិតិអត្រានុកូលដ្ឋាន។ និតីវិធីនៃការចុះបញ្ជី ត្រូវកំណត់ឱ្យមានការពិនិត្យផ្ទៀងផ្ទាត់ទ្វេដង ដោយមន្ត្រីទទួលខុសត្រូវពីររូបផ្សេងៗគ្នា ដើម្បីអនុម័តបញ្ចូលទិន្នន័យទាំងនោះទៅក្នុងប្រព័ន្ធ មុនពេលអាចបោះពុម្ពសំបុត្រអត្រានុកូលដ្ឋានបាន។ គ្រប់ឃុំ សង្កាត់ទាំងអស់ ត្រូវតែអនុវត្តតាមនីតីវិធីដែលមានការឯកភាពនេះដូចៗគ្នា ដូច្នេះហើយ ការរៀបចំសៀវភៅណែនាំប្រតិបត្តិត្រូវតែមានលក្ខណៈងាយស្រួលយល់សម្រាប់ឱ្យមន្ត្រីប្រើប្រាស់ ជាមួយនឹងការកំណត់ឱ្យមានគោលការណ៍តម្លាភាពសម្រាប់អតិថិជនក៏ដូចជាអ្នកដាក់ពាក្យសុំចុះបញ្ជីផងដែរ។ |
| ការបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានដែលមានស្រាប់ជាឌីជីថល | ការធ្វើឌីជីថលទិន្នន័យអត្រានុកូលដ្ឋានដែលមានស្រាប់ ត្រូវតែធ្វើឡើងដើម្បី គោលបំណងបម្រើឱ្យការងារប័ណ្ណសារឯកសារ និងសម្រាប់តម្រូវការក្នុងការផ្ទៀងផ្ទាត់ប្រព័ន្ធថ្មី។ |
| ការផ្លាស់ប្តូរទម្រង់សំបុត្រកំណើត | ទម្រង់សំបុត្រត្រូវតែរចនាឡើងវិញ ដោយមានដាក់បញ្ចូល ល.ក.អ.ខ.(KIDC)។ ការរចនាថ្មីនេះ ត្រូវពិចារណាពីទម្រង់ដែលមានភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់ និងចំណាយតិច។ |

### ៦.២.៣.គោលដៅទី៣ ៖ បង្កើតប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋាន ឱ្យបានត្រឹមឆ្នាំ២០២៣

ស្ថិតិអត្រានុកូលដ្ឋានអំពីប្រជាសាស្ត្រ និងសុខភាពរបស់ប្រជាជន និងព័ត៌មានផ្សេងទៀត នឹងផ្តល់ជាមូលដ្ឋានភស្តុតាងសម្រាប់អ្នកធ្វើគោលនយោបាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងការផ្តល់កិច្ចអន្តរាគមន៍

សម្រាប់ឆ្លើយតបនឹងវិសមភាពសង្គម សេដ្ឋកិច្ច និងសុខភាព ជាពិសេសក្នុងចំណោមប្រជាជនដែលពិបាកនឹងទទួលសេវា ហើយនិងក្រុមដែលបានការយកចិត្តទុកដាក់តិចតួច។ របាយការណ៍ស្ថិតិអត្រានុកូលដ្ឋានដែលមានភាពត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលសម្រាប់រយៈពេល២ឆ្នាំចុងក្រោយ តាមរយៈការប្រើប្រាស់កំណត់ត្រានៃការចុះបញ្ជីអត្រានុកូលដ្ឋាន គឺជាប្រភពដ៏ចម្បងដែលអាចដាក់ឱ្យប្រើប្រាស់តាមប្រព័ន្ធវេបសាយ ឱ្យបានមុនឆ្នាំ២០២៤។

**តារាងទី៧**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
|---|---|
| បង្កើតប្រព័ន្ធផលិតស្ថិតិអត្រានុកូលដ្ឋានជាទៀងទាត់មួយ ដោយផ្អែកលើកំណត់ត្រាអត្រានុកូលដ្ឋាន និងអនុញ្ញាតឱ្យសាធារណៈជនចូលយកប្រើប្រាស់បាន | បន្ទាប់ពីមានក្របខ័ណ្ឌច្បាប់ដែលបានបង្កើតឡើងត្រឹមត្រូវហើយ ក្របខ័ណ្ឌច្បាប់នោះត្រូវធានាគុណភាព ភាពទាន់ពេលវេលា និងភាពពេញលេញនៃស្ថិតិអត្រានុកូលដ្ឋានដែលត្រូវបានផលិតឡើងស្របទៅតាមគោលការណ៍ជាមូលដ្ឋាននៃស្ថិតិផ្លូវការ និងគួរមានបទប្បញ្ញត្តិសម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន។ ជាមួយគ្នានេះដែរ ប្រព័ន្ធកុំព្យូទ័រនឹងអាចបង្កើតឡើង និងចែកផ្សាយនូវតារាងស្ថិតិអត្រានុកូលដ្ឋានផងដែរ។ ដំណើរការនេះទាមទារឱ្យមានការរៀបចំបង្កើតតារាងលម្អិតស្តីពីស្ថិតិអត្រានុកូលដ្ឋាន ហើយផលិតស្ថិតិនេះដោយផ្អែកលើកំណត់ត្រាបញ្ជីអត្រានុកូលដ្ឋាន។ |
| រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង និងកសាងសមត្ថភាពលើការងារបង្កើតស្ថិតិអត្រានុកូលដ្ឋាន | ការធ្វើប្រតិភូកម្មមុខងារស្ថិតិអត្រានុកូលដ្ឋានទៅកាន់អង្គភាពជាក់លាក់នៅក្នុងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដែលត្រូវទទួលខុសត្រូវនៅក្នុងការបង្កើតស្ថិតិអត្រានុកូលដ្ឋាន និងសមត្ថភាពវិភាគនៅក្នុងនាយកដ្ឋាន ក៏ដូចជាសម្របសម្រួល និងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធផ្សេងៗទៀត។ |

### ៦.២.៤. *គោលដៅទី៤ ៖ ភ្ជាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋាន ជាមួយនឹងប្រព័ន្ធជំនួយផ្សេងទៀតសម្រាប់ការផ្លាស់ប្តូរទិន្នន័យ ឱ្យបានត្រឹមឆ្នាំ២០២៤*

ការភ្ជាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋានជាមួយនឹងប្រព័ន្ធព័ត៌មានពាក់ព័ន្ធសំខាន់ៗដទៃទៀតទាក់ទងទៅនឹងដំណើរការចុះបញ្ជីអត្រានុកូលដ្ឋាន នឹងគាំទ្រដល់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ព្រមទាំងជួយជំរុញដល់អភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិច។ ការភ្ជាប់ជាមួយនឹងប្រព័ន្ធព័ត៌មានសុខាភិបាល និងប្រព័ន្ធព័ត៌មានតុលាការ ត្រូវតែពិចារណារៀបចំឡើងដោយស្ថាប័នទាំងពីរនេះ ដែលជាអ្នកជូនដំណឹងស្តីពីព្រឹត្តិការណ៍នានាសម្រាប់ការចុះបញ្ជីអត្រានុកូលដ្ឋាន ហើយប្រព័ន្ធនេះក៏បាននិងកំពុងអនុវត្តសាកល្បងរួចហើយ។ ការភ្ជាប់ជាមួយប្រព័ន្ធចុះបញ្ជីប្រជាពលរដ្ឋ ក៏នឹងជួយជំរុញឱ្យមានការបង្កើត ល.ក.អ.ខ.(KIDC) និងជាការ

កំណត់អត្តសញ្ញាណពិសេសមួយសម្រាប់បុគ្គលទាំងអស់ចាប់ពីពេលកើតមក។

**តារាងទី៨**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
|---|---|
| ភ្ជាប់ប្រព័ន្ធព័ត៌មានសុខាភិបាលជាមួយនឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន | ប្រព័ន្ធព័ត៌មានសុខាភិបាល (កម្មវិធីសាកល្បង ឬក៏ការរៀបចំបង្កើតប្រព័ន្ធជាក់លាក់មួយ) ត្រូវការពង្រីកបន្ថែមដើម្បីអាចផ្តល់ដំណឹងជាទម្រង់អេឡិចត្រូនិចមកប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននេះ ក៏ត្រូវការរៀបចំធ្វើយ៉ាងណាឱ្យអាចគាំទ្រទៅដល់ការទទួលបាន និងការរក្សាទុកសេចក្តីជូនដំណឹងអេឡិត្រូនិចនោះពីប្រព័ន្ធព័ត៌មានសុខាភិបាលបាន។ ការធ្វើបែបនេះនឹងធានាឱ្យមានការភ្ជាប់ប្រព័ន្ធដែលអាចបញ្ជូនដំណឹងបានភ្លាមៗនៅពេលមានព្រឹត្តិការណ៍ជីវិតកើតឡើង និងធានាបាននូវគុណភាពទិន្នន័យកាន់តែល្អប្រសើរជាងមុន។ |
| ភ្ជាប់ប្រព័ន្ធព័ត៌មានតុលាការជាមួយប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន | ប្រព័ន្ធព័ត៌មានពីតុលាការ (កម្មវិធីសាកល្បង ឬក៏ត្រូវរៀបចំបង្កើតប្រព័ន្ធជាក់លាក់មួយ) គួរតែត្រូវពង្រីកបន្ថែមដើម្បីអាចផ្តល់សេចក្តីសម្រេចចិត្តរបស់តុលាការជាទម្រង់អេឡិចត្រូនិច មកកាន់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ក៏ត្រូវការរៀបចំធ្វើយ៉ាងណាឱ្យអាចគាំទ្រទៅដល់ការទទួលបាន និងការរក្សាទុកសេចក្តីជូនដំណឹងពីសម្រេចចិត្តតុលាការជាទម្រង់អេឡិចត្រូនិចបាន។ ធ្វើបែបនេះនឹងធានាឱ្យមានការភ្ជាប់ប្រព័ន្ធមួយដែលអាចបញ្ជូនដំណឹងតាមពេលវេលាជាក់ស្តែង ហើយនឹងធានាឱ្យមានគុណភាពទិន្នន័យកាន់តែល្អប្រសើរផងដែរ។ |
| ភ្ជាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានជាមួយនឹងការចុះបញ្ជីប្រជាពលរដ្ឋ (Population Registry) | ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននឹងត្រូវភ្ជាប់ជាមួយការចុះបញ្ជីប្រជាពលរដ្ឋ (Population Registry) ភ្លាម នៅពេលការចុះបញ្ជីប្រជាពលរដ្ឋចាប់ផ្តើមដំណើរការ ដើម្បីគាំទ្រការបញ្ជូនសំណើបង្កើត ល.ក.អ.ខ.(KIDC) និងទាញយកលេខកូដដែលបានបង្កើតឡើងនោះមកប្រើប្រាស់ ហើយបញ្ជូនទិន្នន័យ ឬធ្វើបច្ចុប្បន្នភាពទិន្នន័យបុគ្គលទាំងអស់ ទៅកាន់ប្រព័ន្ធការចុះបញ្ជីប្រជាពលរដ្ឋ (Population Registry) វិញ ហើយនិងអាចស្វែងរកទិន្នន័យនោះបានផងដែរ។ |

### ៦.៣. គោលបំណងទី៣ ៖ បង្កើតប្រព័ន្ធរួមអត្តសញ្ញាណកម្មពលរដ្ឋ (IPIS)

#### *៦.៣.១. គោលដៅទី១ ៖ បង្កើតឱ្យមានលេខកូដអត្តសញ្ញាណខ្មែរ (KIDC) ដល់ប្រជាជនទាំងអស់ដែលបានកំណត់អត្តសញ្ញាណរួច ឱ្យបានត្រឹមឆ្នាំ២០១៩*

ល.ក.អ.ខ.(KIDC) ត្រូវតែណែនាំឱ្យប្រើប្រាស់ ដែលនោះគឺជាលេខកូដអត្តសញ្ញាណតែមួយគត់ដែលបានប្រគល់ឱ្យបុគ្គលម្នាក់នៅពេលចុះបញ្ជីកំណើត ហើយត្រូវប្រើប្រាស់ពេញមួយជីវិតរបស់ពួកគេ។ ប្រសិនបើគ្មានការប្រើប្រាស់លេខកូដអត្តសញ្ញាណបែបនេះទេនោះ ប្រហែលជាការចែករំលែកព័ត៌មានបុគ្គលក្នុងចំណោមស្ថាប័នផ្សេងៗ ពិតជាមិនអាចធ្វើទៅរួចឡើយ។ ល.ក.អ.ខ.(KIDC) នេះ គឺជាតម្រូវការសម្រាប់ការបង្កើតឡើង និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធអត្តសញ្ញាណប្រជាពលរដ្ឋ។

ល.ក.អ.ខ.(KIDC) នេះត្រូវតែផ្តល់ទៅឱ្យបុគ្គលគ្រប់រូបដែលបានចុះបញ្ជីកំណើត ហើយការចុះបញ្ជីនោះបានភ្ជាប់ជាមួយនឹងទិន្នន័យដែលបានបញ្ចូល។ ជាងនេះទៅទៀត លេខកូដអត្តសញ្ញាណខ្មែរត្រូវតែសរសេរនៅលើសំបុត្រកំណើត និងឯកសារអត្តសញ្ញាណផ្សេងៗទៀត។ តាមលក្ខណៈបច្ចេកទេស ការបង្កើត និងការផ្តល់ឱ្យនូវ ល.ក.អ.ខ.(KIDC) ថ្មីនេះ ត្រូវតែអនុវត្តនៅក្នុងការចុះបញ្ជីពលរដ្ឋ (Population Registry) ដែលជាសេវាមួយភ្ជាប់ជាមួយប្រព័ន្ធផ្សេងៗទៀតដែលកំពុងគ្រប់គ្រងដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។ លើសពីនេះទៅទៀត ប្រព័ន្ធផ្លាស់ប្តូរទិន្នន័យទាំងអស់ ត្រូវតែប្រើប្រាស់លេខកូដនេះដើម្បីធានាថាអត្តសញ្ញាណរបស់បុគ្គលណាម្នាក់ មិនមានការច្រឡូកច្របល់ជាមួយនឹងអត្តសញ្ញាណរបស់បុគ្គលផ្សេងទៀតឡើយ។

ដោយហេតុថា ល.ក.អ.ខ.(KIDC) ក៏នឹងបង្កើត និងផ្តល់ឱ្យដល់ជនបរទេសទាំងឡាយណាដែលរស់នៅនិងធ្វើការនៅក្នុងទឹកដីកម្ពុជាក្នុងរយៈពេលជាក់លាក់ណាមួយ ឬជនបរទេសដែលបានទទួលសញ្ជាតិខ្មែរតាមរយៈប្រព័ន្ធគ្រប់គ្រងការងារសញ្ជាតិ ដូច្នេះ សំណើសុំបង្កើត ល.ក.អ.ខ.(KIDC) ពីប្រព័ន្ធផ្សេងៗ ដូចជា ប្រព័ន្ធគ្រប់គ្រងការងារសញ្ជាតិ និងប្រព័ន្ធគ្រប់គ្រងការស្នាក់នៅ ក៏ត្រូវដាក់ឱ្យដំណើរការផងដែរ ប៉ុន្តែត្រូវតែធ្វើទៅតាមករណីនីមួយៗ ដូចបានកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់។

**តារាងទី៩**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
|---|---|
| កសាងទំនុកចិត្ត និងលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃ ល.ក.អ.ខ.(KIDC) | យុទ្ធនាការលើកម្ពស់ការយល់ដឹងជាសាធារណៈទូលំទូលាយ នឹងត្រូវធ្វើឡើងដើម្បីណែនាំពីការប្រើប្រាស់ ល.ក.អ.ខ.(KIDC) និងអំពីសារៈសំខាន់នៃឯកសារអត្តសញ្ញាណថ្មីៗដោយមានបញ្ចូល ល.ក.អ.ខ.(KIDC) នេះផង។ |
| រចនាទម្រង់ និងណែនាំអំពីឯកសារអត្តសញ្ញាណកម្មដែលមានបញ្ចូល ល.ក.អ.ខ.(KIDC) | រាល់ឯកសារអត្តសញ្ញាណទាំងអស់ត្រូវមានបញ្ចូល ល.ក.អ.ខ.(KIDC) ដែលទើបតែបានណែនាំឱ្យប្រើប្រាស់ថ្មីៗ ដូច្នេះត្រូវធ្វើការរចនាឱ្យមានគំរូថ្មី និងដាក់ឱ្យប្រើប្រាស់។ |

### ៦.៣.២.គោលដៅទី២ ៖ ការបង្កើតបញ្ជីពលរដ្ឋ (Population Registry) ឱ្យបានត្រឹមឆ្នាំ២០១៩

បញ្ជីពលរដ្ឋនឹងក្លាយទៅជាប្រព័ន្ធទិន្នន័យកណ្តាលថ្នាក់ជាតិមួយដែលផ្ទុកទិន្នន័យសំខាន់ៗអំពីប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសកម្ពុជា។ វាគឺជាបណ្តុំទិន្នន័យកណ្តាលមួយនៃ ប.រ.អ.ព.(IPIS) និងត្រូវរៀបចំឡើងឱ្យមានមុខងារអាចធ្វើការផ្លាស់ប្តូរព័ត៌មានបានរវាងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ប្រព័ន្ធអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ប្រព័ន្ធលិខិតឆ្លងដែន ប្រព័ន្ធសញ្ជាតិ និងប្រព័ន្ធចុះបញ្ជីការស្នាក់នៅ។ បញ្ជីពលរដ្ឋត្រូវចម្លងទិន្នន័យឱ្យដូចគ្នាទៅនឹងប្រព័ន្ធបែងចែកទិន្នន័យ សម្រាប់ការបញ្ចេញព័ត៌មានដែលទទួលបានការអនុញ្ញាត និងមានសុវត្ថិភាព ទៅកាន់វិស័យឯកជន និងវិស័យសាធារណៈ។ ការបង្កើតបញ្ជីពលរដ្ឋត្រូវតែធ្វើឡើងតាមរយៈសកម្មភាពដែលទាក់ទងទៅនឹងការអភិវឌ្ឍប្រព័ន្ធព័ត៌មាន ការកសាងសមត្ថភាព និងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង។

**តារាងទី១០**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
|---|---|
| រចនាទម្រង់ និងអភិវឌ្ឍបញ្ជីប្រជាពលរដ្ឋ (Population Registry) | គួរប្រើវិធីសាស្ត្ររចនា និងអភិវឌ្ឍបញ្ជីប្រជាពលរដ្ឋនេះ ជាជាងប្រើវិធីសាស្ត្រលក់ផលិតផលឱ្យអស់ពីលើធ្នើ (COTS - commercial off-the-shelf product) ដោយសារការរៀបចំបញ្ជីនេះគឺជាតម្រូវការពិសេសនៃការប្រើប្រាស់ Interface ព័ត៌មាន និងទិន្នន័យជាភាសាខ្មែរ ព្រមទាំងការបង្កើតឱ្យមានលក្ខណៈពិសេសដោយឡែកនៃបញ្ជីប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជា ដែលជាបណ្តុំទិន្នន័យប្រមូលផ្តុំពីប្រព័ន្ធជំនួយផ្សេងៗទៀតនៅក្នុងការដោះស្រាយការងារចុះបញ្ជីទិន្នន័យទាំងអស់។ សំណុំទិន្នន័យបុគ្គលដែលត្រូវចម្លងបញ្ចូលទៅក្នុង ប.រ.អ.ព.(IPIS) ត្រូវតែកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ |
| កសាងសមត្ថភាពដើម្បីអភិវឌ្ឍ និងធ្វើប្រតិបត្តិការបញ្ជីប្រជាពលរដ្ឋ | សមត្ថភាពរបស់មន្ត្រីត្រូវការអភិវឌ្ឍបន្ថែមក្នុងគោលបំណងដើម្បីរក្សា និងតាមដានបញ្ជីពលរដ្ឋនេះ។ |

### ៦.៣.៣.គោលដៅទី៣ ៖ បង្កើតប្រព័ន្ធគ្រប់គ្រងការស្នាក់នៅទំនើប និងភ្ជាប់ជាមួយនឹង ប.រ.អ.ព. (IPIS) ឱ្យបានត្រឹមឆ្នាំ២០១៩

ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅនឹងក្លាយជាប្រព័ន្ធថ្នាក់ជាតិមួយដែលត្រូវប្រើប្រាស់ដើម្បីប្រកាសអាសយដ្ឋានស្នាក់នៅរបស់បុគ្គល និងអំពីសមាសភាពសមាជិកនៅក្នុងគ្រួសារ។ ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅ គឺជាប្រព័ន្ធតែមួយគត់សម្រាប់ផ្តល់ព័ត៌មានអំពីអាសយដ្ឋានរបស់បុគ្គល ឱ្យដល់ ប.រ.អ.ព.(IPIS)។ ប្រព័ន្ធនេះត្រូវតែបង្កើតឡើងដើម្បីកែទម្រង់សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារដែលបច្ចុប្បន្នកំពុងប្រើប្រាស់នៅលើក្រដាស ហើយដែលតាំងពីដើមមកត្រូវបានគេប្រើដើម្បីបញ្ជាក់អំពីអត្តសញ្ញាណរបស់បុគ្គល។ ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅនឹងត្រូវភ្ជាប់ជាមួយនឹង ប.រ.អ.ព.(IPIS) ដើម្បីជួយធ្វើបច្ចុប្បន្នភាពទិន្នន័យអំពីទីតាំងលំនៅដ្ឋាន និងទីសំណាក់នៅ

ក្នុងបញ្ជីពលរដ្ឋ។ ការបង្កើតឱ្យមានប្រព័ន្ធគ្រប់គ្រងការស្នាក់នៅ ក៏ត្រូវធ្វើឡើងតាមរយៈសកម្មភាពដែលមានការពាក់ព័ន្ធទៅនឹងការអភិវឌ្ឍប្រព័ន្ធព័ត៌មាន ការកសាងសមត្ថភាព និងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង។

**តារាងទី១១**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
| --- | --- |
| រចនាគុបតែងទម្រង់ និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់កត់ត្រាការស្នាក់នៅ | ត្រូវអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងការស្នាក់ដែលអាចដំណើរការបានជាមួយវេបសាយ ដោយត្រូវពិចារណាលើតម្រូវការបច្ចេកទេសលម្អិត (Specification) ការរចនាគុបតែង (Design) ការអភិវឌ្ឍ (Development) និងអាចដាក់ឱ្យប្រើប្រាស់បាននៅទូទាំងប្រទេស។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់កត់ត្រាការស្នាក់នៅនេះ នឹងត្រូវប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ ប.វ.គ.ព.(ICT) ដែលត្រូវបានបង្កើតឡើងដូចមានចែងក្នុងគោលបំណងយុទ្ធសាស្ត្រទី២ តារាងសកម្មភាពទី៧ខាងលើនេះ។ |
| ធានាសុវត្ថិភាព និងការប្រើប្រាស់ទិន្នន័យ | តម្រូវការសុវត្ថិភាពអ៊ីនធឺណែត (Cybersecurity) ត្រូវដាក់បញ្ចូល និងគោរពតាមដូចបណ្ដាប្រព័ន្ធដទៃៗទៀតដែរ ទាំងប្រព័ន្ធកំពុងដំណើរការ និងប្រព័ន្ធមិនទាន់ដំណើរការ។ ការដាក់បញ្ចូលនេះត្រូវតែអនុវត្តយ៉ាងម៉ត់ចត់តាមគោលការណ៍ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់។ |
| កសាងសមត្ថភាពគ្រប់គ្រងដើម្បីធានាប្រសិទ្ធភាពនៃការប្រកាសអំពីទីតាំងស្នាក់នៅ | ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅត្រូវអាស្រ័យទៅលើបុគ្គលិកប្រកបសមត្ថភាព និងមានចំនួនគ្រប់គ្រាន់។ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិចារណាពីយន្តការអភិឌ្ឍន៍អាជីព និងការលើកសរសើរផ្សេងៗ ក៏ដូចជាការបណ្ដុះបណ្ដាលជាបន្តបន្ទាប់ ដើម្បីពង្រឹងបន្ថែមកម្រិតជំនាញរបស់មន្ត្រី និងអាចឱ្យពួកគេបន្តបំពេញការងារបានយូរអង្វែង។ ការកសាងសមត្ថភាពគឺធ្វើយ៉ាងណាឱ្យពួកគេអាចបង្កើត ថែទាំ និងតាមដានប្រព័ន្ធគ្រប់គ្រងការស្នាក់នៅនេះបាន។ ត្រូវតែរៀបចំឱ្យមានកម្មវិធីបណ្ដុះបណ្ដាលជាតិ នៅគ្រប់ដំណាក់កាលនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ ហើយកម្មវិធីបណ្ដុះបណ្ដាលគួរផ្ដោតលើរចនាសម្ព័ន្ធគ្រប់គ្រង ក្របខ័ណ្ឌច្បាប់ ប.វ.ព.ទ.(ICT) និងការផ្ដល់សេវាលើការប្រកាសទីកន្លែងស្នាក់នៅ និងសមាសភាពគ្រួសារជាដើម។ |
| រៀបចំបង្កើតសៀវភៅណែនាំ និងគោលការណ៍ណែនាំសម្រាប់ការប្រកាសអំពីការស្នាក់នៅ | ត្រូវរៀបចំឡើងនូវនីតិវិធីប្រតិបត្តិ និងដាក់ឱ្យអនុវត្ត ដើម្បីធានាមុខងារដ៏មានសារៈសំខាន់នៃការប្រកាសអំពីការស្នាក់នៅ។ រាល់ការិយាល័យចុះបញ្ជីទាំងអស់ត្រូវតែអនុវត្តតាមនីតិវិធីរួមដូចគ្នា ដូច្នេះហើយសៀវភៅណែនាំនេះត្រូវមានភាពងាយស្រួល ព្រមទាំងកំណត់អំពីគោលការណ៍តម្លាភាពសម្រាប់អតិថិជន ឬអ្នកដាក់ពាក្យសុំប្រកាសទីស្នាក់អាស្រ័យរបស់ពួកគេ។ |

### ៦.៣.៤.គោលដៅទី៤ ៖ បង្កើតប្រព័ន្ធគ្រប់គ្រងសញ្ជាតិដែលមានប្រសិទ្ធភាព និងភ្ជាប់ជាមួយ ប.រ.អ.ព.(IPIS) ឱ្យបានត្រឹមឆ្នាំ២០១៩

ប្រព័ន្ធគ្រប់គ្រងសញ្ជាតិនឹងត្រូវបានប្រើប្រាស់ ដើម្បីគាំទ្រទៅដល់លំហូរការគ្រប់គ្រងការងារសញ្ជាតិនៅថ្នាក់ជាតិ។ ប្រព័ន្ធគ្រប់គ្រងសញ្ជាតិត្រូវធ្វើឡើងតាមរយៈសកម្មភាពដែលទាក់ទងជាមួយនឹងការអភិវឌ្ឍប្រព័ន្ធព័ត៌មាន ការកសាងសមត្ថភាព និងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង។

**តារាងទី១២**

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| រចនាតុបតែងទម្រង់ និងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងការងារសញ្ជាតិ | ត្រូវបង្កើតឡើងនូវប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងការងារសញ្ជាតិដើម្បីអាចជួយតាមដានការលះបង់សញ្ជាតិ ការទទួលបានសញ្ជាតិខ្មែរ និងជួយដល់ការរក្សាទុកឯកសារដែលពាក់ព័ន្ធនឹងកំណត់ត្រាដែលជាប់ពាក់ព័ន្ធ។ |
| កសាងសមត្ថភាពដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងការងារសញ្ជាតិ | តាមរយៈការណែនាំឱ្យប្រើប្រាស់ប្រព័ន្ធ ប.វ.គ.ព.(ICT) ថ្មី សមត្ថភាពត្រូវតែបង្កើតឡើងដោយផ្តោតទៅលើការគ្រប់គ្រងឱ្យមានប្រសិទ្ធភាពនៃដំណើរការ និងធនធានទាំងនោះ។ |
| ធានាសុវត្ថិភាព និងការប្រើប្រាស់ទិន្នន័យ | តម្រូវការសុវត្ថិភាពអ៊ីនធឺណែត (Cybersecurity) ត្រូវដាក់បញ្ចូល និងគោរពតាមដូចបណ្តាប្រព័ន្ធដទៃៗទៀតដែរ ទាំងប្រព័ន្ធកំពុងដំណើរការ និងប្រព័ន្ធមិនទាន់ដំណើរការ។ ការដាក់បញ្ចូលនេះត្រូវតែអនុវត្តយ៉ាងម៉ត់ចត់តាមគោលការណ៍ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់។ |

### ៦.៣.៥.គោលដៅទី៥ ៖ ធ្វើទំនើបកម្ម និងភ្ជាប់ប្រព័ន្ធអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជាមួយនឹង ប.រ.អ.ព.(IPIS) ឱ្យបានត្រឹមឆ្នាំ២០១៩

ប្រព័ន្ធអត្តសញ្ញាណប័ណ្ណត្រូវបានប្រើប្រាស់ ដើម្បីគ្រប់គ្រងដំណើរចេញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ ប្រព័ន្ធអត្តសញ្ញាណប័ណ្ណនេះ គឺជាប្រព័ន្ធដែលកំពុងតែមានដំណើរការល្អ ហើយនឹងមានភាពទូលំទូលាយ។ ជាមួយនឹងការណែនាំបង្កើត ល.ក.អ.ខ.(KIDC) ប្រព័ន្ធអត្តសញ្ញាណប័ណ្ណត្រូវតែពង្រីកដើម្បីអាចប្រើប្រាស់ជាឧបករណ៍កំណត់អត្តសញ្ញាណនៃប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា អាចទាញយក ល.ក.អ.ខ.(KIDC) ពី ប.រ.អ.ព.(IPIS) ហើយផ្ទុកវានៅក្នុងប្រព័ន្ធអត្តសញ្ញាណប័ណ្ណ និងប្រើប្រាស់វាជាកូនសោគន្លឹះសម្រាប់ការស្វែងរក និងផ្ទុកនូវទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាព។ ការណែនាំឱ្យប្រើប្រាស់ ល.ក.អ.ខ.(KIDC) ត្រូវការចាំបាច់នូវសកម្មភាពអភិវឌ្ឍប្រព័ន្ធព័ត៌មាន ព្រមទាំងកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីធានាគុណភាពទិន្នន័យឌីជីថល និងភាពពិសេសនៃអត្តសញ្ញាណបុគ្គលនៅក្នុងប្រព័ន្ធអត្តសញ្ញាណប័ណ្ណ។

**តារាងទី១៣**

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| ពង្រីកមុខងារប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណឱ្យអាចគាំទ្រ ល.ក.អ.ខ.(KIDC) និងការផ្លាស់ប្តូរទិន្នន័យ | ត្រូវធ្វើការពង្រីកមុខងារប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណបន្ថែមទៀតក្នុងគោលបំណងអនុញ្ញាតឱ្យមានប្រតិបត្តិការអន្តរកម្មជាមួយនឹង ប.រ.អ.ព.(IPIS)។ ការកែសម្រួល និងការពង្រីកប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណ អាចត្រូវបានអនុវត្តនៅដំណាក់ការដំបូងនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ ហើយត្រូវបម្រើការសម្រាប់ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរសិន។ ផ្នែកនេះ អាចត្រូវបានប្រើសម្រាប់ការបង្កើតបញ្ជីឈ្មោះអ្នកបោះឆ្នោត និងសម្រាប់តម្រូវការពាក់ព័ន្ធផ្សេងៗទៀត (ដូចជាការពង្រឹងការអនុវត្តច្បាប់) ឬតម្រូវការផ្នែកឯកជន ក្នុងខណៈពេលដែល ប.រ.អ.ព.(IPIS) ដំណើរការបានពេញលេញ។ |
| ធានាគុណភាពទិន្នន័យឌីជីថលនិងភាពគ្មានស្ទួននៃអត្តសញ្ញាណបុគ្គលនៅក្នុងប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណ | នៅក្នុងប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណនាពេលបច្ចុប្បន្ន ភាពជាន់គ្នាអាចកើតមានឡើង ប៉ុន្តែអាចមានកម្រិតទាបណាស់។ តាមរយៈការណែនាំឱ្យប្រើប្រាស់ ល.ក.អ.ខ.(KIDC) គុណភាពទិន្នន័យឌីជីថលនៅក្នុងប្រព័ន្ធគ្រប់គ្រងអត្តសញ្ញាណប័ណ្ណ គួរតែត្រូវត្រួតពិនិត្យឡើងវិញ ត្រូវវិភាគ (ធ្វើសវនកម្ម) ហើយនិងត្រូវដោះស្រាយក្នុងគោលបំណងគាំទ្រដល់ការកំណត់អត្តសញ្ញាណបុគ្គលតាមរយៈ ល.ក.អ.ខ. (KIDC) នេះ។ |
| ធានាសុវត្ថិភាព និងការប្រើប្រាស់ទិន្នន័យ | តម្រូវការសុវត្ថិភាពអ៊ីនធឺណែត (Cybersecurity) ត្រូវដាក់បញ្ចូល និងគោរពតាមដូចបណ្តាប្រព័ន្ធដទៃៗទៀតដែរ ទាំងប្រព័ន្ធកំពុងដំណើរការ និងប្រព័ន្ធមិនទាន់ដំណើរការ។ ការដាក់បញ្ចូលនេះត្រូវតែអនុវត្តយ៉ាងម៉ត់ចត់តាមគោលការណ៍ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់។ |

### *៦.៣.៦.គោលដៅទី៦ ៖ ធ្វើទំនើបកម្ម និងភ្ជាប់ប្រព័ន្ធលិខិតឆ្លងដែនជាមួយនឹង ប.រ.អ.ព.(IPIS) ឱ្យបានត្រឹមឆ្នាំ២០១៩*

ប្រព័ន្ធលិខិតឆ្លងដែនត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រងដំណើរចេញលិខិតឆ្លងដែន។ ប្រព័ន្ធលិខិតឆ្លងដែននេះ គឺជាប្រព័ន្ធដែលកំពុងតែមានដំណើរការល្អ ហើយនឹងមានភាពទូលំទូលាយ។ ជាមួយនឹងការណែនាំបង្កើត ល.ក.អ.ខ.(KIDC) ប្រព័ន្ធលិខិតឆ្លងដែនត្រូវតែពង្រីកដើម្បីអាចប្រើប្រាស់ជាឧបករណ៍កំណត់អត្តសញ្ញាណនៃប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា អាចទាញយក ល.ក.អ.ខ.(KIDC) ពីប្រព័ន្ធ ប.រ.អ.ព.(IPIS) រួចផ្ទុកវានៅក្នុងប្រព័ន្ធលិខិតឆ្លងដែន និងប្រើប្រាស់វាជាកូនសោគន្លឹះសម្រាប់ការស្វែងរក និងផ្ទុកនូវទិន្នន័យដែលបានធ្វើបច្ចុប្បន្នភាព។ ការណែនាំឱ្យប្រើប្រាស់ ល.ក.អ.ខ.(KIDC) ត្រូវការចាំបាច់នូវសកម្មភាពអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានព្រមទាំងកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីធានាគុណភាពទិន្នន័យឌីជីថល និងភាពពិសេសនៃអត្តសញ្ញាណបុគ្គលនៅក្នុងប្រព័ន្ធលិខិតឆ្លងដែន។

**តារាងទី១៨**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
|---|---|
| ពង្រីកមុខងារប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន ឱ្យអាចគាំទ្រ ល.ក.អ.ខ.(KIDC) និងការផ្លាស់ប្តូរទិន្នន័យ | ប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន ត្រូវការពង្រីកដោយបន្ថែមមុខងារមួយចំនួនទៀតដើម្បីអនុញ្ញាតឱ្យមានប្រតិបត្តិការអន្តរកម្មជាមួយនឹង ប.វ.អ.ព.(IPIS)។ |
| ធានាគុណភាពទិន្នន័យឌីជីថលនិងភាពគ្មានស្ទួននៃអត្តសញ្ញាណបុគ្គលនៅក្នុងប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន | ទិន្នន័យនាពេលបច្ចុប្បន្ននៅក្នុងប្រព័ន្ធលិខិតឆ្លងដែន នៅមិនទាន់ធានាអត្តសញ្ញាណពិសេសរបស់បុគ្គលនៅឡើយ ពោលគឺអាចមានភាពជាន់គ្នាខ្លះនៅក្នុងប្រព័ន្ធទិន្នន័យ។ តាមរយៈការណែនាំឱ្យប្រើប្រាស់លេខកូដអត្តសញ្ញាណខ្មែរ គុណភាពទិន្នន័យឌីជីថលនៃប្រព័ន្ធគ្រប់គ្រងលិខិតឆ្លងដែន គួរតែត្រូវបានពិនិត្យឡើងវិញ វិភាគ និងដោះស្រាយ ដើម្បីគាំទ្រដល់ការកំណត់អត្តសញ្ញាណពិសេសរបស់បុគ្គលតាមរយៈ ល.ក.អ.ខ.(KIDC)។ |
| ធានាសុវត្ថិភាព និងការប្រើប្រាស់ទិន្នន័យ | តម្រូវការសុវត្ថិភាពអ៊ីនធឺណែត (Cybersecurity) ត្រូវដាក់បញ្ចូល និងគោរពតាមដូចបណ្តាប្រព័ន្ធដទៃៗទៀតដែរ ទាំងប្រព័ន្ធកំពុងដំណើរការ និងប្រព័ន្ធមិនទាន់ដំណើរការ។ ការដាក់បញ្ចូលនេះត្រូវតែអនុវត្តយ៉ាងម៉ត់ចត់តាមគោលការណ៍ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់។ |

### *៦.៣.៧.គោលដៅទី៧ ៖ បង្កើតមជ្ឈមណ្ឌលទិន្នន័យទំនើប និងមានសុវត្ថិភាពសម្រាប់ ប.វ.អ.ព. (IPIS) ឱ្យបានត្រឹមឆ្នាំ២០១៧*

មជ្ឈមណ្ឌលទិន្នន័យ រួមជាមួយនឹង ប.វ.អ.ព.(IPIS) ត្រូវតែបង្កើតឡើងជាកម្មវិធីដ៏សំខាន់សម្រាប់អគ្គនាយកដ្ឋាន និងស្ថាប័ននានា ប្រើប្រាស់ជាប្រភពទិន្នន័យគោល និងតែមួយគត់អំពីព័ត៌មានប្រជាពលរដ្ឋ។ ការបង្កើតមូលដ្ឋានធនធានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដែលមាននិរន្តរភាព និងមានការអភិវឌ្ឍសមត្ថភាពរួមជាមួយនឹងការរក្សាសុវត្ថិភាពប្រកបដោយវិជ្ជាជីវៈ និងការបង្កើតស្តង់ដាអភិបាលកិច្ច នឹងក្លាយទៅជាទិសដៅជាយុទ្ធសាស្ត្រនៅពេលដែលបង្កើតមជ្ឈមណ្ឌលទិន្នន័យនេះ។

**តារាងទី១៩**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
|---|---|
| បង្កើតហេដ្ឋារចនាសម្ព័ន្ធ ប.វ.គ.ព.(ICT) ដែលមានលទ្ធភាពខ្ពស់សម្រាប់បម្រើឱ្យ ប.វ.អ.ព.(IPIS) | ការកសាងប្រព័ន្ធលទ្ធភាពខ្ពស់ (High Availability-HA) គឺជាការកសាងប្រព័ន្ធនៅថ្នាក់ជាតិដែលមានសមត្ថភាពលើសលប់ ទោះបីជាផ្នែកណាមួយនៃហេដ្ឋារចនាសម្ព័ន្ធ ប.វ.គ.ព.(ICT) នេះខូចខាត ក៏នឹងមិន |

| សកម្មភាព | ការពណ៌នាសកម្មភាព |
| --- | --- |
| | បណ្ដាលឱ្យប្រព័ន្ធទាំងមូលខូចខាតដែរ។ រាល់ទិដ្ឋភាពទាំងអស់ដែលទាក់ទងនឹងមជ្ឈមណ្ឌលទិន្នន័យ ត្រូវតែយកទៅពិចារណាឱ្យបានម៉ត់ចត់ ដូចជា ការជ្រើសរើសទីតាំង ឧបករណ៍ គំនូសប្លង់អគារ ប្រព័ន្ធបច្ចេកទេស និងអគ្គីសនី ឧបករណ៍សុវត្ថិភាព និងការត្រួតពិនិត្យជាដើម។ |
| បង្កើតប្រព័ន្ធគ្រប់គ្រង ប.វ.គ.ព.(ICT) ដ៏ល្អមួយ និងធានាស្តង់ដាសុវត្ថិភាព | ហេដ្ឋារចនាសម្ព័ន្ធសុវត្ថិភាពប្រព័ន្ធអ៊ីនធឺណែត (Cyber Security Infra-structure) និងសមត្ថភាពមន្ត្រីត្រូវបានបង្កើតឡើងនៅក្នុងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ស្របតាមស្តង់ដាគ្រប់គ្រង ប.វ.គ.ព.(ICT) ដែលពិភពលោកទទួលស្គាល់។ |
| ធានាឱ្យដំណើរការងារមាននិរន្តរភាព | ត្រូវមានការយកចិត្តទុកដាក់ជាពិសេសទៅលើយុទ្ធសាស្ត្ររក្សាសុវត្ថិភាពទិន្នន័យ (Data Security) និងទិន្នន័យបម្រុង (Data Backup) នៅក្នុងបរិបទនៃការរៀបចំផែនការដ៏ជាប់លាប់មួយ។ ដំណើរការការងារមាននិរន្តរភាព ចាំបាច់ត្រូវការរៀបចំឱ្យមានផែនការជាមុន ដូចជាក្នុងករណី ប.វ.អ.ព.(IPIS) ឈប់ដំណើរការដោយសារហេតុផលបច្ចេកទេសណាមួយជាដើម។ |
| បង្កើនសមត្ថភាពមន្ត្រីទាក់ទងនឹង ប.វ.ព.ទ.(ICT) | សមត្ថភាពទាក់ទងនឹង ប.វ.គ.ព.(ICT) ត្រូវតែប្រមូលផ្តុំនៅក្នុងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ហើយសមត្ថភាពនៃនាយកដ្ឋានគ្រប់គ្រងព័ត៌មានវិទ្យារបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក៏ត្រូវតែពង្រឹង និងលើកកម្ពស់តាមរយៈការកសាងសមត្ថភាពថ្មីៗ ដូចបានពណ៌នានៅក្នុងវិធីសាស្ត្រអភិបាលកិច្ច ប.វ.គ.ព.(ICT) ដែលក្នុងនោះរួមមានសមត្ថភាពគ្រប់គ្រងកម្មវិធី (Project Management Capacity) ស្ថាបត្យកម្ម ប.វ.គ.ព.(ICT) (ICT Architecture) សុវត្ថិភាពប្រព័ន្ធអ៊ីនធឺណែត (Cyber Security) និងបច្ចេកវិទ្យាច្នៃប្រឌិតថ្មីៗ ព្រមទាំងវិធីសាស្ត្រផ្សេងៗទៀត។ |

## ៦.៤. គោលបំណងទី៤ ៖ ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឯកភាពបែងចែកទិន្នន័យពលរដ្ឋ

### *៦.៤.១. គោលដៅទី១ ៖ បង្កើតប្រព័ន្ធបែងចែកទិន្នន័យ ឱ្យបានត្រឹមឆ្នាំ២០២០*

ប្រព័ន្ធបែងចែកទិន្នន័យត្រូវដាក់ឱ្យប្រើប្រាស់បន្ទាប់ពីបានពិនិត្យឃើញ និងមានជឿជាក់ថាប្រព័ន្ធ ប.វ.អ.ព.(IPIS) ពិតជាមានប្រតិបត្តិការដោយជោគជ័យ និងបានប្រមូលផ្តុំនូវកំណត់ត្រាដែលគួរឱ្យទុកចិត្តបានអំពីប្រជាពលរដ្ឋ រួមទាំងអាចកំណត់អត្តសញ្ញាណពិសេសសម្រាប់មនុស្សគ្រប់រូបតាមរយៈ ល.ក.អ.ខ.(KIDC)។ ប្រព័ន្ធ

បែងចែកទិន្នន័យគឺជាប្រព័ន្ធទិន្នន័យដាច់ដោយឡែកមួយ និងជាប្រព័ន្ធកម្មវិធីមួយដែលគាំទ្រដល់ដំណើរការលំហូរនៃការផ្តល់ទិន្នន័យ ការធ្វើសវនកម្ម និងគណនេយ្យ និងការស្តុកទុកទិន្នន័យតាមរបៀបដ៏មានប្រសិទ្ធភាពមួយដែលអាចឆ្លើយតបបានឆាប់រហ័សទៅនឹងបញ្ហាដែលមាននៅក្នុងប្រព័ន្ធទិន្នន័យ។ ការគ្រប់គ្រងអ្នកប្រើប្រាស់ត្រូវតែជាចំណែកមួយនៃប្រព័ន្ធបែងចែកទិន្នន័យនេះ។ ប្រព័ន្ធនេះត្រូវតែគាំទ្រដល់ការចោទសួរនៅតាមប្រព័ន្ធអ៊ីនធឺណេត ក៏ដូចជាតាមច្រកផ្តល់ព័ត៌មានផ្សេងៗទៀតដែរ។

**តារាងទី១៦**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
|---|---|
| បង្កើតរចនាសម្ព័ន្ធគ្រប់គ្រងនិងសមត្ថភាពក្នុងការផ្តល់ទិន្នន័យ | ត្រូវបង្កើតអង្គភាពមួយស្ថិតនៅក្រោមអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មឱ្យទទួលភារកិច្ចបង្កើតប្រព័ន្ធបែងចែកទិន្នន័យនេះ ហើយនិងទទួលខុសត្រូវទៅលើប្រតិបត្តិការប្រព័ន្ធនេះទាំងស្រុង។ រចនាសម្ព័ន្ធគ្រប់គ្រង និងមន្ត្រីនៃអង្គភាពនេះ ត្រូវតែរៀបចំបង្កើតឡើងឱ្យបានត្រឹមត្រូវ។ សមត្ថភាពធនធានមនុស្សត្រូវតែអភិវឌ្ឍ ជាពិសេសការអភិវឌ្ឍសមត្ថភាពលើការដោះស្រាយ សំណើសុំព័ត៌មាន ធ្វើទំនាក់ទំនងជាមួយអ្នកប្រើប្រាស់ព័ត៌មាន ការពិគ្រោះយោបល់ និងប្រតិបត្តិការ។ |
| រៀបចំបង្កើតនីតិវិធី និងយន្តការបញ្ចេញទិន្នន័យ | ព័ត៌មានស្តីពីប្រជាពលរដ្ឋត្រូវតែរក្សាការសម្ងាត់ និងអាចបញ្ចេញឱ្យដល់តែអ្នកប្រើប្រាស់ដែលទទួលបានការអនុញ្ញាតតែប៉ុណ្ណោះ ពោលគឺផ្តល់ឱ្យតែអ្នកប្រើប្រាស់ដែលជាប់កិច្ចសន្យាជាមួយនឹងល័ក្ខខ័ណ្ឌរក្សាការសម្ងាត់តែប៉ុណ្ណោះ។ ទម្រង់ និងចំនួនព័ត៌មានបុគ្គលផ្តល់ឱ្យសម្រាប់ធ្វើការផ្ទៀងផ្ទាត់ គឺត្រូវកំណត់នៅក្នុងច្បាប់ពាក់ព័ន្ធ។ ត្រូវតែកំណត់ឱ្យច្បាស់ពីផលិតផលព័ត៌មាន ជាមួយនឹងនីតិវិធីនៃការប្រគល់ព័ត៌មាន ចាប់ពីដំណាក់កាលស្នើសុំព័ត៌មាន រហូតដល់អ្នកស្វែងរកទិន្នន័យបានទទួលព័ត៌មានចុងក្រោយ ហើយនិងភ្ជាប់នូវល័ក្ខខ័ណ្ឌបង់ប្រាក់ផង។ ការអភិវឌ្ឍប្រព័ន្ធ ប.វ.គ.ព.(ICT) ក៏ត្រូវតែគិតគូរឱ្យគ្របដណ្តប់លើបច្ចេកទេសគាំទ្រយន្តការបញ្ចេញទិន្នន័យនេះ ដើម្បីអាចឆ្លើយឆ្លងចម្ងល់ផ្សេងៗ ការប្រគល់ទទួលព័ត៌មាន ការគ្រប់គ្រងអ្នកប្រើប្រាស់ និងអនុវត្តមុខងារចាំបាច់ដទៃទៀត ដែលបានកំណត់នៅក្នុងអំឡុងពេលធ្វើការវិភាគលើប្រព័ន្ធ លក្ខណៈបច្ចេកទេស និងការរចនាតុបតែងជាដើម។ |
| ធានាសុវត្ថិភាព និងការប្រើប្រាស់ទិន្នន័យ | តម្រូវការសុវត្ថិភាពអ៊ីនធឺណែត (Cybersecurity) ត្រូវដាក់បញ្ចូល និងគោរពតាមដូចបណ្តាប្រព័ន្ធដទៃៗទៀតដែរ ទាំងប្រព័ន្ធកំពុងដំណើរការ និងប្រព័ន្ធមិនទាន់ដំណើរការ។ ការដាក់បញ្ចូលនេះត្រូវតែអនុវត្តយ៉ាងម៉ត់ចត់តាមគោលការណ៍ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌច្បាប់។ |

### ៦.៤.២. គោលដៅទី២ ៖ បំពេញតាមសំណូមពរស្នើសុំព័ត៌មានឱ្យបានពីរលានដងក្នុងមួយឆ្នាំ ឱ្យបានត្រឹមឆ្នាំ២០២៤

គោលបំណងនៃប្រព័ន្ធបែងចែកទិន្នន័យ គឺដើម្បីបម្រើដល់បញ្ហាសំខាន់ៗមួយចំនួនសម្រាប់ការផ្ទៀងផ្ទាត់អត្តសញ្ញាណ និងរបាយការណ៍នានា។ យ៉ាងហោចណាស់ក៏មានសំណូមពរស្នើសុំព័ត៌មានចំនួនពីរលានដងនឹងបានទទួលក្នុងមួយឆ្នាំដែរ នៅត្រឹមឆ្នាំ២០២៤។ ដើម្បីសម្រេចបានសមិទ្ធផលនេះ កិច្ចខិតខំប្រឹងប្រែងជាច្រើនត្រូវតែធ្វើឡើងដើម្បីលើកកម្ពស់ការយល់ដឹង ការធ្វើកិច្ចសន្យា និងការអប់រំអំពីការប្រើប្រាស់ទិន្នន័យ និងនីតិវិធីនៃផ្ដល់ទិន្នន័យទាំងអស់នេះ។

**តារាងទី១៧**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
|---|---|
| កសាងទំនាក់ទំនងដោយភ្ជាប់កិច្ចសន្យាជាមួយភាគីពាក់ព័ន្ធសម្រាប់ការផ្ដល់ទទួលទិន្នន័យ | កិច្ចព្រមព្រៀងជាមួយអ្នកទទួលព័ត៌មាន ត្រូវតែរៀបចំបង្កើតឡើង និងចុះហត្ថលេខា មុនពេលដែលមានការបញ្ចេញព័ត៌មានណាមួយ។ កិច្ចព្រមព្រៀងត្រូវតែបញ្ជាក់ឱ្យបានច្បាស់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ប្រព័ន្ធប្រតិបត្តិការបែងចែកទិន្នន័យ និងអ្នកទទួលព័ត៌មាន។ |
| កសាងទំនុកចិត្ត និងលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃការផ្ទៀងផ្ទាត់អត្តសញ្ញាណ | យុទ្ធនាការលើកកម្ពស់ការយល់ដឹងដ៏ទូលំទូលាយមួយ គួរតែរៀបចំឡើងក្នុងចំណោមអាជ្ញាធរសាធារណៈ និងផ្នែកឯកជន ដែលជាស្ថាប័នមានការពាក់ព័ន្ធនឹងទិន្នន័យប្រជាពលរដ្ឋ ដោយសារមានភាពចាំបាច់ក្នុងគ្រប់គ្រងហានិភ័យតាមរយៈការផ្ទៀងផ្ទាត់អត្តសញ្ញាណបុគ្គល តម្រូវការទិន្នន័យប្រកបដោយគុណភាព និងគោលបំណងផ្សេងៗទៀត ក៏ដូចជាដើម្បីជូនដំណឹង និងបង្ហាញពីលទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្ដីពីអត្តសញ្ញាណកម្មដែលផ្ដល់គុណតម្លៃដល់ការលើកកម្ពស់គុណភាពទិន្នន័យ និងការកសាងទំនុកចិត្តលើតម្លៃនៃព័ត៌មានបុគ្គល និងព័ត៌មានពីប្រជាពលរដ្ឋទាំងមូល។ |
| អប់រំរដ្ឋបាលសាធារណៈអំពីការប្រើប្រាស់ស្ថិតិពលរដ្ឋ | រដ្ឋបាលសាធារណៈនឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនពីស្ថិតិពលរដ្ឋសម្រាប់ស្ថាប័នខ្លួនក្នុងការរៀបចំផែនការ កម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពហេតុដូច្នេះ កម្មវិធីអប់រំលើកកម្ពស់ការយល់ដឹង ត្រូវតែរៀបចំឡើងចំពោះមន្ត្រីរាជការស៊ីវិលទាំងអស់។ កម្មវិធីអប់រំនេះ អាចធ្វើឡើងតាមវិធីផ្សេងៗគ្នា ដូចជាការបង្កើតវីដេអូអប់រំ ការធ្វើសន្និសីទវីដេអូ ព្រមទាំងរបៀបបណ្ដុះបណ្ដាលធម្មតាផងដែរ។ |

### ៦.៥. គោលបំណងទី៥ ៖ កែសម្រួលរបៀបរបបការងារ និងដាក់ឱ្យដំណើរការប្រព័ន្ធអេឡិចត្រូនិកសម្រាប់ផ្តល់សេវាជូនអតិថិជនប្រកបដោយប្រសិទ្ធភាព និងតម្លាភាព

#### *៦.៥.១. គោលដៅទី១ ៖ សម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ ឱ្យបានត្រឹមឆ្នាំ២០១៧*

ការចុះបញ្ជីអត្រានុកូលដ្ឋាន និងការផ្តល់សេវាផ្សេងៗទៀតទាក់ទងទៅនឹងការចេញឯកសារអត្តសញ្ញាណ អាចនឹងធ្វើឡើងកាន់តែល្អប្រសើរថែមទៀត ដោយសារការផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋបានចូលរួមកាន់តែសកម្ម នៅក្នុងដំណើរការផ្តល់សេវា។ ការកែលម្អសេវាកម្មនេះត្រូវធ្វើឡើងតាមរយៈការផ្តល់លទ្ធភាពឱ្យប្រជាពលរដ្ឋមាន លទ្ធភាពចូលរួមផ្តល់មតិយោបល់ត្រលប់អំពីការផ្តល់សេវានៅមូលដ្ឋាន ដែលនេះគឺជាការផ្តល់ឱកាសមួយក្នុងការ លើកកម្ពស់ការបំពេញការងារឱ្យកាន់តែប្រសើរជាងមុន តាមរយៈការរៀបចំកែសម្រួលរបៀបរបបការងារផ្ទៃក្នុង ដើម្បីឆ្លើយតបឱ្យសកម្មទៅនឹងបញ្ហានោះ។ លទ្ធភាពក្នុងការផ្តល់យោបល់ត្រលប់ក៏រួមចំណែកដល់ការកសាង ទំនុកចិត្តនៅក្នុងស្ថាប័ន និងសេវាកម្មដែលត្រូវផ្តល់ឱ្យនោះផងដែរ។ សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ក៏ជាតួអង្គដ៏សំខាន់នៅក្នុងការតភ្ជាប់តម្រូវការរបស់ប្រជាពលរដ្ឋទៅនឹងការផ្តល់សេវាកម្ម ដូច្នេះកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលជាមួយនឹងតួអង្គទាំងអស់នោះត្រូវតែរក្សាឱ្យបានរឹងមាំតាមរយៈរចនាសម្ព័ន្ធអភិបាលកិច្ចសម្រាប់អនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ នេះ។

**តារាងទី១៨**

| **សកម្មភាព** | **ការពណ៌នាសកម្មភាព** |
|---|---|
| ធានាឱ្យមានការចូលរួមពីសង្គមស៊ីវិល និង អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងរចនាសម្ព័ន្ធ គ្រប់គ្រងការងារអត្រានុកូលដ្ឋាន និងស្ថិតិ អត្រានុកូលដ្ឋាន | សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល គួរតែជាផ្នែកមួយនៃរចនាសម្ព័ន្ធអភិបាលកិច្ចការងារអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ហើយកិច្ចសហប្រតិបត្តិការនេះត្រូវធ្វើឡើងក្នុងគោលបំណងសម្របសម្រួលឱ្យមានការចូលរួមពីប្រជាពលរដ្ឋ និងការប្រមូលព័ត៌មានត្រលប់ពីប្រជាពលរដ្ឋ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើក្រុមគោលដៅមួយចំនួនដែលពិបាកក្នុងការទទួលបានសេវា ឬក៏ក្រុមជនដែលមិនសូវទទួលបានការយកចិត្តទុកដាក់គ្រប់គ្រាន់។ |
| ដាក់ឱ្យប្រើប្រាស់សេវាទូរស័ព្ទឥតគិតថ្លៃ សម្រាប់ទទួលព័ត៌មានត្រលប់ពីប្រជាពលរដ្ឋ | ការបើកឱ្យមានការប្រើប្រាស់សេវាទូរស័ព្ទឥតគិតថ្លៃនេះ គឺជាការផ្តល់នូវលទ្ធភាពដល់អតិថិជនក្នុងការផ្តល់យោបល់ត្រលប់ អំពីការផ្តល់សេវាកម្ម ក៏ដូចជាដើម្បីទទួលបានព័ត៌មានអំពីដំណើរការ និងនីតិវិធីដែលត្រូវតែធ្វើតាមនៅក្នុងអំឡុងពេលចុះបញ្ជី ឬការចេញឯកសារអត្តសញ្ញាណ និងតម្រូវការផ្លូវច្បាប់ផ្សេងៗទៀត។ ប្រសិនបើមានលទ្ធភាព ជម្រើសតាមប្រព័ន្ធអ៊ីនធឺណែតសម្រាប់ការទទួលមតិយោបល់ត្រលប់នោះក៏អាចអនុវត្តបានផងដែរ។ |
| យុទ្ធនាការប្រកាសព័ត៌មានអំពីខ្សែទូរស័ព្ទឥតគិតថ្លៃ និងលទ្ធភាពនៅក្នុងការផ្តល់ព័ត៌ | យុទ្ធនាការប្រកាសព័ត៌មានគួរតែត្រូវធ្វើឡើងឱ្យបានមុនពេលដាក់ឱ្យប្រើប្រាស់ខ្សែទូរស័ព្ទឥតគិតថ្លៃ ក្នុងគោលបំណងបង្ហាញឱ្យសាធារណៈជន |

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| មានត្រលប់អំពីការចុះបញ្ជីអត្រានុកូលដ្ឋាន និងសេវាផ្សេងៗទៀត | បានដឹងជាមុនពីលទ្ធភាពក្នុងការផ្ដល់មតិយោបល់ទៅលើសេវាកម្ម ហើយក៏អាចទទួលបានព័ត៌មានសំខាន់ៗនានាអំពីការចុះបញ្ជី និងតម្រូវការដែលមានការពាក់ព័ន្ធផ្សេងៗផងដែរ។ |
| រៀបចំកែសម្រួលរបៀបរបបការងារផ្ទៃក្នុងចំពោះយោបល់ត្រលប់ពីប្រជាពលរដ្ឋ | ត្រូវរៀបចំបង្កើតនីតិវិធីក្នុងការឆ្លើយតបចំពោះមតិត្រលប់របស់ប្រជាពលរដ្ឋ និងយន្តការស្ថាប័នដើម្បីដោះស្រាយនូវបញ្ហាដែលជាការព្រួយបារម្ភទាំងអស់នោះ។ |

## ៦.៩.២. *គោលដៅទី២ ៖ កែសម្រួលរបៀបរបបការងារសម្រាប់លើកកម្ពស់ការផ្ដល់សេវាកម្ម ឱ្យបានត្រឹមឆ្នាំ២០១៧*

ដើម្បីនាំយកនូវសេវាអតិថិជនឱ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋ និងបន្តកែលម្អគុណភាពសេវានោះ ការរៀបចំការផ្ដល់សេវានឹងត្រូវធ្វើឡើងតាមបែបវិមជ្ឈការ និងត្រូវប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់។ ការិយាល័យច្រកចេញចូលតែមួយបានបង្ហាញថា ជាមណ្ឌលសេវាកម្មរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ព្រមទាំងមានការវាយតម្លៃខ្ពស់ពីអតិថិជន។ ដូច្នេះ នៅក្នុងរយៈពេលខ្លី សេវាខ្លះដែលទាក់ទងទៅនឹងការចុះបញ្ជី និងការងារអត្តសញ្ញាណកម្ម ត្រូវតែចាប់ផ្ដើមធ្វើឡើងតាមការិយាល័យច្រកចេញចូលតែមួយ ខណៈពេលដែលត្រូវរៀបចំផែនការបន្ថែមទៀតដើម្បីកសាងមូលដ្ឋានសម្រាប់បង្កលទ្ធភាពឱ្យមានការផ្ដល់សេវាចុះបញ្ជី និងសេវាអត្តសញ្ញាណកម្មភាគច្រើនបំផុតធ្វើឡើងតាមច្រកចេញចូលតែមួយ។ គោលបំណងក្នុងរយៈពេលវែងគឺត្រូវរៀបចំការផ្ដល់សេវាកម្មតាមរយៈមន្ត្រីរាជការស៊ីវិលដែលមានគុណសម្បត្តិគ្រប់គ្រាន់ ដោយត្រូវបែងចែកតួនាទីឱ្យមន្ត្រីរាជការស៊ីវិលជាអ្នកទាក់ទងផ្ទាល់ជាមួយនឹងអតិថិជន (ធ្វើឡើងនៅការិយាល័យជួរមុខ) និងមន្ត្រីជំនាញឯកទេសជាអ្នកផ្ដល់សេវាកម្ម (ធ្វើឡើងនៅការិយាល័យជួរក្រោយ) នៅកម្រិតមូលដ្ឋាន។

**តារាងទី១៩**

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| ការផ្ដល់សេវាតាមច្រកចេញចូលតែមួយ | នៅតាមថ្នាក់រដ្ឋបាលដែលមានការិយាល័យច្រកចេញចូលតែមួយស្រាប់ ត្រូវចាប់ផ្ដើមផ្ដល់សេវាស្នើសុំធ្វើអត្តសញ្ញាណប័ណ្ណ និងសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ នៅតាមច្រកចេញចូលតែមួយទាំងនោះ។ ក៏ត្រូវពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មទៅលើបទប្បញ្ញត្តិនានាសម្រាប់ការផ្ដល់សេវាតាមរយៈច្រកចេញចូលតែមួយនេះដែរ។ |
| រៀបចំផែនការផ្ដល់សេវាអត្តសញ្ញាណកម្មទាំងអស់តាមរយៈការិយាល័យច្រកចេញចូលតែមួយ | រៀបចំផែនការដើម្បីផ្ដល់សេវាចុះបញ្ជីអត្រានុកូលដ្ឋាន និងការផ្ដល់ឯកសារអត្តសញ្ញាណកម្មទាំងអស់តាមរយៈការិយាល័យច្រកចេញចូលតែមួយ។ ចំពោះការចុះបញ្ជីអត្រានុកូលដ្ឋាន និងសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ ក៏អាចនៅតែបន្តធ្វើនៅតាមទីតាំងដែលធ្លាប់បានផ្ដល់ |

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| | សេវាកម្មនេះកន្លងមក ដែលជាការបង្កើតទីតាំងផ្តល់សេវាឱ្យកាន់តែច្រើនសម្រាប់អ្នកទទួលសេវា។ |
| រៀបចំផែនការចម្លងយន្តការការិយាល័យច្រកចេញចូលតែមួយនៅតាមរដ្ឋបាលមូលដ្ឋាននានា | រៀបចំផែនការចម្លងយន្តការការិយាល័យច្រកចេញចូលតែមួយ និងដាក់ឱ្យដំណើរការយន្តការនេះនៅតាមចំណុចផ្តល់សេវាកម្មនៅថ្នាក់ឃុំ សង្កាត់ ក្នុងគោលបំណងដើម្បីឱ្យការផ្តល់សេវាកម្មនេះត្រូវធ្វើឡើងតាមរយៈមន្ត្រីរដ្ឋបាលស៊ីវិល ដោយគិតទាំងការចុះបញ្ជីស្នាក់នៅ និងបញ្ជីគ្រួសារផងដែរ។ |
| កសាងសមត្ថភាព និងយន្តការតាមដានត្រួតពិនិត្យ | កសាងសមត្ថភាពក្នុងការិយាល័យច្រកចេញចូលតែមួយ និងបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ តាមរយៈយន្តការស្ថាប័នដែលមានការឆ្លើយតប និងមានការទទួលខុសត្រូវដើម្បីត្រួតពិនិត្យគុណភាព។ |

### ៦.៥.៣.គោលដៅទី៣ ៖ ណែនាំឱ្យប្រើប្រាស់សេវាកម្មតាមប្រព័ន្ធអេឡិចត្រូនិច ឱ្យបានត្រឹមឆ្នាំ ២០២១

រាជរដ្ឋាភិបាលកម្ពុជាបានយល់ និងខិតខំស្វែងរកអត្ថប្រយោជន៍ពីការគ្រប់គ្រងរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិច ដែលក្នុងនោះរួមមានការផ្តល់សេវាកម្មសាធារណៈបានដល់ជនគ្រប់រូប គ្រប់ទីកន្លែង គ្រប់ពេលវេលា ដោយមិនមានការលំបាកដែលធ្លាប់មានជាប្រពៃណីកន្លងមក ដូចជាបញ្ហាពេលវេលា និងទីកន្លែងទទួលសេវាជាដើម។ ការប្រើប្រាស់ប្រព័ន្ធ ប.វ.គ.ព.(ICT) និយាយជារួម និងនិយាយដោយឡែក ការប្រើប្រាស់បច្ចេកវិទ្យាចល័ត (Tablet) គឺកំពុងតែមានភាពរីកចម្រើនជាទូទៅនៅក្នុងប្រទេស ដូច្នេះការផ្តល់សេវាកម្មតាមប្រព័ន្ធអេឡិចត្រូនិចនៅក្នុងវិស័យចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម គឺជាជំហានបន្ទាប់ដែលត្រូវចាប់យកដើម្បីបំពេញគោលបំណងនៅក្នុងការលើកកម្ពស់តម្លាភាព ប្រសិទ្ធផល និងប្រសិទ្ធភាពនៅក្នុងការផ្តល់សេវាកម្មជូនប្រជាពលរដ្ឋ។ ការណែនាំឱ្យប្រើប្រាស់ប្រព័ន្ធ ប.វ.គ.ព.(ICT) សម្រាប់បម្រើឱ្យការចុះបញ្ជី និងការងារអត្តសញ្ញាណកម្មទាំងអស់ នឹងបណ្តាលឱ្យដំណើរការផ្នែកស្ថាប័នដែលពាក់ព័ន្ធនឹងផ្តល់សេវាកម្មទាំងអស់ ត្រូវងាកមកធ្វើឡើងតាមទម្រង់ជាអេឡិត្រូនិចវិញ។

**តារាងទី២០**

| សកម្មភាព | ការពណ៌នាសកម្មភាព |
|---|---|
| រៀបចំរបៀបរបបការងារផ្ទៃក្នុងសម្រាប់ដំណើរការតាមប្រព័ន្ធអេឡិចត្រូនិច | ត្រូវរៀបចំនូវរបៀបរបបការងារផ្ទៃក្នុងមួយ ដោយផ្អែកទៅលើទម្រង់ ប.វ.គ.ព.(ICT) នៅក្នុងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ជាមួយនឹងសង្វាក់ការអនុវត្តការងារប្រកបដោយការទទួលខុសត្រូវច្បាស់លាស់ មាននីតិវិធីតាមដានត្រួតពិនិត្យ និងប្រព័ន្ធរបាយការណ៍ជាក់លាក់មួយ។ |
| ដាក់ឱ្យដំណើរការសេវាកម្មចុះបញ្ជីអត្រានុ | សេវាចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះបញ្ជីការស្នាក់នៅ គួរធ្វើតាម |

| សកម្មភាព | ការពណ៌នាសកម្មភាព |
| --- | --- |
| កូលដ្ឋាន និងការចុះបញ្ជីស្នាក់នៅតាមប្រព័ន្ធអេឡិចត្រូនិច | ប្រព័ន្ធអេឡិចត្រូនិច ចំពោះអ្នកដែលមានលទ្ធភាពចុះបញ្ជី និងការស្នើសុំឯកសារពាក់ព័ន្ធ។ សេវាទាំងនេះនឹងត្រូវពង្រីកជាមួយនឹងសេវាជូនដំណឹងសម្រាប់ការចុះបញ្ជីអត្រានុកូលដ្ឋាន ដែលអាចឱ្យអ្នកស្នើសុំអាចចុះបញ្ជីព្រឹត្តិការណ៍រស់នៅរបស់ខ្លួនដោយមិនចាំបាច់មានវត្តមានដោយផ្ទាល់នៅកន្លែងចុះបញ្ជី។ ការបញ្ជាក់អត្តសញ្ញាណតាមរយៈប្រព័ន្ធអេឡិចត្រូនិច ដូចជាហត្ថលេខាឌីជីថល គួរតែត្រូវបានដាក់ឱ្យប្រើប្រាស់។ |
| ដាក់ឱ្យដំណើរការប្រព័ន្ធបង់ប្រាក់អេឡិចត្រូនិចសម្រាប់សេវាកម្មទាំងអស់ | ត្រូវបើកឱ្យមានគណនីនៅតាមធនាគារដើម្បីបម្រើឱ្យការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិចសម្រាប់ទូទាត់ការបង់ថ្លៃចុះបញ្ជីអត្រានុកូលដ្ឋាន និងផ្តល់ឯកសារអត្តសញ្ញាណកម្មទាំងអស់ ក៏ដូចជាសម្រាប់ការផ្ទេរប្រាក់បង់ថ្លៃការចុះបញ្ជី និងឯកសារអត្តសញ្ញាណកម្មនានាតាមប្រព័ន្ធអេឡិចត្រូនិច ព្រមទាំងសម្រាប់សេវាកម្មដែលពាក់ព័ន្ធទៅនឹងការផ្ទៀងផ្ទាត់ព័ត៌មានប្រជាពលរដ្ឋផងដែរ។ |

## VII. អភិបាលកិច្ច និងការតាមដានត្រួតពិនិត្យ

ការអនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ នេះ នឹងត្រូវធ្វើឡើងដោយមានការតាមដានត្រួតពិនិត្យនិងសម្របសម្រួលពីគណៈកម្មាធិការជាតិដឹកនាំតម្រង់ទិសការងារអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកលដ្ឋាន និងអត្តសញ្ញាណកម្ម ( គ.ជ.ជ.អ. ) ( National Steering Committee on CRVS and Identification - NSCI ) មួយ ដែលរួមមានតំណាងមកពីអ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់។

គ.ជ.ជ.អ ( NSCI ) ត្រូវបង្កើតឡើងដោយរាជរដ្ឋាភិបាល និងត្រូវមានសមាសភាពដឹកនាំដូចខាងក្រោម ៖

- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន
- រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកការងារអត្តសញ្ញាណកម្ម ជាអនុប្រធាន
- អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ជាសមាជិកអចិន្ត្រៃយ៍
- រដ្ឋលេខាធិការក្រសួងផែនការ០១រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងយុត្តិធម៌០១រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងសុខាភិបាល០១រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ០១រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងការបរទេសនិងទំនាក់ទំនងអន្តរជាតិ០១រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងក្រសួងកិច្ចការនារី០១រូប ជាសមាជិក
- តំណាងរបស់អង្គការសង្គមស៊ីវិលធ្វើការក្នុងវិស័យអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋាន០១រូប ជាសមាជិក
- តំណាងដៃគូអភិវឌ្ឍន៍០១រូប ជាសមាជិក។

នៅពេលដែលការអនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ នេះមានការរីកចម្រើន គណៈកម្មាធិការជាតិនេះអាចនឹងពង្រីកបន្ថែមសមាសភាពមកពីតំណាងក្រសួង ស្ថាប័នមួយចំនួនទៀតដូចខាងក្រោម ៖

- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា០១រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងប្រៃសនីយ៍ និងទូរគមនាគមន៍០១រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា០១រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ០១រូប ជាសមាជិក
- រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ០១រូប ជាសមាជិក និង
- ភាគីពាក់ព័ន្ធផ្សេងៗទៀត។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវដើរតួនាទីជាលេខាធិការដ្ឋាននៃ គ.ជ.ជ.អ.( NSCI ) និងមានភារកិច្ចជួយរៀបចំលិខិតអញ្ជើញ ឯកសារ សម្ភារៈសម្រាប់កិច្ចប្រជុំតាមកាលវិភាគដែលបានគ្រោងទុក ដើម្បីសម្រេចឱ្យបាននូវគោលបំណងយុទ្ធសាស្ត្រទាំងឡាយ។ គ.ជ.ជ.អ.( NSCI ) ត្រូវប្រជុំរៀងរាល់០៦ខែម្តងដើម្បីពិនិត្យមើលឡើងវិញពីសូចនាករសំខាន់ៗដែលបានទទួលបានពីការអនុវត្ត ផ.យ.ជ.អ.២០១៥-២០២៤ និងដោះស្រាយបញ្ហាប្រឈមនានាដែលបានជួបប្រទះ។

សម្រាប់ការអនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ នេះ ក្រុមការងារបច្ចេកទេសអន្តរក្រសួងថ្នាក់ជាតិសម្រាប់អនុវត្តកម្មវិធី ( ក.ប.អ.ក. ) ( Technical Program Implementation Team - TPIT ) នឹងត្រូវបង្កើតឡើង

ដើម្បីសម្របសម្រួលការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ ហើយសមាសភាពនៃក្រុមការងារនេះត្រូវមានតំណាងថ្នាក់អគ្គនាយករង និងប្រធាននាយកដ្ឋាន មកពីក្រសួងជាសមាជិក គ.ជ.ជ.អ.(NSCI) ខាងលើនេះ រួមនឹងតំណាងមកពីស្ថាប័នដទៃទៀតដែលចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រ បូកជាមួយតំណាងមកពីរដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់) ក៏ដូចជាតំណាងអង្គការសង្គមស៊ីវិលធ្វើការក្នុងវិស័យអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និងសហគមន៍ម្ចាស់ជំនួយ។ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវដឹកនាំក្រុមការងារនេះ និងត្រូវមានតំណាងជាអ្នកគ្រប់គ្រងចំនួនបីរូបយ៉ាងតិច។ ក.ប.អ.ក.(TPIT) នេះត្រូវជួបប្រជុំយ៉ាងហោចណាស់បី(០៣)ខែម្តង។

## ៧.១. មុខងារ និងការទទួលខុសត្រូវ

ផ.យ.ជ.អ.២០១៥-២០២៤ គឺជាផែនការដ៏ស្មុគស្មាញ និងប្រកបដោយមហិច្ឆតា។ ផែនការនេះនឹងគ្របដណ្តប់រយៈពេល១០ឆ្នាំ លើការបង្កើតមុខងារថ្មីៗ ការកែលម្អនូវមុខងារមួយចំនួនផ្សេងទៀត ការអភិវឌ្ឍនិងការប្រើប្រាស់ដំណោះស្រាយដែលផ្អែកទៅលើប្រព័ន្ធ ប.វ.គ.ព.(ICT)។ ក្រៅពីការបង្កើត និងការរួមចំណែកដោយផ្ទាល់នៃមុខងារទាំងអស់នេះ ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះនឹងមានផលប៉ះពាល់យ៉ាងសំខាន់ទៅលើការជានាអះអាងនៅគ្រប់កម្រិតក្នុងចំណោមស្ថាប័ននានាដែលកន្លងមកពុំមានការភ្ជាប់ទំនាក់ទំនងផ្លូវការជាមួយគ្នា។ ការអនុវត្តផែនការយុទ្ធសាស្ត្រនឹងបង្កើតបាននូវប្រភពព័ត៌មានមួយដ៏មានតម្លៃ និងទុកចិត្តបាន អំពីមនុស្សគ្រប់រូបនៅក្នុងប្រទេសកម្ពុជា ដូច្នេះរាល់ស្ថាប័នទាំងអស់ដែលនឹងត្រូវប្រើប្រាស់ទិន្នន័យប្រជាពលរដ្ឋ ត្រូវទទួលឥទ្ធិពលក្នុងការផ្លាស់ប្តូរសមត្ថភាព និងដំណើរការនានាឱ្យស្របតាម ផ.យ.ជ.អ.២០១៥-២០២៤ នេះ។

ការផ្លាស់ប្តូរទាំងអស់ចាំបាច់ត្រូវមានការវាយតម្លៃ និងគ្រប់គ្រងដើម្បីធានាឱ្យមានការសម្របសម្រួលក្នុងការអនុវត្តផែនការនេះបានយ៉ាងល្អប្រសើរ។ ទោះបីជានៅពេលដែលឆន្ទៈនយោបាយមានកម្រិតខ្ពស់ និងបានកំណត់ច្បាស់លាស់ក៏ដោយ ក៏ការអនុវត្តអាចជួបនឹងឧបសគ្គមួយចំនួនប្រសិនបើរចនាសម្ព័ន្ធអភិបាលកិច្ចទាំងអស់មិនបានពិចារណាឱ្យបានពេញលេញនោះទេ។

នៅក្នុងរចនាសម្ព័ន្ធដែលមានភាពស្មុគស្មាញលើការទទួលខុសត្រូវ និងអន្តរកម្មនៃស្ថាប័នសាធារណៈបែបនេះ ត្រូវតែកំណត់អាណត្តិនៃស្ថាប័ននីមួយៗឱ្យបានច្បាស់លាស់ និងត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់។ ការអនុវត្តត្រូវតែទទួលបានការគាំទ្រពីរចនាសម្ព័ន្ធអភិបាលកិច្ចពាក់ព័ន្ធតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ប្រតិបត្តិ រួមមាន ៖

- ការបង្កើតឱ្យមានផែនការសកម្មភាពច្បាស់លាស់នៅថ្នាក់ជាតិ ជាមួយនឹងកាលបរិច្ឆេទផុតកំណត់នៃសកម្មភាពនីមួយៗ ដោយចាត់តាំងឱ្យមានមន្ត្រីជាន់ខ្ពស់ជាអ្នកទទួលខុសត្រូវអនុវត្ត។
- ត្រូវកំណត់អាណត្តិច្បាស់លាស់នៅក្នុងខ្សែសង្វាក់ប្រតិបត្តិការចាប់ពីថ្នាក់ក្រោមឡើងទៅ ធ្វើបែបនេះនាំឱ្យការទទួលខុសត្រូវ និងសមិទ្ធផលមានលក្ខណៈជាក់លាក់។
- ត្រូវធ្វើការតាមដាននូវវឌ្ឍនភាព និងពិនិត្យមើលថាសកម្មភាពទាំងអស់អនុវត្តបានត្រឹមត្រូវដើម្បីកុំឱ្យមានការបរាជ័យ។

### ៧.២.អំពីអាណត្តិ

ប្រការសំខាន់ត្រូវធានាថា អាណត្តិការងារនានាត្រូវបានកំណត់ និងបែងចែកច្បាស់លាស់ពីរាជរដ្ឋាភិបាល ពោលគឺចាប់ពីអាណត្តិរបស់ស្ថាប័នដែលបង្កើតផែនការយុទ្ធសាស្ត្រជាតិនេះ រហូតដល់រចនាសម្ព័ន្ធខាងក្រោមទាំងអស់។ ការអនុវត្តផែនការយុទ្ធសាស្ត្រជាតិនេះ គឺជាផែនការនៃការផ្លាស់ប្តូរលើសមាសធាតុជាច្រើន ដូចជារចនាសម្ព័ន្ធ និងការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្ន ដែលត្រូវតែផ្លាស់ប្តូរឱ្យបានសមស្រប។ ដូច្នេះ អាណត្តិត្រូវតែបែងចែកនៅក្នុងចំណោមស្ថាប័នដែលមានការទទួលខុសត្រូវ និងមានសមត្ថកិច្ចទៅលើការចាត់ចែងការងារជាក់លាក់មួយចំនួន។ ការតាមដានត្រួតពិនិត្យ និងការធ្វើរបាយការណ៍ជាទៀងទាត់ នឹងជួយជំរុញទឹកចិត្តស្ថាប័ន និងមន្ត្រី ឱ្យបំពេញភារកិច្ចតាមអាណត្តិរបស់ពួកគេ។

### ៧.៣.អំពីរបាយការណ៍

ការធ្វើរបាយការណ៍នឹងជួយគាំទ្រដល់អាណត្តិការងារ និងផ្តល់នូវខ្សែចង្វាក់ចាំបាច់សម្រាប់ការអនុវត្ត និងការលើកទឹកចិត្ត ក៏ដូចជាផ្តល់សេណារីយ៉ូច្បាស់លាស់សម្រាប់ការចាត់ចែងសកម្មភាពផងដែរ។ ត្រូវតែយល់ថាការធ្វើរបាយការណ៍ គឺជាឱកាសមួយសម្រាប់អ្នកគ្រប់គ្រងអាចបង្ហាញការប្តេជ្ញាចិត្ត និងការលះបង់របស់ខ្លួនដល់បុព្វហេតុគ្រប់គ្រងទាំងអស់នោះ។ លើសពីនេះទៅទៀត នីតិវិធីនៃការធ្វើរបាយការណ៍ក៏ជាឱកាសមួយសម្រាប់សកម្មភាពផ្តល់នូវការលើកទឹកចិត្ត ឬក៏សម្រាប់ការកែតម្រូវផងដែរ។

ជាការសំខាន់ណាស់ដែលមន្ត្រីដែលជាអ្នកទទួលរបាយការណ៍ ត្រូវមានសេណារីយ៉ូច្បាស់លាស់មួយលើលទ្ធភាពផ្តល់យោបល់នៅក្នុងកិច្ចប្រជុំ។ ការខកខានមិនបានចាត់វិធានការលើការពន្យាពេល ឬការមិនបានបំពេញការងារណាមួយដែលបានរាយការណ៍មក គឺជាការបង្ហាញអំពីកង្វះការប្តេជ្ញាចិត្ត ហើយក្រោយមកនឹងអាចធ្វើឱ្យរចនាសម្ព័ន្ធនេះមិនអាចប្រតិបត្តិបាន។

**តារាងទី២១**

| អង្គភាព | មុខងារ | ការបែងចែកអាណត្តិ | ការធ្វើរបាយការណ៍ |
|---|---|---|---|
| **រាជរដ្ឋាភិបាល** | មានអាណត្តិទូទៅក្នុងការគ្រប់គ្រងប្រទេស។<br>អនុម័ត ផ.យ.ជ.អ. ២០១៥-២០២៤ ក្នុងគោលបំណង កសាងប្រព័ន្ធមួយទំនើប មានមុខងារល្អ និងអាចទុកចិត្តបានសម្រាប់ការងារអត្តសញ្ញាណកម្ម ដែលនឹងប្រើប្រាស់ជាប្រភពព័ត៌ | រាជរដ្ឋាភិបាលត្រូវតែងតាំង គ.ជ.ជ.អ. (NSCI) មួយដែលមានរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន ដើម្បីសម្របសម្រួល និងពិនិត្យទៅលើការអនុវត្តផែនការយុទ្ធសាស្ត្រ។ គ.ជ.ជ.អ. (NSCI) ត្រូវធ្វើរបាយការណ៍អំពីការរីកចម្រើនរៀងរាល់១២ខែម្តង។<br>គ.ជ.ជ.អ.(NSCI) មានសិទ្ធិស្នើសុំជំនួយពីទីប្រឹក្សាផ្តល់យោបល់មកពីខាងក្រៅ។ | រាជរដ្ឋាភិបាល បន្ទាប់ពីបានស្តាប់របាយការណ៍រីកចម្រើននៃការអនុវត្ត ផ.យ.ជ.អ.២០១៥-២០២៤ អាចធ្វើការពិភាក្សាវែកញែកលើរបាយការណ៍នេះ និងធ្វើការសម្រេចចិត្តអំពី ៖<br>- សេចក្តីសង្ខេបទូទៅអំពីការរីកចម្រើន ជោគជ័យ និងការពន្យារពេល<br>- ទទួលស្គាល់អ្នកបានចូលរួមចំណែកសំខាន់ៗក្នុងការងារនេះ |

| អង្គភាព | មុខងារ | ការបែងចែកអាណត្តិ | ការធ្វើរបាយការណ៍ |
|---|---|---|---|
| | មានអំពីប្រជាពលរដ្ឋតែមួយគត់ដែលអាចទុកចិត្តបាន។ | អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវបានតែងតាំងជាលេខាធិការដ្ឋាននៃ គ.ជ.ជ.អ.(NSCI)។ | - សម្រេចអំពីការចូលរួមបដិភាគ និងការប្តេជ្ញាចិត្តដែលត្រូវការពីរាជរដ្ឋាភិបាល<br>- ពិនិត្យឡើងវិញ ឬក៏អនុម័តយល់ព្រមទៅលើសេចក្តីសម្រេចដែលបានផ្តល់អនុសាសន៍ និង<br>- សំណូមពរនានាដល់ គ.ជ.ជ.អ.(NSCI)។<br>ការសម្រេច ៖<br>- ការពេញចិត្ត (ឬមិនពេញចិត្តចំពោះវឌ្ឍនភាព)<br>- អនុសាសន៍នានាដល់តួអង្គនីមួយៗដើម្បីចូលរួម<br>- ធ្វើសេចក្តីសម្រេចលើអ្វីៗដែលបានស្នើសុំ (ឬបដិសេធ)។ |
| **គ.ជ.ជ.អ.(NSCI)** | ទទួលបានអាណត្តិពីរដ្ឋាភិបាលក្នុងការសម្របសម្រួលនិងពិនិត្យមើលលើការអនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤។<br>គ.ជ.ជ.អ.(NSCI) ត្រូវប្រជុំរៀងរាល់០៦ខែម្តង ដើម្បីពិនិត្យឡើងវិញទៅលើការរីកចម្រើន និងធ្វើការសម្រេច។<br>កិច្ចប្រជុំរបស់ គ.ជ.ជ.អ.(NSCI) ត្រូវរៀបចំឡើងដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដូចជាការរៀបចំឯកសារ សម្ភារៈនិងរបៀបវារៈសម្រាប់កិច្ច | កំណត់អាណត្តិរបស់ ក.ប.អ.ក.(TPIT) ដើម្បីធ្វើការទៅលើការអនុវត្តកម្មវិធី។<br>ស្នើឱ្យធ្វើសេចក្តីរាយការណ៍បួន (០៤)ខែម្តងអំពីវឌ្ឍនភាព។<br>កំណត់អាណត្តិអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មឱ្យធ្វើជាប្រធាន ក.ប.អ.ក.(TPIT) និងស្ថាប័ននានាដើម្បីប្រតិបត្តិការងារជាក់លាក់នានា ឬពេលចាំបាច់ ត្រូវស្នើទៅរដ្ឋាភិបាលឱ្យជួយលើការងារជាក់លាក់មួយចំនួន។ | រៀងរាល់១២ខែម្តង ក.ប.អ.ក.(TPIT) ត្រូវរៀបចំរបាយការណ៍រីកចម្រើននិងបង្ហាញជូនរាជរដ្ឋាភិបាល។ របាយការណ៍ទៅរាជរដ្ឋាភិបាលត្រូវដាក់ជូនដោយក្រសួងមហាផ្ទៃ។<br>ពិនិត្យមើលពីរបាយការណ៍រីកចម្រើនរបស់ ក.ប.អ.ក.(TPIT) រៀងរាល់៦ខែម្តង។<br>ក្នុងអំឡុងពេលនៃកិច្ចប្រជុំទៀងទាត់ត្រូវធ្វើការពិភាក្សា និងសម្រេចចិត្តទៅលើ ៖<br>- សង្ខេបទូទៅនៃការរីកចម្រើន ភាពជោគជ័យ និងការពន្យារពេល<br>- ទទួលស្គាល់អ្នកដែលបានចូលរួមចំណែកសំខាន់ៗ |

| អង្គភាព | មុខងារ | ការបែងចែកអាណត្តិ | ការធ្វើរបាយការណ៍ |
| --- | --- | --- | --- |
| | ប្រជុំ។ល។ | | - ធ្វើសេចក្តីសម្រេចលើសំណើនានារបស់ ក.ប.អ.ក.(TPIT)។ សេចក្តីសម្រេចចិត្ត ៖ - ការពេញចិត្ត (ឬមិនពេញចិត្តចំពោះវឌ្ឍនភាព) - ផ្តល់អនុសាសន៍ទៅឱ្យភាគីផ្សេងៗទៀតឱ្យចូលរួមចំណែក - ធ្វើការសម្រេចទៅលើសំណូមពររបស់ ក.ប.អ.ក.(TPIT)។ |
| **ក.ប.អ.ក.(TPIT)** | ទទួលបានអាណត្តិពី គ.ជ.ជ.អ.(NSCI) ដើម្បីដឹកនាំ និងតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធី។ ក.ប.អ.ក.(TPIT) ត្រូវដឹកនាំដោយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។ រាល់កម្មវិធីទាំងអស់ស្ថិតនៅក្រោមផែនការយុទ្ធសាស្ត្រជាតិត្រូវសម្របសម្រួល និងត្រួតពិនិត្យដោយ ក.ប.អ.ក.(TPIT)។ ការិយាល័យគ្រប់គ្រងកម្មវិធីត្រូវបានបង្កើតឡើងសម្រាប់គោលបំណងនេះនៅក្នុងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ហើយត្រូវរាយការណ៍ដោយផ្ទាល់ទៅអគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម។ | បានទទួលអាណត្តិពី គ.ជ.ជ.អ.(NSCI) ដើម្បីទទួលរបាយការណ៍ពីស្ថាប័នផ្សេងៗ។ | ប្រជុំរៀងរាល់បីខែម្តង ឬក៏ច្រើនជាងនេះទៅតាមការចាំបាច់។ ធ្វើការសម្រេចចិត្តទៅលើបញ្ហាដែលកើតឡើងជាប្រចាំថ្ងៃ។ ស្នើសុំការសម្រេចពី គ.ជ.ជ.អ.(NSCI) ប្រសិនបើបញ្ហានោះនៅក្រៅវង្វង់សមត្ថកិច្ចរបស់ ក.ប.អ.ក.(TPIT)។ រៀបចំរបាយការណ៍រីកចម្រើនដាក់ជូនទៅ គ.ជ.ជ.អ.(NSCI)។ |

| អង្គភាព | មុខងារ | ការបែងចែកអាណត្តិ | ការផ្ញើរបាយការណ៍ |
| --- | --- | --- | --- |
| ស្ថាប័នចូលរួមអនុវត្ត ផ.យ.ជ.អ. ២០១៥-២០២៤ | មានតំណាងរបស់ខ្លួននៅក្នុង ក.ប.អ.ក.(TPIT)។<br>មានតំណាងរបស់ខ្លួននៅក្នុង គ.ជ.ជ.អ.(NSCI) ជារដ្ឋលេខាធិការនៃក្រសួងពាក់ព័ន្ធ ឬតំណាងដែលត្រូវបានជ្រើសរើស។<br>ស្ថាប័នទាំងអស់នេះត្រូវបានទទួលអាណត្តិក្នុងការអនុវត្តការងារពិសេសៗ (រៀបចំមុខងារ ប្រតិបត្តិមុខងារ អភិវឌ្ឍប្រព័ន្ធ ។ល។) | | រាយការណ៍តាមរបបដែលបានព្រមព្រៀងគ្នា ទៅ ក.ប.អ.ក.(TPIT)។ |

### ៧.៤. ការតាមដានត្រួតពិនិត្យលើការអនុវត្ត

ដោយសារតែការចុះបញ្ជីអត្រានុកូលដ្ឋានត្រូវអនុវត្តនៅថ្នាក់មូលដ្ឋានឃុំ សង្កាត់ទាំង១៦៣៣នោះ ការត្រួតពិនិត្យទៅលើការអនុវត្តកាងារនេះគឺមានភាពស្មុគស្មាញណាស់។ ឃុំ សង្កាត់គឺជាថ្នាក់ដ៏មានសារៈសំខាន់មួយក្នុងការផ្តល់សេវាកម្មដល់អចិតិជនដោយផ្ទាល់ និងត្រូវកំណត់អំពីគុណភាពសេវាផង។ ដូច្នេះការរៀបចំដំណើរការតាមដានត្រួតពិនិត្យនេះ គឺមានគោលបំណងអភិវឌ្ឍប្រព័ន្ធដែលមានប្រសិទ្ធភាព តាមរយៈការកំណត់នូវមុខងារឱ្យបានច្បាស់លាស់ និងជំហានជាក់លាក់សម្រាប់មន្ត្រីពាក់ព័ន្ធ ដើម្បីឱ្យស៊ីសង្វាក់ជាមួយការរៀបចំការចុះបញ្ជីដែលមានលក្ខណៈដូចការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ។

ដើម្បីធ្វើឱ្យសង្វាក់នៃការចុះបញ្ជីដំណើរការទៅប្រកបដោយប្រសិទ្ធភាពនោះ ប្រព័ន្ធតាមដានការបំពេញការងារត្រូវតែដាក់ឱ្យអនុវត្ត។ ប្រព័ន្ធផ្តល់ព័ត៌មានត្រលប់ គឺជាផ្នែកដំបូងដ៏សំខាន់មួយនៃការរៀបចំដ៏ស្មុគស្មាញនេះដែលតម្រូវឱ្យមានការកំណត់ឱ្យបានច្បាស់លាស់អំពីការបំពេញភារកិច្ចរបស់ខ្លួន និងកម្រិតនៃការបំពេញភារកិច្ចនោះនៅក្នុងប្រព័ន្ធទាំងមូល។ ដើម្បីធានាដំណើរការគ្រប់គ្រង តម្រូវការព័ត៌មានអំពីរបៀបដែលអង្គភាពនានាអាចឈានទៅសម្រេចបានតាមគោលបំណងសំខាន់ៗនោះ គឺជាប្រការដ៏សំខាន់ដើម្បីអាចចាត់វិធានការចាំបាច់ក្នុងការគាំទ្រប្រសិនបើមានការបរាជ័យ។

ហានិភ័យដ៏ចម្បងក្នុងចំណោមហានិភ័យធំៗនានា ដែលទំនងជាអាចកើតឡើងនៅក្នុងការអនុវត្តកម្មវិធីនោះ គឺការខកខានមិនបានយកចិត្តទុកដាក់ខ្ជាប់ខ្ជួនគ្រប់គ្រាន់ដើម្បីធានាស្តង់ដាបំពេញការងារ ហើយដែលបញ្ហានេះធ្លាប់បានកើតឡើងរួចមកហើយ។ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានត្រូវពឹងផ្អែកយ៉ាងខ្លាំងលើកត្តាមនុស្ស ហើយនឹងនៅតែបន្តពឹងផ្អែកទៅលើកត្តាមនុស្សនេះដដែល។ ដូច្នេះ វិធីសាស្ត្រគ្រប់គ្រងត្រូវតែត្រៀមទុកជាមុនឱ្យឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ដើម្បីធានាឱ្យមានការសម្រេចសមរម្យមួយ និងទាន់ពេលវេលាក្នុងការផ្គត់ផ្គង់ធន

ធានសមស្របសម្រាប់ការបំពេញការងារ ការផ្លាស់ប្តូរមន្ត្រី ប្រព័ន្ធលើកទឹកចិត្តដែលផ្អែកលើលទ្ធផល ឬផ្អែកលើការបំពេញការងារ សម្រាប់ជំរុញទឹកចិត្តមន្ត្រី ជាដើម។ វិធីសាស្ត្រគ្រប់គ្រងអាចត្រូវបានកំណត់ន័យដ៏សាមញ្ញមួយតាមរយៈល័ក្ខខ័ណ្ឌវិនិច្ឆ័យដូចខាងក្រោម ៖

- គោលបំណងបំពេញការងារ គោលដៅ កម្រិតសេវាកម្ម ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ និងគ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់បានដឹងពីបញ្ហានេះ។
- របាយការណ៍សកម្មភាពដែលបានទទួលពីព័ត៌មានត្រលប់ ត្រូវតែបញ្ជូនដល់ដៃមន្ត្រីដែលទទួលខុសត្រូវដោយផ្ទាល់សម្រាប់មុខងារជាក់លាក់នោះ។ ការសិក្សាជាច្រើនបានបង្ហាញថានៅពេលដែលបុគ្គលិកទទួលបានមតិយោបល់ត្រលប់អំពីការបំពេញការងាររបស់ពួកគេ ៗទំនងជានឹងកែតម្រូវអាកប្បកិរិយា និងរក្សាបាននូវការបំពេញភារកិច្ចរបស់ពួកគេ។
- គួររៀបចំឱ្យមានប្រព័ន្ធរបាយការណ៍ច្បាស់លាស់មួយ សម្រាប់រាយការណ៍ពីការបំពេញការងាររបស់មន្ត្រី និងប្រតិបត្តិការប្រព័ន្ធមកថ្នាក់លើ។ ការគ្រប់គ្រងនៅថ្នាក់លើ គួរតែមានមុខងារក្នុងការសម្រេចចិត្តទៅលើការចាត់ចែងមន្ត្រីឡើងវិញ ការផ្តល់ធនធានបន្ថែម ការផ្លាស់ប្តូរដំណើរការ ឬការផ្តល់ការគាំទ្របច្ចេកទេសជាដើម។
- ភាពញឹកញាប់ក្នុងការធ្វើរបាយការណ៍ អាស្រ័យទៅលើការងារដែលកំពុងតែធ្វើនោះ ឬក៏តាមកម្រិតនៃរបាយការណ៍នោះ ដែលជាទូទៅ ៖
  - បុគ្គលិកនៅក្នុងមុខងារគួរតែមានរបាយការណ៍ប្រចាំថ្ងៃ ឬរបាយការណ៍ញឹកញាប់
  - អ្នកមើលការខុសត្រូវផ្ទាល់របស់ពួកគេត្រូវទទួលរបាយការណ៍ប្រចាំថ្ងៃ
  - ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវតែមានរបាយការណ៍ប្រចាំសប្តាហ៍
  - អង្គភាពត្រួតពិនិត្យមើលការខុសត្រូវ ត្រូវតែទទួលរបាយការណ៍ប្រចាំខែ។
- របាយការណ៍ត្រូវរៀបរាប់អំពីកម្រិតសេវាដែលបានកំណត់ ឬបានព្រមព្រៀងគ្នា ធៀបជាមួយនឹងការបំពេញការងារជាក់ស្តែង តើបានសម្រេច ឬខកខានមិនបានសម្រេចតាមគោលដៅកម្រិតសេវាកម្មនោះ។
- របាយការណ៍ត្រូវតែរៀបចំឡើងតាមទម្រង់ច្បាស់លាស់ស្របតាមសូចនាករសកម្មភាពនានា ដូចជា ការទទួលស្គាល់នូវការបំពេញការងារល្អរបស់មន្ត្រី របស់ក្រុម ឬរបស់អង្គភាព ឬក៏អាចជាការស្នើឱ្យមានការចាត់វិធានការផ្នែកគ្រប់គ្រងណាមួយដើម្បីលុបបំបាត់ភាពអាក់សកម្មក្នុងការបំពេញការងារទាំងឡាយ។

## VIII. ក្របខ័ណ្ឌហិរញ្ញវត្ថុ

ក្របខ័ណ្ឌហិរញ្ញវត្ថុចាំបាច់ត្រូវការកំណត់ឱ្យបានច្បាស់លាស់ និងរក្សាបានទំហំសមស្រប ដើម្បីធានាឱ្យមាននិរន្តរភាពនៃប្រព័ន្ធអត្តសញ្ញាណកម្មនៅក្នុងប្រទេសកម្ពុជា ដូចដែលមានរៀបរាប់នៅក្នុងផែនការយុទ្ធសាស្ត្រនេះ។ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក៏ដូចជាការគាំទ្រពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ នឹងធ្វើឱ្យមានការកែលម្អយ៉ាងសំខាន់ទៅដល់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅក្នុងពេលបច្ចុប្បន្ននេះ ក៏ដូចជាការកសាងនូវអត្តសញ្ញាណប្រជាពលរដ្ឋមួយផងដែរ។

ប្រទេសកម្ពុជាកំពុងតែក្តោបក្តាប់ឱកាសដើម្បីទទួលបាននូវអត្ថប្រយោជន៍ពីបទពិសោធន៍ជាសកលដែលកំពុងតែមានស្រាប់ និងឆ្ពោះទៅផ្លាស់ប្តូរពីប្រព័ន្ធដែលប្រើប្រាស់ក្រដាស ទៅជាប្រព័ន្ធដែលប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានយ៉ាងឆាប់រហ័ស ដែលមានការចំណាយតិចនៅក្នុងការថែទាំ។ មធ្យោបាយនេះពិតជាមានសក្តានុពលក្នុងការធ្វើដំណើរឆ្ពោះទៅមុខ នៅក្នុងរយៈពេលខ្លីមួយ ពីប្រព័ន្ធចាស់ដែលមិនសូវជឿទុកចិត្តបានចំណាយច្រើន និងមិនសូវមានប្រសិទ្ធភាព ទៅកាន់ប្រព័ន្ធមួយដែលមានការចំណាយទាប និងមានប្រសិទ្ធភាពខ្ពស់ទៅពេលអនាគត។ ការផ្លាស់ប្តូរនេះនឹងទាមទារឱ្យមានការវិនិយោគមូលធន និងអភិវឌ្ឍន៍សមត្ថភាពរដ្ឋបាលថ្មីឱ្យបានគ្រប់គ្រាន់។ តែទោះយ៉ាងណា ទស្សនៈវិស័យផ្នែកសេដ្ឋកិច្ច គឺមានភាពរឹងមាំគ្រប់គ្រាន់ដើម្បីធានាថា តម្រូវការវិនិយោគត្រូវតែធ្វើឡើង ហើយថាដៃគូអន្តរជាតិត្រូវតែជួយប្រមូលអ្នកជំនាញការឱ្យបានគ្រប់គ្រាន់ និងការវិនិយោគរយៈពេលខ្លី ដើម្បីឱ្យប្រព័ន្ធនេះអាចដំណើរការទៅបានតាមការគ្រោងទុកទៅអនាគតប្រកបដោយនិរន្តរភាព។

ជំហានសំខាន់ៗខាងក្រោមនេះត្រូវបានគេប្រមើលមើលសម្រាប់ការអភិវឌ្ឍក្របខ័ណ្ឌហិរញ្ញវត្ថុ ៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលនៅក្នុងការអនុវត្ត ផ.យ.ជ.អ.២០១៥-២០២៤ គឺត្រូវបង្ហាញឡើងតាមរយៈការសន្ទត់អំពីកាតព្វកិច្ចហិរញ្ញវត្ថុសម្រាប់យកទៅអនុវត្តផែនការនេះ និងការជូនដំណឹងទៅដល់សភាជាតិនៃប្រទេសកម្ពុជាអំពីការប្តេជ្ញាចិត្តក្នុងការកែលម្អប្រព័ន្ធអត្តសញ្ញាណកម្មក្នុងរយៈពេល១០ឆ្នាំខាងមុខនេះ។ ក្របខ័ណ្ឌហិរញ្ញវត្ថុនឹងធានាដល់ផែនការវិនិយោគរបស់រាជរដ្ឋាភិបាលសម្រាប់ការអនុវត្ត និងសម្រាប់ការវិភាជថវិកាប្រចាំឆ្នាំប្រកបដោយនិរន្តរភាព (ដោយស្វ័យប្រវត្តិ) (ដែលអាចជាប្រព័ន្ធផ្អែកលើការបំពេញការងារ) ដើម្បីគ្របដណ្តប់ទៅលើការចំណាយប្រតិបត្តិការសម្រាប់ស្ថាប័ន ដែលកំពុងតែអនុវត្តផែនការយុទ្ធសាស្ត្រនេះ។ កម្មវិធីហិរញ្ញប្បទានដែលមាននិរន្តរភាពនឹងធានាឱ្យមានការអនុវត្តត្រឹមត្រូវតាមពេលវេលានៃគោលបំណងយុទ្ធសាស្ត្រទាំងអស់ និងប្រតិបត្តិការប្រព័ន្ធប្រព្រឹត្តទៅដោយរលូនមិនមានការរំខានទៅអនាគត។
- ការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុដ៏រឹងមាំរបស់រាជរដ្ឋាភិបាល គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ សហគមន៍ម្ចាស់ជំនួយ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិផ្សេងៗទៀត។ ក្នុងការគាំទ្រពីម្ចាស់ជំនួយអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ដល់ការអភិវឌ្ឍប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មជាតិ គោលការណ៍នៃប្រសិទ្ធភាពជំនួយត្រូវតែយកមកអនុវត្តដើម្បីធានាអំពីភាពជាម្ចាស់ និងតម្លាភាពនៅក្នុងការរៀបចំទាំងអស់នេះ។ ក្របខ័ណ្ឌហិរញ្ញវត្ថុដែលនឹងត្រូវបង្ហាញ ត្រូវមានការដាក់ឱ្យពិភាក្សា និងបានការឯកភាពគ្នានៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយម្ចាស់ជំនួយនានាដែលបានប្តេជ្ញាចិត្តក្នុង

ការគាំទ្រ ផ.យ.ជ.អ.២០១៥-២០២៤ នេះ។ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងសហគមន៍ម្ចាស់ជំនួយគឺត្រូវរៀបចំឡើងជាផ្លូវការ និងត្រូវអនុវត្តឱ្យបានម៉ត់ចត់ដោយភាគីទាំងអស់។

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលនេះ គឺត្រូវបកស្រាយគោលបំណងយុទ្ធសាស្ត្រនៃផែនការយុទ្ធសាស្ត្រនេះ សម្រាប់ដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រជាតិរបស់រាជរដ្ឋាភិបាល និងឯកសារផែនការយុទ្ធសាស្ត្រតាមវិស័យពាក់ព័ន្ធនានាផងដែរ។ ការធ្វើបែបនេះនឹងធានាឱ្យមានចីរភាព និងមានការជំនះតស៊ូនៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីអនុវត្តផែនការនេះ។

នៅពេលរៀបចំក្របខ័ណ្ឌហិរញ្ញវត្ថុ ចំណុចខាងក្រោមនេះគួរត្រូវយកទៅពិចារណា ៖

- តម្រូវការវិនិយោគទាំងមូលសម្រាប់ការអនុវត្ត ផ.យ.ជ.អ.២០១៥-២០២៤ នៅក្នុងដំណាក់កាលផ្សេងៗគ្នានៃការអនុវត្ត ៖ រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- ការចំណាយថែទាំទាំងអស់នៅក្នុងដំណាក់កាលអនុវត្តផ្សេងៗគ្នានេះ ៖ រយៈពេលខ្លី ពេលមធ្យម និងរយៈពេលវែង
- ការចំណាយទៅលើមន្ត្រីត្រូវរៀបចំឡើងដោយប្រមើលមើលលើសកម្មភាពនានាដែលត្រូវអនុវត្ត
- ការចំណាយប្រតិបត្តិការប្រចាំឆ្នាំជាមធ្យមសម្រាប់ការចុះបញ្ជី និងការងារអត្តសញ្ញាណកម្ម
- ប្រាក់ចំណូប្រចាំឆ្នាំជាមធ្យមដែលបានមកអំពីការចេញឯកសារអត្តសញ្ញាណ
- ត្រួតពិនិត្យឡើងវិញទៅលើអត្រាកម្រៃសេវាសម្រាប់ការចេញឯកសារអត្តសញ្ញាណ (ដូចជា អត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែន) ក្នុងគោលបំណងឱ្យអាចគ្របដណ្តប់ទៅលើការចំណាយក្នុងការចេញឯកសារទាំងអស់នេះ
- ប្រាក់ចំណូលជាមធ្យមប្រចាំឆ្នាំដែលអាចនឹងរកបានពីសេវាកម្ម ដែលផ្តល់ដោយការចុះបញ្ជីប្រជាពលរដ្ឋតាមរយៈប្រព័ន្ធបែងចែកទិន្នន័យ
- លទ្ធភាពរកចំណូលផ្សេងៗក្រៅពីការវិនិយោគពីរាជរដ្ឋាភិបាល
- ការរួមចំណែកជាសក្តានុពលពីដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយនានា។

ការប៉ាន់ប្រមាណជាសកលអំពីការចំណាយនេះ រួមបញ្ចូលទាំងការវិភាគអំពីថវិកាដែលត្រូវការសម្រាប់ការរៀបចំបង្កើត និងការបន្តនិរន្តរភាពនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និង ប.រ.អ.ព.(IPIS)។ ថវិកាប៉ាន់ស្មាន (សូមមើលចំណុច១០ខាងក្រោម) ប្រមើលមើលអំពីកម្រិតតម្រូវការចាំបាច់សម្រាប់ការវិនិយោគក្នុងការកសាងប្រព័ន្ធទាំងនេះ។ ការវិភាគក៏បានផ្តល់នូវការចង្អុលបង្ហាញមួយផងដែរអំពីថវិការំពឹងទុក ដែលនឹងត្រូវការដើម្បីថែទាំប្រព័ន្ធទាំងពីរនេះនៅក្នុងរយៈពេលខ្លី រយៈពេលមធ្យម រយៈពេលវែង ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រីកការចុះបញ្ជី និងការងារអត្តសញ្ញាណកម្ម។ បន្ថែមពីលើមូលធនវិនិយោគ និងការចំណាយសម្រាប់ការអភិវឌ្ឍដំបូង ការវិភាគត្រូវរួមបញ្ចូលការប៉ាន់ស្មានអំពីការកសាងសមត្ថភាព ដែលប្រទេសនេះត្រូវត្រៀមខ្លួនអនុវត្តតាមការប្តេជ្ញាចិត្ត ដែលជាចំណែកមួយនៃការចូលរួមក្នុងការអភិវឌ្ឍ និងប្រតិបត្តិការរយៈ ពេលវែងនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និង ប.រ.អ.ព.(IPIS)។ ការផ្តល់ហិរញ្ញប្បទានដែលមាននិរន្តរភាពរយៈពេលវែង គឺត្រូវមានប្រភពក្នុងស្រុក ដែលជាការធានាឱ្យរាជរដ្ឋាភិបាលអាចកសាងដោយធនធានផ្ទាល់ខ្លួនដើម្បីថែទាំប្រព័ន្ធទាំងអស់នេះនៅក្នុងរយៈពេលវែង។

ការវិនិយោគដ៏ធំបំផុតត្រូវបានគេមើលឃើញនៅក្នុងអំឡុងពេល៥ឆ្នាំដំបូងនៃការអនុវត្ត ដូច្នេះប្រព័ន្ធអាចចាប់ផ្តើមដំណើរការនៅក្នុងរយៈពេលមធ្យមបាន។ ការចំណាយប្រតិបត្តិការ គឺនៅរក្សាក្នុងកម្រិតមួយដដែលរហូតដល់បញ្ចប់ការអនុវត្តផែនការយុទ្ធសាស្ត្រ ដែលនៅពេលនោះប្រព័ន្ធទាំងអស់នឹងរៀបចំបានរួចរាល់។

## IX. ផែនទីបង្ហាញផ្លូវសម្រាប់ផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម




*កំណត់សម្គាល់ ៖ យ៉ាងហោចណាស់គោលដៅមួយនៃគោលបំណងយុទ្ធសាស្ត្រ ត្រូវបានរៀបចំផែនការ អភិវឌ្ឍ និងចាប់ផ្តើមប្រតិបត្តិ*

## X. ថវិកាប៉ាន់ស្មាន

ផែនការថវិកាកម្រិតខ្ពស់សម្រាប់ការអនុវត្ត ផ.យ.ជ.អ.២០១៥-២០២៤ បានបង្ហាញនៅក្នុងឧបសម្ពន្ធទី១នេះ។ ថវិកាត្រូវបានរៀបចំបង្កើតឡើងដោយផ្អែកទៅលើការវិភាគប្រព័ន្ធ ការពិគ្រោះយោបល់ និងវិសាលភាពនៃផែនការយុទ្ធសាស្ត្រជាតិនេះ។

| ល.រ | វិស័យហិរញ្ញប្បទាន | ការវិនិយោគ | ចំណាយប្រតិបត្តិការសម្រាប់១ឆ្នាំ | ការវិនិយោគនិងការចំណាយប្រតិបត្តិការ ២០១៦-២០១៨ | ការវិនិយោគនិងការចំណាយប្រតិបត្តិការ ២០១៩-២០២១ | ការវិនិយោគនិងការចំណាយប្រតិបត្តិការ ២០២២-២០២៤ |
|---|---|---|---|---|---|---|
| ១ | **ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិ** | 400,000.00 | | 400,000.00 | | |
| ២ | **រៀបចំបានការិយាល័យចុះបញ្ជី និងការកសាងសមត្ថភាពអំពីប្រព័ន្ធឌីជីថលដល់ឃុំ សង្កាត់ (ការិយាល័យទាំង១៦៣៣កន្លែង)** | | | | | |
| ២.១ | Mobile Windows tablets | 1,355,000.00 | | 1,355,000.00 | | |
| ២.២ | Mobile printing solution with mobile printers | 250,000.00 | | 250,000.00 | | |
| ២.៣ | ការថែទាំទីតាំងចំនួន១៦៣៣ * | | 326,600.00 | 326,600.00 | 979,800.00 | 979,800.00 |
| ២.៤ | ការផ្គត់ផ្គង់បណ្តាញអ៊ីនធឺណែត | | 200,000.00 | 200,000.00 | 600,000.00 | 600,000.00 |
| ៣ | **ការបង្កើតមជ្ឈមណ្ឌលទិន្នន័យ (Establishment of Data Center)** | | | | | |
| ៣.១ | ប្រព័ន្ធការពារកម្តៅ ប្រព័ន្ធបូមខ្យល់ និងប្រព័ន្ធត្រជាក់ | 150,000.00 | | 150,000.00 | | |
| ៣.២ | ការផ្គត់ផ្គង់អគ្គិសនី និងម៉ាស៊ីនភ្លើង | 200,000.00 | | 200,000.00 | | |
| ៣.៣ | ឧបករណ៍ផ្គត់ផ្គង់អគ្គីសនីដោយមិនមានការអាក់ខាន | 150,000.00 | | 150,000.00 | | |
| ៣.៤ | ឧបករណ៍សុវត្ថិភាព និងប្រព័ន្ធតាមដាន និងប្រព័ន្ធប្រកាសអាសន្ន | 50,000.00 | | 50,000.00 | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣.៥ | ការថែទាំ និងការគាំទ្រ | | 15,000.00 | 30,000.00 | 45,000.00 | 45,000.00 |
| **៤** | **ការបង្កើតហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់ (Establishment of Resilience Infrastructure)** | | | | | |
| ៤.១ | ដំណោះស្រាយផ្នែកបណ្តាញនៃមជ្ឈមណ្ឌលទិន្នន័យ (Data Center networking solution) | 800,000.00 | | 800,000.00 | | |
| ៤.២ | ឧបករណ៍ការពារ (Firewall) ការការពារការគំរាមកំហែង (Threat protection) និងដំណោះស្រាយក្នុងការគ្រប់គ្រង | 350,000.00 | | 350,000.00 | | |
| ៤.៣ | ម៉ាស៊ីនមេ (Server) រួមជាមួយប្រព័ន្ធប្រតិបត្តិការ និង Virtualization Software | 300,000.00 | | 300,000.00 | | |
| ៤.៤ | បណ្តាញប្រព័ន្ធផ្ទុកទិន្នន័យ និងដំណោះស្រាយនៃការផ្ទុកទិន្នន័យ | 500,000.00 | | 500,000.00 | | |
| ៤.៥ | ដំណោះស្រាយសម្រាប់ការគ្រប់គ្រង និងការត្រួតពិនិត្យ | 130,000.00 | | 130,000.00 | | |
| ៤.៦ | ថែទាំហេដ្ឋារចនាសម្ព័ន្ធ និងការគាំទ្រ | | 250,000.00 | 250,000.00 | 750,000.00 | 750,000.00 |
| **៥** | **ការអភិវឌ្ឍប្រព័ន្ធព័ត៌មាន (Information System Development)** | | | | | |
| ៥.១ | ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន | 1,300,000.00 | | 1,300,000.00 | | |
| ៥.២ | លេខកូដអត្តសញ្ញាណខ្មែរ (KIDC) | 300,000.00 | | 300,000.00 | | |
| ៥.៣ | ការអភិវឌ្ឍប្រព័ន្ធចុះបញ្ជីការស្នាក់នៅដោយផ្អែកលើ ប.វ.គ.ព.(ICT) | 1,300,000.00 | | | 1,300,000.00 | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥.៤ | ធ្វើសវនកម្មទៅលើប្រព័ន្ធអត្តសញ្ញាណប័ណ្ណមុនពេលផ្តល់ ល.ក.អ.ឧ.(KIDC) | 600,000.00 | | 600,000.00 | | |
| ៥.៥ | ប្រព័ន្ធរួមអត្តសញ្ញាណកម្មពលរដ្ឋ(IPIS) | 1,300,000.00 | | | 1,300,000.00 | |
| ៥.៦ | ប្រព័ន្ធបែងចែកព័ត៌មាន | 500,000.00 | | | 500,000.00 | |
| ៥.៧ | RDBMS, Application and enterprise service bus software | 1,500,000.00 | | | 1,500,000.00 | |
| ៥.៨ | ការបង្កើតសេវាកម្មតាមប្រព័ន្ធអេឡិចត្រូនិច (E-services establishment) | 300,000.00 | | | | 300,000.00 |
| ៥.៩ | Go life technical assistance | 700,000.00 | | 400,000.00 | 300,000.00 | |
| ៥.១០ | ការធ្វើសវនកម្មផ្នែកសន្តិសុខ (Security audits) | 100,000.00 | | 100,000.00 | | |
| ៥.១១ | ការធ្វើសវនកម្មផ្នែកសន្តិសុខជាទៀងទាត់ (Regular security audits) | | 70,000.00 | 70,000.00 | 210,000.00 | 210,000.00 |
| ៥.១២ | ការថែទាំ (Software) និងការគាំទ្រ | | 700,000.00 | 350,000.00 | 2,100,000.00 | 2,100,000.00 |
| **៦** | **ការបង្កើតមជ្ឈមណ្ឌលសង្គ្រោះទិន្នន័យពេលមានគ្រោះមហន្តរាយ (Establishment of Disaster Recovery Data Center)** | | | | | |
| ៦.១ | ឧបករណ៍សម្ភារៈសម្រាប់មជ្ឈមណ្ឌលទិន្នន័យ | 500,000.00 | | | 500,000.00 | |
| ៦.២ | ការបង្កើតឱ្យមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់សង្គ្រោះពេលមានគ្រោះមហន្តរាយ (Establishment of Disaster Recovery Infrastructure) | 1,500,000.00 | | | 1,500,000.00 | |

| | | | | | | |
|---|---|---|---|---|---|---|
| ៦.៣ | ការរៀបចំផែនការសង្គ្រោះនៅពេលមានមហន្តរាយ និងការអនុវត្ត | 100,000.00 | | | 100,000.00 | |
| ៦.៤ | ការសាកល្បង និងការបណ្តុះបណ្តាលឱ្យយល់ដឹងអំពីការសង្គ្រោះពេលមានគ្រោះមហន្តរាយ | 50,000.00 | | | 50,000.00 | |
| ៦.៥ | ការបន្តធ្វើតេស្តសាកល្បងការសង្គ្រោះនៅពេលមានគ្រោះមហន្តរាយ | | 20,000.00 | | 60,000.00 | 60,000.00 |
| ៦.៦ | ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងការគាំទ្រ | | 265,000.00 | | 795,000.00 | 795,000.00 |
| **៧** | **ការបង្កើតសេវាដែលមាននិរន្តរភាព និងស្ថាប័នគាំទ្រសម្រាប់បម្រើប្រជាពលរដ្ឋ ( Establishment of sustainable service and support organization for serving citizens )** | | | | | |
| ៧.១ | Help desk system and implementation | 100,000.00 | | 50,000.00 | 50,000.00 | |
| ៧.២ | ការអនុវត្តបញ្ញត្តិគ្រប់គ្រងសេវាកម្មបច្ចេកវិទ្យាព័ត៌មាន ( IT service manage-ment concept implementation ) | 100,000.00 | | | 100,000.00 | |
| ៧.៣ | ការគាំទ្រដល់អ្នកប្រើប្រាស់តាមរយៈការចុះបញ្ជី ( User support through registration process ) | | 30,000.00 | 30,000.00 | 90,000.00 | 90,000.00 |
| **៨** | **វាយបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានដែលមានស្រាប់ជាឌីជីថល ( Digitization of existing registration records )** | **2,000,000.00** | | **1,000,000.00** | **1,000,000.00** | |
| **៩** | **ការអភិវឌ្ឍគោលការណ៍ណែនាំ និងនីតិវិធី** | **400,000.00** | | **200,000.00** | **200,000.00** | |

| | | | | | | |
|---|---|---|---|---|---|---|
| | ប្រតិបត្តិការ (Development of operational guidelines and procedures) | | | | | |
| **១០** | **ការកសាងសមត្ថភាព** | 2,250,000.00 | | | | |
| ១០.១ | ការកសាងសមត្ថភាពមន្ត្រីអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មអំពីការប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននិងស្ថិតិអត្រានុកូលដ្ឋាន ប.វ.គ.ព.(ICT) ការផ្តល់សេវាកម្ម ការរៀនសូត្រពីបទពិសោធន៍របស់ប្រទេសផ្សេងៗទៀត | | | 150,000.00 | 150,000.00 | 150,000.00 |
| ១០.២ | ការកសាងសមត្ថភាពនៅថ្នាក់មូលដ្ឋានអំពីក្របខ័ណ្ឌច្បាប់ ដំណើរការនិងនីតិវិធីការប្រើប្រាស់ ប.វ.គ.ព.(ICT) និងការផ្តល់សេវាកម្ម | | | 600,000.00 | 600,000.00 | 600,000.00 |
| ១០.៣ | ការកសាងសមត្ថភាពជាបន្តបន្ទាប់ដើម្បីថែទាំប្រព័ន្ធ ប.វ.គ.ព.(ICT) | | 100,000.00 | 100,000.00 | 300,000.00 | 300,000.00 |
| **១១** | **យុទ្ធនាការតស៊ូមតិ និងទំនាក់ទំនង** (Advocacy and communication campaigns) | 8,600,000.00 | | | | |
| ១១.១ | យុទ្ធនាការជាតិអំពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន ការណែនាំអំពី ល.ក.អ.ខ.(KIDC) និងការណែនាំអំពី | | | 2,000,000.00 | 3,000,000.00 | 1,500,000.00 |

| | | | | | | |
|---|---|---|---|---|---|---|
| | សេវាកម្មថ្មី | | | | | |
| ១១.២ | យុទ្ធការផ្តោតទៅលើគោលដៅដែលពិបាកទៅដល់ ជនបាត់បង់សមត្ថភាពពលកម្ម និងក្រុមជនដែលបានទទួលការយកចិត្តទុកដាក់តិចតួច | | | 300,000.00 | 600,000.00 | 300,000.00 |
| ១១.៣ | ខ្សែទូរស័ព្ទឥតគិតថ្លៃសម្រាប់ទទួលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ ( Toll-free telephone line for citizen feedback ) | | 100,000.00 | 200,000.00 | 300,000.00 | 300,000.00 |
| **១២** | **សកម្មភាពផ្សព្វផ្សាយ** ( Outreach activities ) | | | | | |
| ១២.១ | សកម្មភាពផ្សព្វផ្សាយដើម្បីបង្កើនអត្រាគ្របដណ្តប់ | | 600,000.00 | 600,000.00 | 600,000.00 | 600,000.00 |
| ១២.២ | សកម្មភាពផ្សព្វផ្សាយ និងកសាងសមត្ថភាពដល់ផ្នែកសាធារណៈនិងផ្នែកឯកជនដើម្បីប្រើប្រាស់មជ្ឈមណ្ឌលផ្សព្វផ្សាយទិន្នន័យ | 100,000.00 | | | 50,000.00 | 50,000.00 |
| ១៣ | ការតម្រឹមស្ថាប័នឱ្យស្របតាមរចនាសម្ព័ន្ធច្រកចេញចូលតែមួយ | 400,000.00 | | 100,000.00 | 300,000.00 | |
| | **ចំណាយវិនិយោគ** | **28,635,000.00** | **2,676,600.00** | **11,735,000.00** | **13,100,000.00** | **2,900,000.00** |
| | **ចំណាយប្រតិបត្តិការ** | **15,816,200.00** | | **2,156,600.00** | **6,829,800.00** | **6,829,800.00** |
| | **សរុប USD** | **44,451,200.00** | | | | |

## XI. ការតាមដានត្រួតពិនិត្យ

| សកម្មភាពចម្បងៗ/ឆ្នាំ | | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 |
|---|---|---|---|---|---|---|---|---|---|---|---|
| ច្បាប់ស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋានត្រូវបានអនុម័ត | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាន អត្តសញ្ញាណកម្ម និងស្ថិតិអត្រានុកូលដ្ឋានត្រូវបានអនុម័ត | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| វិសោធនកម្មច្បាប់ដែលមានភាពចាំបាច់សម្រាប់បង្កើត ប.រ.អ.ព.(IPIS) ត្រូវបានអនុម័ត | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| អនុក្រឹត្យដែលមានភាពចាំបាច់សម្រាប់បង្កើត ប.រ.អ.ព.(IPIS) ត្រូវបានអនុម័ត | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| មជ្ឈមណ្ឌលទិន្នន័យទំនើប និងមានសុវត្ថិភាពសម្រាប់ ប.រ.អ.ព.(IPIS) ត្រូវបានបង្កើតឡើង | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ការកែសម្រួលរបៀបរបបការងារសម្រាប់លើកកម្ពស់ការផ្តល់សេវា | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានមានលក្ខណៈជាសកល និងដោយប្រើប្រាស់ ប.វ.គ.ព.(ICT) ត្រូវបានបង្កើត | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| បញ្ជីប្រជាពលរដ្ឋត្រូវបានបង្កើត | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ប្រព័ន្ធគ្រប់គ្រងការស្នាក់នៅទំនើបត្រូវបានបង្កើត និងត្រូវភ្ជាប់ជាមួយ ប.រ.អ.ព.(IPIS) | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យសញ្ជាតិត្រូវបានបង្កើតឡើង និងភ្ជាប់ជាមួយ | ជាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |

| សកម្មភាពចម្បងៗ/ឆ្នាំ | | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 |
|---|---|---|---|---|---|---|---|---|---|---|---|
| ប.រ.អ.ព.(IPIS) | | | | | | | | | | | |
| ប្រព័ន្ធអត្តសញ្ញាណប័ណ្ណខ្មែរត្រូវបានធ្វើទំនើបកម្ម និងភ្ជាប់ជាមួយ ប.រ.អ.ព.(IPIS) | ដាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ប្រព័ន្ធលិខិតឆ្លងដែនត្រូវបានធ្វើទំនើបកម្ម និងភ្ជាប់ជាមួយ ប.រ.អ.ព.(IPIS) | ដាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ល.ក.អ.ខ.(KIDC) ត្រូវបានផ្តល់ឱ្យប្រជាពលរដ្ឋទាំងអស់ដែលបានកំណត់អត្តសញ្ញាណរួច | ដាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ប្រព័ន្ធបែងចែកទិន្នន័យត្រូវបានបង្កើត | ដាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ដំណើការអភិបាលកិច្ចតាមប្រព័ន្ធអេឡិចត្រូនិចត្រូវបានដាក់ឱ្យប្រើប្រាស់ | ដាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋានត្រូវបានបង្កើត | ដាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| អត្រាដណ្តប់នៃការចុះបញ្ជីអត្រានុកូលដ្ឋានមានការកើនឡើង | ដាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានត្រូវបានភ្ជាប់ជាមួយប្រព័ន្ធជំនួយផ្សេងទៀតសម្រាប់ផ្លាស់ប្តូរទិន្នន័យ | ដាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |
| បំពេញបានសំណើសុំព័ត៌មានចំនួន២លានក្នុងមួយឆ្នាំ | ដាក់ស្តែង | ◆ | | | | | | | | | |
| | ដើមគ្រា | | | | | | | | | | |

## កំណត់សម្គាល់ដើមគ្រា

| | |
|---|---|
| | កំពុងដំណើរការ |
| | មិនមានសកម្មភាព |
| | ការងារបានសម្រេច |

កំណត់សម្គាល់អំពីការអនុវត្តជាក់ស្តែង

| | |
|---|---|
| ◆ (បៃតង) | រីកចម្រើនតាមផែនការ |
| ◆ (លឿង) | ហានិភ័យមិនបានបញ្ចប់តាមកាលកំណត់ ការពន្យារពេលច្រើនជាងការកំណត់ដើមគ្រា |
| ◆ (ក្រហម) | ហានិភ័យខ្ពស់មិនបានបញ្ចប់តាមកាលកំណត់ |
| ◆ (ខៀវខ្ចី) | គ្មានសកម្មភាព ស្ថិតនៅស្ថានភាពដើមគ្រា |